**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលឃុំសាន់គ ស្រុកកំពង់ស្វាយ (ខេត្តកំពង់ធំ)

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា ឈាន ធីណា**

**លោក រស់ វណ្ណា**

ណែនាំដោយសាស្ត្រាចារ្យរង៖

**បណ្ឌិត សឿន សោភ័ណ**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៧

ឆ្នាំចូលរៀន ២០២០

ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលឃុំសាន់គ ស្រុកកំពង់ស្វាយ

# (ខេត្តកំពង់ធំ)

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា ឈាន ធីណា**

**លោក រស់ វណ្ណា**

ណែនាំដោយសាស្ត្រាចារ្យរង៖

**បណ្ឌិត សឿន សោភ័ណ**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៧

ឆ្នាំចូលរៀន ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ និងខ្ញុំបាទ ឈ្មោះ **ឈាន ធីណា** និង **រស់ ចន្ណា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាញរដ្ឋបាលសាធារណៈ ឆ្នាំទី៤ ជំនាន់ទី១៧ ក្រុម P4C4 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២៣-២០២៤។

## សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ

សូមគោរពសម្តែងនូវកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះ **លោកឪពុក** និង**អ្នកម្តាយ** ទាំងពីរដែលលោកជាអ្នកមានគុណយ៉ាងធំធេង ចំពោះកូនដែលមានតម្លៃពុំអាចកាត់ថ្លៃបាន ព្រោះលោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូនៗតាំងពីកូននៅក្នុងឧទរនៅឡើយ ហើយពេលដែលកូនធំដឹងក្តីបន្តិចឡើង លោកទាំងពីរបានទូន្មានប្រៀនប្រដៅដាស់តឿនកូនឱ្យប្រព្រឹត្តតែអំពើល្អ សេពគប់មិត្តភក្តិល្អជាដើម ម្យ៉ាងវិញទៀតលោកបានធ្វើការទាំងថ្ងៃក្តៅ យប់រងារត្រជាក់សព្វគ្រប់បែបយ៉ាងដើម្បីបានថវិកាយកមកទំនុកបម្រុងការសិក្សារបស់កូន ព្រមទាំងផ្តល់ការស្រឡាញ់ ការថ្នាក់ថ្នម ភាពកក់ក្តៅ និងការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ ដល់កូនៗទាំងអស់គ្នា ទាំងនេះជាមហាគុណដ៏ធំធេងដែលកូនមិនអាចបំភ្លេចបានឡើយនៅក្នុងជីវិតរបស់កូន។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់**ឯកឧត្តមបណ្ឌិត លុយ ចន្ណា សាកលវិទ្យាធិការ** និងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ ព្រមទាំងសាស្ត្រាចារ្យគ្រប់រូប នៃសាកលវិទ្យា-ល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ដោយទំនួលខុសត្រូវយ៉ាងខ្ពង់ខ្ពស់ចំពោះការសិក្សារបស់និស្សិតទាំងអស់ ដោយលោកមិនគិតពីបញ្ហាលំបាកនឿយហត់ដោយប្រការណាមួយឡើយ លោកបានខិតខំដាស់តឿន អប់រំសិស្សនិងនិស្សិតឱ្យខិតខំប្រឹងប្រែងរៀនសូត្រ ស្វែងរកចំណេះវិជ្ជាមកដាក់នៅក្នុងខ្លួន និងពង្រឹងខ្លួនឯងធ្វើយ៉ាងណាឱ្យក្លាយជាមនុស្សម្នាក់ដែលមានសមត្ថភាពពេញលេញដែលសង្គមត្រូវការ។ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យគ្រប់រូបលោកក៏ខិតខំប្រឹងប្រែងរកនូវរបកគំហើញថ្មីៗបន្ថែមទៀតដើម្បីផ្ទេរនូវពុទ្ធិ និងបទពិសោធន៍ដ៏ល្អដល់សិស្សនិស្សិតគ្រប់ៗគ្នាផងដែរ។

ជាពិសេសយើងខ្ញុំ សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ សាស្ត្រាចារ្យរង បណ្ឌិត **សឿន សោភ័ណ** ដែលជាសាស្ត្រាចារ្យណែនាំរបស់យើងខ្ញុំទាំងពីរនាក់ លោកគ្រូតែងតែផ្តល់នូវគំនិត គន្លឹះ ទ្រឹស្តី និងការអនុវត្តក្នុងការសិក្សាឈ្វេងយល់លើប្រធានបទរបស់នាងខ្ញុំ និងខ្ញុំបាទទាំងពីរ លោកសាស្ត្រាចារ្យមិនដែលរអ៊ូរទាំ ឬមានភាពធុញទ្រាន់ចំពោះការផ្តល់នូវគំនិតយោបល់អ្វីឡើយ ទោះបីជាលោកមានការនឿយហត់នៅក្នុងការបំពេញការងារក៏ពិតមែនឬ ការបង្ហាត់បង្រៀនយ៉ាងណាក្តីក៏សាស្ត្រាចារ្យលោកតែងតែផ្តល់ស្នាមញញឹម និងបានផ្តល់នូវភាពសប្បាយរីករាយពេលឃើញសិស្ស និស្សិតខិតខំសិក្សាស្រាវជ្រាវឯកសារនានាដែលពាក់ព័ន្ធនឹងប្រធានបទ លោកសាស្ត្រាចារ្យថែមទាំងព្យាយាមពន្យល់ណែនាំ និងប្រាប់បទពិសោធន៍ល្អៗព្រមទាំងវិធីសាស្ត្រផ្សេងៗ ដែលទាក់ទងនឹងការសិក្សាស្រាវជ្រាវឱ្យកាន់តែមានភាពងាយស្រួលផងដែរ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក **ជួ សួន** មេឃុំនៃសាលាឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ លោក លោកស្រី ដែលជាក្រុមប្រឹក្សា ជាថ្នាក់ដឹកនាំ និងបុគ្គលិករបស់រដ្ឋបាលឃុំគ្រប់លំដាប់ថ្នាក់

ទាំងអស់ដែលបានអនុញ្ញាត និងផ្តលឱកាសដល់នាងខ្ញុំ និងខ្ញុំបាទឱ្យបានសិក្សាឈ្វេងយល់លើឯកសារនានា រួមទាំងដំណើរការនៃការផ្តល់សេវារបស់រដ្ឋបាលឃុំសាន់គ ទាំងមូល ដើម្បីទទួលបាននូវចំណេះដឹងបទពិសោធន៍នៃការអនុវត្តជាក់ស្តែងក្នុងការយកមករៀបរៀងចងក្រងកិច្ចការមួយនេះជាសារណា ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ។

ជាពិសេសសូមថ្លែងអំណរគុណចំពោះលោក **ខា ណារ៉ុខ** ស្មៀនឃុំសាន់គ ដែលបានផ្តល់ឱកាសដល់នាងខ្ញុំនិងខ្ញុំបាទបានចុះសិក្សាស្រាវជ្រាវ និងស្វែងរកឯកសារនានាដែលពាក់ព័ន្ធនឹងប្រធានបទរបស់យើងខ្ញុំទាំងពីររូប ប្រកបដោយការយកចិត្តទុកដាក់ និងរួសរាយរាក់ទាក់ដោយសេចក្តីគោរពរាប់អាន លោក ក៏បានចំណាយពេលវេលាដ៏មានតម្លៃ និងមមាញឹកក្នុងការងារ ដើម្បីជួយពន្យល់បន្ថែមយ៉ាងក្បោះក្បាយ និងយកចិត្តទុកដាក់បំផុត។

ជាចុងបញ្ចប់យើងខ្ញុំសូមជូនស្នាដៃ និងគុណតម្លៃទាំងឡាយដែលបានទទួលពីការសិក្សាស្រាវជ្រាមួយនេះជូនចំពោះអស់លោកអ្នកមានគុណដូចដែលនាងខ្ញុំ និងខ្ញុំបាទបានជម្រាបរៀបរាប់ខាងលើ។ នាងខ្ញុំ និងខ្ញុំបាទសូមប្តេជ្ញាចិត្តថានឹងយកនូវចំណេះដឹង បញ្ញា ស្មារតី កម្លាំងកាយចិត្តដែលមានទៅជួយសង្គមជាតិមួយនេះឱ្យសមនឹងការតបស្នង ជួយជ្រោមជ្រែងដ៏មានតម្លៃរបស់លោកអ្នកទាំងអស់គ្នា។ ជាមួយគ្នានេះដែរ នាងខ្ញុំ និងខ្ញុំបាទសូមប្រសិទ្ធិពរជ័យជូនដល់លោកឪពុក អ្នកម្តាយ ឯកឧត្តម លោក លោកស្រី ទាំងអស់សូមឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងទទួលបាននូវជោគជ័យគ្រប់ភារកិច្ចការងារកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រុមនាងខ្ញុំ និងខ្ញុំបាទទាំងពីររូបសូមគោរពចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ** លោកគ្រូ អ្នកគ្រូ និងមិត្តនិស្សិតរួមជំនាន់គ្រប់រូប មិត្តអ្នកអាននានា ដោយក្តីគោរព និងស្រឡាញ់។

នាងខ្ញុំ និងខ្ញុំបាទជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បន្ទាប់ពីបានឆ្លងកាត់នូវការសិក្សា និងក្រេបយកចំណេះដឹងអស់រយៈពេល ៤ឆ្នាំមកនេះ នាងខ្ញុំ និងខ្ញុំបាទបានទទួលនូវចំណេះជាច្រើនលើជំនាញរដ្ឋបាលសាធារណៈ។ ដោយក្រុមខ្ញុំទាំងពីររូប បានព្យាយាម និងបានខិតខំអស់ពីកម្លាំងកាយចិត្ត សម្រាប់នូវការរៀបចំកិច្ចការស្រាវជ្រាវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈនេះឡើងមកគួបផ្សំដោយការប្រព្រឹត្តនៅក្រោម ពាក្យណែនាំ និងបង្ហាត់បង្ហាញដោយផ្ទាល់ពីសំណាក់សាស្ត្រាចារ្យរង បណ្ឌិត **សឿន សោភ័ណ** ដែលជាសាស្ត្រាចារ្យ ដឹកនាំ ដោយបានសម្រេចចិត្តជ្រើសរើសក្រោមប្រធានបទស្តីអំពី «**ការគ្រប់គ្រងរដ្ឋបាល-ឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ** »។

គោលបំណងដែលក្រុមនាងខ្ញុំ និងខ្ញុំបាទជ្រើសរើសយកប្រធានបទមួយនេះ ពីព្រោះវាពិតជាមានសារៈសំខាន់ចំពោះនិស្សិត-សាមណនិស្សិតរដ្ឋបាលសាធារណៈ ថែមទាំងរួមចំណែកផ្តល់ជាចំណេះដឹងដល់និស្សិតគ្រប់មជ្ឈដ្ឋាន និងសម្រាប់អ្នកស្រាវជ្រាវទាំងឡាយ ដែលចង់ដឹងពីបែបបទនៃការរៀបចំ ការប្រព្រឹត្តទៅរបស់រដ្ឋបាលថ្នាក់ឃុំ សង្កាត់ បញ្ហាប្រឈម និងដំណោះស្រាយទៅ លើផលវិបាកមួយចំនួនដែលធ្វើឱ្យមានការរាំងស្ទះដល់ការអនុវត្តការគ្រប់គ្រងរដ្ឋបាលស្រុកជាដើម។

ក្រុមនាងខ្ញុំ និងខ្ញុំបាទទាំងពីររូប ពិតជាមានសេចក្តីសោមនស្សរីករាយក្រៃលែងក្នុងការលះបង់អស់ពីកម្លាំងកាយចិត្ត ពេលវេលា និងថវិកាផ្ទាល់ខ្លួនក្នុងការរៀបចំសារណានេះឱ្យចេញជារូបរាងឡើង ដើម្បីចងក្រងទុកជាអត្ថបទ និងជាជំនួយដល់និស្សិត-សាមណៈនិស្សិតគ្រប់ជំនាន់ទុកជាមូលដ្ឋានបណ្តុះគំនិតបញ្ញាស្មារតី និងការស្វែងយល់ឱ្យបានកាន់តែច្បាស់នូវចំណេះដឹងដែលទាក់ទងនឹងប្រធានបទនេះ។

ជាទីអវសាននេះ សូមជូនពរដល់ ឯកឧត្តមសាកលវិទ្យាធិការ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងមិត្តអ្នកអានគ្រប់រូបឲ្យជួបប្រទះតែភាពសុខដុមរម្យនា រុងរឿងថ្កុំថ្កើង និងមានសុភមង្គលជានិរន្តរាយ កុំបីឃ្លៀង ឃ្លាតឡើយ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមនាងខ្ញុំ និងខ្ញុំបាទទាំងពីររូប ជានិស្សិតដែលមានចំណេះដឹងនៅមានកម្រិត នាងខ្ញុំ និងខ្ញុំបាទសូម ឱនលំទនសុំការអភ័យទោសផងដែរ ចំពោះការខ្វះខាតក្នុងការសិក្សាស្រាវជ្រាវនូវប្រធានបទមួយនេះ យើងខ្ញុំនឹងរងចាំដោយរីករាយសម្រាប់ទទួលការរិះគន់ដើម្បីស្តាបនាពីសំណាក់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងមិត្ត អ្នកអានជាទីគោរពគ្រប់វិនាទី។

# មាតិកា


**សេចក្តីផ្តើម** ........ ១

១. លំនាំនៃការសិក្សាស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហា ........ ២

៣. គោលបំណង ........ ២

៤. ដែនកំណត់ និងវិសាលភាព ........ ២

៥. វិធីសាស្ត្រស្រាវជ្រាវ ........ ៣

៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

**ជំពូកទី១. សញ្ញាណទូទៅនៃការគ្រប់គ្រងរដ្ឋបាលឃុំ**

**១.១. លក្ខណៈទូទៅនៃរដ្ឋបាល** ........ ៤

១.១.១. និយមន័យ ........ ៦

១.១.២. គោលដៅរបស់រដ្ឋបាល ........ ៧

១.១.៣. មធ្យោបាយរបស់រដ្ឋបាល ........ ៨

**១.២. ប្រវត្តិនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា** ........ ៧

១.២.១. អភិបាលកិច្ចមូលដ្ឋាននៅកម្ពុជាចាប់ពីឆ្នាំ១៩០៨ ដល់ឆ្នាំ១៩៥៥ ........ ១០

១.២.២. អភិបាលកិច្ចមូលដ្ឋាននៅកម្ពុជាចាប់ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧៩ ........ ១២

១.២.៣. អភិបាលកិច្ចមូលដ្ឋាននៅកម្ពុជាចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ ........ ១៣

១.២.៤. អភិបាលកិច្ចមូលដ្ឋានក្រោយការបោះឆ្នោតជាតិឆ្នាំ១៩៩៣ ........ ១៥

**១.៣. ប្រព័ន្ធវិមជ្ឈការ និងប្រព័ន្ធវិសហមជ្ឈការ** ........ ១៦

១.៣.១. ប្រព័ន្ធវិមជ្ឈការ ........ ១៦

១.៣.១.១. និយមន័យ ........ ១៦

១.៣.១.២. ប្រភេទវិមជ្ឈការ ........ ១៨

១.៣.១.៣. វិមជ្ឈការបច្ចេកទេស ........ ១៩

១.៣.១.៤. វិមជ្ឈការដែនដី ........ ១៩

១.៣.១.៥. គោលបំណងនៃធ្វើវិមជ្ឈការ ............................................................................................20
១.៣.២. វិមជ្ឈការនៅកម្ពុជានាពេលបច្ចុប្បន្ន............................................................................................២០
១.៣.២.១. រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ...................................................................................២១
១.៣.២.២. រដ្ឋបាលឃុំ សង្កាត់.....................................................................................................២២
១.៣.២.៣. ទំហំនៃវិមជ្ឈការដែលរៀបចំនៅកម្ពុជា....................................................................................២២
១.៣.៣. ប្រព័ន្ធវិសហមជ្ឈការ ......................................................................................................២៣
១.៣.៣.១. និយមន័យ..............................................................................................................២៣
១.៣.៣.២. ចរិតលក្ខណៈ...........................................................................................................២៤
១.៣.៣.៣. វិធីសាស្ត្រក្នុងការរំលែកអំណាចកណ្ដាលបែង...............................................................................២៤
១.៣.៣.៤. អំណាចឋានានុក្រម......................................................................................................២៦
១.៣.៣.៥. គុណសម្បត្តិ និងគុណវិបត្តិ ..............................................................................................២៧
**ជំពូកទី២. ការគ្រប់គ្រងរដ្ឋបាលឃុំសាន់គ**
**២.១. ប្រវត្តិ និងស្ថានភាពទូទៅ**.............................................................................................២៩
២.១.១. ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ....................................................................................២៩
២.១.២. ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច .......................................................................................៣០
២.១.៣. ការគ្រប់គ្រងធនធានធម្មជាតិបរិស្ថាន និងការប្រែប្រួលអាកាសធាតុ..........................................................៣៤
២.១.៤. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ.......................................................៣៤
**២.២. ការរៀបចំនិងការប្រព្រឹត្តនៃរដ្ឋបាលឃុំសាន់គ**.........................................................................៣៦
២.២.១. រចនាសម្ព័ន្ធ ..............................................................................................................៣៦
២.២.២. ការបង្កើតគណៈកម្មាធិការឃុំ .............................................................................................៣៨
២.២.៣. តួនាទី និងភារកិច្ច .......................................................................................................៤៦
**២.៣. ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ឃុំសាន់គ**..................................................................................៤៨
២.៣.១. ការរៀបចំ និងអនុម័តថវិកាឃុំ.............................................................................................៤៨
២.៣.២. កំណត់ហេតុប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាឃុំសាន់គ.........................................................................៤៩
២.៣.៣. ចំណូល និងចំណាយថវិកាឃុំសាន់គ.......................................................................................៥២
២.៣.៣.១. ប្រាក់ឧបត្ថម្ភប្រចាំខែរបស់មន្ត្រីរាជការ និងមន្ត្រីភូមិ ....................................................................៥៤
២.៣.៣.២. ផ្នែកមូលនិធិឃុំ ........................................................................................................៥៤

២.៣.៣.៣. ប្រព័ន្ធទូទាត់ គណនេយ្យ ..................................................... ៥៤
**ជំពូកទី៣. សមិទ្ធផល បញ្ហាប្រឈម និងដំណោះស្រាយ**
**៣.១. សមិទ្ធផល** ..................................................... ៥៦
៣.១.១. សមិទ្ធផលក្នុងឆ្នាំ២០២២ ..................................................... ៥៦
៣.១.២. សមិទ្ធផលក្នុងឆ្នាំ២០២៣ ..................................................... ៦០
៣.១.៣. សមិទ្ធផលក្នុងឆ្នាំ២០២៤ ..................................................... ៦៥
**៣.២. បញ្ហាប្រឈម** ..................................................... ៧០
៣.២.១. ផ្នែកអប់រំ ..................................................... ៧០
៣.២.២. ផ្នែកសុខាភិបាល ..................................................... ៧០
៣.២.៣. ផ្នែកយេនឌ័រ ..................................................... ៧១
៣.២.៤. ធនធានធម្មជាតិបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ..................................................... ៧២
៣.២.៥. គ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ..................................................... ៧៣
**៣.៣. ដំណោះស្រាយ** ..................................................... ៧៤
៣.៣.១. ផ្នែកអប់រំ ..................................................... ៧៤
៣.៣.២. ផ្នែកសុខាភិបាល ..................................................... ៧៤
៣.៣.៣. ផ្នែកយេនឌ័រ ..................................................... ៧៥
៣.៣.៤. ធនធានធម្មជាតិបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ..................................................... ៧៥
៣.៣.៥. គ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ..................................................... ៧៧
សេចក្តីសន្និដ្ឋាន ..................................................... ៧៨
**អនុសាសន៍**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំនៃការសិក្សាស្រាវជ្រាវ

យើងបានដឹងរួចមកហើយថា ប្រទេសកម្ពុជាបានរងនូវឥទ្ធិពលនៃសង្គ្រាមស៊ីវិលរាំរ៉ៃអស់រយៈពេលជាងពីរសតវត្សកន្លងមកហើយ ក្រោយបញ្ចប់សង្គ្រាមនេះប្រទេសកម្ពុជាបានកម្រើកឡើងវិញបន្តិចម្តងៗ ដោយមានការបោះឆ្នោតជ្រើសរើសតាំងតំណាងរាស្ត្រនាឆ្នាំ១៩៩៣។ ចាប់តាំពីពេលនោះមកសង្កេតឃើញថា ប្រទេសកម្ពុជាមានការអភិវឌ្ឍកើនឡើងជាលំដាប់។ ជាមួយគ្នានេះផងដែរ ស្ថានភាពនយោបាយរបស់ប្រទេស ក៏កាន់តែមានស្ថិរភាព ហើយរចនាសម្ព័ន្ធនៃលទ្ធិប្រជាធិបតេយ្យក៏ត្រូវបានពង្រីក (ដោយមានការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ចាប់ពីឆ្នាំ២០០២មក) សេដ្ឋកិច្ច ក៏កាន់តែមានការរីកចម្រើនយ៉ាងលឿនគួរឱ្យកត់សម្គាល់ ហើយលក្ខខណ្ឌនៃការរស់នៅរបស់ប្រជាពលរដ្ឋកាន់តែមានភាពប្រសើរឡើង។ ប៉ុន្តែអ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺចាប់តាំងពីឆ្នាំ២០០៤ មករាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈរបស់ខ្លួន ដោយផ្តោតសំខាន់ទៅលើសេវាសាធារណៈ។

កំណែទម្រង់រដ្ឋបាលសាធារណៈតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ ជាតម្រូវការមួយដ៏សំខាន់ដើម្បីកសាងរដ្ឋបាលមួយដែលមាន ប្រសិទ្ធភាព តម្លាភាព និងមានភាពជិតស្និទ្ធជាមួយប្រជាពលរដ្ឋ។ ក្នុងនោះដែរ វាជាផ្នែកមួយនៃអភិបាលកិច្ចល្អដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល។ ការគ្រប់គ្រងរដ្ឋបាលសាធារណៈដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាសាធារណៈឱ្យជិតទៅនឹងប្រជាពលរដ្ឋ និងរហ័សទាន់ពេលវេលាក្នុងគោលបំណង ដើម្បីឱ្យសេវាសាធារណៈមួយគួរឱ្យជឿទុកចិត្តបាន មាននីតិវិធីសាមញ្ញ មានតម្លាភាព និងស្របទៅតាមតម្រូវការជាក់ស្តែង។ ការផ្តល់សេវានេះផងដែរ រាជរដ្ឋាភិបាលបានបែងចែកការគ្រប់គ្រង និងការផ្តល់សេវាទៅតាមលំដាប់ថ្នាក់ គឺថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ជាក់ស្តែង រាជរដ្ឋាភិបាលបានបង្កើតឱ្យមានការគ្រប់គ្រងរដ្ឋបាលថ្នាក់ឃុំ សង្កាត់ នៅក្នុងគោលបំណងសម្របសម្រួលរចនាសម្ព័ន្ធ និងមុខងាររដ្ឋបាលថ្នាក់ស្រុកឱ្យក្លាយជារដ្ឋបាលជួរមុខដែលមានប្រព័ន្ធគ្រប់គ្រងស្របតាមគោលការណ៍រដ្ឋបាលឯកភាពសំដៅលើការលើកកម្ពស់សេដ្ឋកិច្ច និងផ្តល់សេវាសាធារណៈឱ្យប្រជាពលរដ្ឋនៅមូលដ្ឋានក៏ដូចជានៅក្នុងឃុំ សង្កាត់នីមួយៗ នៅតាមដែនសមត្ថកិច្ចរបស់រដ្ឋបាលឃុំឱ្យកាន់តែមានប្រសិទ្ធភាព គណនេយ្យភាព បរិយាបន្ន អភិបាលកិច្ចល្អ សមធម៌ ដល់ការគ្រប់គ្រងរដ្ឋបាលការិយាល័យអង្គភាពជំនាញ និងធ្វើឱ្យមានចីរភាពក្នុងសង្គម។ មិនតែប៉ុណ្ណោះ អភិបាលនៃគណៈអភិបាលស្រុក ត្រូវតែមានភារកិច្ចយ៉ាងសំខាន់ក្នុងការបែងចែក កំណត់ផែនការ ឬស្វែងរកវិធីសាស្ត្រយ៉ាងណាឱ្យមានការអភិវឌ្ឍស្របតាមចក្ខុវិស័យ និងមានគោលការណ៍ប្រកប ដោយប្រជាធិបតេយ្យដែលរាជរដ្ឋាភិបាលបានកំណត់ជូន។

ហើយបច្ចុប្បន្ននេះផងដែរ ព្រះរាជាណាចក្រកម្ពុជា មានរាជធានី០១ ខេត្ត២៥ ក្រុង៣២ ស្រុក១៦៣ ខណ្ឌ១៤ ឃុំ១,៣៨៨និងសង្កាត់ ២៦៤។ ខេត្តដែលទើបនឹងបង្កើតថ្មី គឺខេត្តត្បូងឃ្មុំ ដែលជាតំបន់បំបែកចេញពីខេត្តកំពង់ចាម។ ភូមិ គឺជានីតិបុគ្គល ភូមិមិនមែន ជាផ្នែកមួយនៃរដ្ឋបាលដែនដីរបស់ប្រទេសកម្ពុជាទេ។ បច្ចុប្បន្ននេះ ចំនួនសរុបដែលត្រូវបានកត់ត្រា ដោយក្រសួងមហាផ្ទៃ មាន ១៤,៥៧០ភូមិ។ ការរៀបចំ និងការប្រព្រឹត្តិទៅនៃរដ្ឋបាល

ដែនដី ត្រូវកំណត់នៅក្នុង ច្បាប់រៀបចំអង្គការ។ រដ្ឋបាលឃុំ/សង្កាត់ ត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ /សង្កាត់។

## ២. ចំណោទបញ្ហា

ក្រុមនាងខ្ញុំ និងខ្ញុំបាទទាំងពីររូបសង្កេតឃើញថា ការគ្រប់គ្រងរដ្ឋបាលឃុំសាន់គ ចាប់ពីអាណត្តិទី៥ (២០២២-២០២៤) គឺនៅមិនទាន់គ្រប់ជ្រុងជ្រោយក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅឡើយ។ ហេតុដូច្នេះហើយ ដើម្បីឱ្យយល់ដឹងបានកាន់តែច្បាស់លាស់ពីរបៀបរបបនៃការគ្រប់គ្រងរដ្ឋបាលឃុំសាន់គ ទើបក្រុមខ្ញុំទាំងពីររូបបានជ្រើសរើសយក ប្រធានបទសារណានេះមកធ្វើការសិក្សាស្រាវជ្រាវ និងបានចោទជាចំណោទបញ្ហាដូចខាងក្រោម៖

១. តើការគ្រប់គ្រងរដ្ឋបាលឃុំសាន់គមានលក្ខណៈដូចម្តេច?

២. តើរដ្ឋបាលឃុំសាន់គសម្រេចបាននូវសមិទ្ធផលអ្វីខ្លះ នៅក្នុងអាណត្តិទី៥(២០២២-២០២៤)?

៣. តើការគ្រប់គ្រងរដ្ឋបាលឃុំសាន់គជួបប្រទះនូវបញ្ហាប្រឈមយ៉ាងដូចម្តេចខ្លះ? ហើយត្រូវមានដំណោះស្រាយយ៉ាងដូចម្តេចទៅលើបញ្ហាទាំងនោះ?

## ៣. គោលបំណង

គោលបំណងនៃការសិក្សាលើប្រធានបទនេះ ដើម្បីរួមចំណែក ធ្វើឱ្យមានការគ្រប់គ្រងរដ្ឋបាលក្នុងឃុំសាន់គ ស្រុកកំពង់ស្វាយ (ខេត្តកំពង់ធំ) ទទួលលទ្ធផលប្រសើរ ជាពិសេសជម្រុញឱ្យមានការរីកចម្រើនក្នុងឃុំក៏ដូចជាតំបន់ក្នុងព្រំដែនលើវិស័យគ្រប់គ្រង ដើម្បីបម្រើ និងឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋឃុំសាន់គតាមស្ថានភាពជាក់ស្តែង។ គោលបំណងទាំងនោះ រួមមាន៖

- ដើម្បីសិក្សាស្រាវជ្រាវទៅលើប្រធានបទសារណាឱ្យច្បាស់លាស់ពីតថភាពនៃការគ្រប់គ្រងរដ្ឋបាលឃុំសាន់គ ស្រុកកំពង់ស្វាយ (ខេត្តកំពង់ធំ)
- ដើម្បីស្វែងយល់ពីការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋរស់នៅក្នុងឃុំសាន់គ ស្រុកកំពង់ស្វាយ (ខេត្តកំពង់ធំ)
- ដើម្បីដឹងពីរបៀបរបបក្នុងការរៀបចំផែនការការងារ និងទទួលបានលទ្ធផលសមស្របសម្រាប់អភិវឌ្ឍន៍ឃុំសាន់គ ស្រុកកំពង់ស្វាយ (ខេត្តកំពង់ធំ)
- ដើម្បីស្វែងយល់ពីដំណើរការអភិវឌ្ឍរដ្ឋបាលឃុំសាន់គ ស្រុកកំពង់ស្វាយ (ខេត្តកំពង់ធំ)
- ដើម្បីស្វែងយល់ពីផលវិបាក និងផ្តល់ជាមតិយោបល់ក្នុងការដោះស្រាយបញ្ហាលើបញ្ហាទាំងនោះ។

## ៤. ដែនកំណត់និងវិសាលភាព

ដែនកំណត់និងវិសាលភាពនៃការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី «**ការគ្រប់គ្រងរដ្ឋបាលឃុំសាន់គ ស្រុកកំពង់ស្វាយ (ខេត្តកំពង់ធំ) អាណត្តិទី៥(២០២២-២០២៤)**» បានផ្តោតសំខាន់ និងគ្របដណ្តប់លើសកម្មភាពរបស់រដ្ឋបាលឃុំសាន់គ ស្រុកកំពង់ស្វាយ (ខេត្តកំពង់ធំ) ព្រមទាំងធ្វើការស្រាវជ្រាវឱ្យបានច្បាស់លាស់ពីការគ្រប់គ្រង បញ្ហាប្រឈម ព្រមទាំងការស្វែងរកដំណោះស្រាយទៅតាមការងារនីមួយៗរបស់ឃុំ។ ម៉្យាងទៀត នាងខ្ញុំ និងខ្ញុំបាទបានចុះសម្ភាសន៍ និងស្រាវជ្រាវឯកសារផ្ទាល់

នៅសាលាឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ចាប់ពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៤ រហូត ដល់ថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០២៣។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី «**ការគ្រប់គ្រងរដ្ឋបាលឃុំសាន់គ ស្រុកកំពង់ស្វាយ (ខេត្តកំពង់ធំ) អាណត្តិទី៥ (២០២២-២០២៤)**» គឺធ្វើឡើងដោយការប្រើប្រាស់ ទិន្នន័យពីរប្រភេទដូចខាងក្រោម ៖

- **ទិន្នន័យចម្បង៖** ការចុះប្រមូលឯកសារផ្ទាល់ពីសាលាឃុំសាន់គ ព្រមទាំងធ្វើការសម្ភាសន៍ជាមួយក្រុមប្រឹក្សា និងអាជ្ញាធរដែលបម្រើការងារនៅក្នុងឃុំ ការណែនាំពីសាស្ត្រាចារ្យ ដឹកនាំការសរសេរសារណា។
- **ទិន្នន័យបន្ទាប់បន្សំ៖** ឯកសារដែលមានស្រាប់ដូចជា ច្បាប់ លិខិតបទដ្ឋានគតិយុត្តិ ឯកសារដែលបានសិក្សាកន្លងមក ឯកសារជាសៀវភៅក្នុងបណ្ណាល័យ Website របស់ក្រសួងមហាផ្ទៃ អ៊ិនធឺណិត និងGoogle ជាដើម។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មិនត្រឹមតែមានសារៈសំខាន់សម្រាប់និស្សិត សាមណនិស្សិតនៅក្នុងការស្វែងយល់ពីការគ្រប់គ្រងរដ្ឋបាលឃុំប៉ុណ្ណោះទេ ថែមទាំងទុកជាជំនួយដល់សង្គម និងបុគ្គលផងដែរ ព្រោះអត្ថបទសារណានេះនឹងជួយជាផ្លូវមួយក្នុងការផ្តល់ចំណេះដឹងដូចជា៖

- យល់ដឹងពីការកែប្រែចំណុចខ្វះខាតលើការគ្រប់គ្រងឃុំសាន់គ ព្រមទាំងបន្តការអភិវឌ្ឍឃុំឱ្យស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ផ្តល់ជាចំណេះដឹងក្នុងការបង្កើននូវពុទ្ធិផ្នែកការសិក្សាស្រាវជ្រាវ និងការប្រមូលទិន្នន័យពាក់ព័ន្ធទៅនឹងប្រធានបទក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ហើយថែមទាំងផ្តល់ឱកាសដល់ក្រុមយើងខ្ញុំ បានចែករំលែកជាចំណេះដឹងដោយផ្តល់ជាឯកសារតម្កល់ទុកក្នុងបណ្ណាល័យដើម្បី ឱ្យនិស្សិត សាមណនិស្សិតជំនាន់ក្រោយបានសិក្សាបន្តទៀត
- ចំពោះសង្គមជាតិ ក៏ដូចគ្នា ការសរសេរសារណានេះ បង្ហាញទិន្នន័យជាក់ស្តែងពិតប្រាកដដល់បណ្តា ក្រសួង ស្ថាប័នពាក់ព័ន្ធនានា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវអត្ថបទសារណានេះ ខ្ញុំទាំងពីរបានធ្វើការបែងចែកចេញជាបីជំពូកគឺ៖

**ជំពូកទី១៖ សញ្ញាណទូទៅនៃការគ្រប់គ្រងរដ្ឋបាលឃុំ**

**ជំពូកទី២៖ ការគ្រប់គ្រងរដ្ឋបាលឃុំសាន់គ ស្រុកកំពង់ស្វាយ (ខេត្តកំពង់ធំ)**

**ជំពូកទី៣៖ សមិទ្ធផល បញ្ហាប្រឈម និងដំណោះស្រាយ**

# ជំពូកទី១

# សញ្ញាណទូទៅនៃ

# ការគ្រប់គ្រងរដ្ឋបាល

# ជំពូកទី១

# សញ្ញាណទូទៅនៃការគ្រប់គ្រងរដ្ឋបាលឃុំ

## ១.១. លក្ខណៈទូទៅនៃរដ្ឋបាល

### ១.១.១. និយមន័យ

ដំបូង តាមន័យទូលំទូលាយពាក្យថា រដ្ឋបាល ( administration ) ជួនកាល សំដៅលើ ″ សកម្មភាពគ្រប់គ្រង″ ជួនកាលលើ ″ អង្គការ″ ដែលគ្រប់គ្រង។ ន័យទាំងពីរនេះ អាចប្រើបានទាំងខាងវិស័យឯកជន ទាំងខាងវិស័យសាធារណៈ។[1]

**ន័យទី១៖ ន័យសកម្មភាព**

- កិច្ចការរដ្ឋបាលរបស់ក្រុមហ៊ុនកាត់ដេរ (វិស័យឯកជន )
- កិច្ចការរដ្ឋបាលរបស់ក្រសួងទេសចរណ៍ (វិស័យសាធារណៈ )។

**ន័យទី២៖ ន័យអង្គការះ**

- ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនអាហារណែនិហារណៃ ( វិស័យឯកជន )
- ក្រសួងទេសចរណ៍ (វិស័យសាធារណៈ)។

បើមើលតាមន័យទូលំទូលាយនេះ សកម្មភាពរដ្ឋបាលរបស់ពួកឯកជនក៏មាន របស់រាជការក៏មាន ដែលជាហេតុនាំឱ្យនឹកគិតថា យើងមិនបាច់ទៅបង្កើតវិធានអ្វីឱ្យខុសប្លែកពីគ្នាទេ។ ការគ្រប់គ្រងនៅតែជាការគ្រប់គ្រងដដែល។ គំនិតហ្នឹងហើយដែលពួកនិយមខាងប្រព័ន្ធច្បាប់ ខូមិនឡូ(Common law) គេយល់ថាមិនបាច់មាននីតិរដ្ឋបាលមួយដោយឡែកសំរាប់រាជការទេ។

ចំណែកឯពួកនិយមប្រព័ន្ធច្បាប់រ៉ូម៉ាំងអាឡឺម៉ង់ដឺវិញ ដូចជាប្រទេសបារាំងជាដើម គេយល់ថា រដ្ឋ ឬសមូហភាពសាធារណៈបម្រើប្រយោជន៍សាធារណៈ គឺមានគោលដៅមិនរកផលប្រយោជន៍ចំណេញផ្ទាល់ខ្លួនដូចបុគ្គលឯកជនឡើយ ដូច្នេះគេត្រូវមានវិធានគ្រប់គ្រង រដ្ឋបាលផ្សេងពីឯកជនសំរាប់រដ្ឋ ឬសមូហភាពសាធារណៈ។ នៅប្រទេសបារាំង គេឱ្យនិយមន័យចង្អៀតលើពាក្យថារដ្ឋបាល ដែលគេគិតសំដៅយកតែរដ្ឋបាលសាធារណៈ។រដ្ឋបាលសាធារណៈពាក្យនេះ គេអាចប្រើខ្លីកាត់ថា រដ្ឋការ ដែលប្រទេសយើងហៅថា រាជការ។ គេមានរបៀបសរសេរកាត់ខ្លី ដោយសរសេរ A ធំ ក្នុងពាក្យ Administration ដើម្បីជំនួសពាក្យវែង administration publique។ ក្នុងភាសានិយាយ កាលណាបារាំងថា administration គឺគេនិយាយពីរដ្ឋការរបស់គេហើយ មិនមែនរឿងឯកជនទេ។ ខ្មែរយើងមានពាក្យរាជការ (ឬរដ្ឋការ) ដែលយើងប្រើបាន ហើយមានន័យច្បាស់លាស់មិនច្រឡំនឹងរដ្ឋបាលឯកជន។ [2]

អាស្រ័យនឹងបរិបទ ជួនកាលយើងអាចនិយាយត្រឹមពាក្យ ″រដ្ឋបាល″ ក៏យើងអាចយល់ថាជា ″រដ្ឋបាលសាធារណៈ″ បានដែរ ។

---

[1] បណ្ឌិត សាយ បូរី, *នីតិរដ្ឋបាលទូទៅ* (២០០៦), ទំព័រ ១០។

[2] បណ្ឌិត សាយ បូរី, *នីតិរដ្ឋបាលទូទៅ* (២០០៦), ទំព័រ ១១។

### ១.១.២. គោលដៅរបស់រដ្ឋបាល

រាជការមានគោលដៅខុសពីឯកជន ត្រង់ការគិតផលប្រយោជន៍ទូទៅរបស់សង្គមជាតិទាំងមូលដែលគេហៅថា ផលប្រយោជន៍សាធារណៈ។[3]

ពួកឯកជន គេគិតផលប្រយោជន៍របស់ខ្លួនគេជាមុនសិន ដូចជាការខំរកស៊ីឱ្យបានចំណេញ មានលុយកាក់ច្រើនផ្ទាល់ខ្លួន មានមុខមានមាត់ក្នុងសង្គម ឬជួនកាលខំបម្រើតែឧត្ដមគតិរបស់ខ្លួនម្នាក់ឯងផ្ទាល់។ ផលប្រយោជន៍ឯកជនខ្លះ អាចមានឥទ្ធិពលដល់ផលប្រយោជន៍សាធារណៈ ទាំងឥទ្ធិពលល្អ ទាំងឥទ្ធិពលអាក្រក់។

ឥទ្ធិពលល្អ គឺស្របនឹងផលប្រយោជន៍សាធារណៈ។ ឧទាហរណ៍៖ ក្រុមហ៊ុនឯកជន មួយរកស៊ីធ្វើសេវាកម្មដឹកជញ្ជូនសាធារណជន ក្នុងទីក្រុងអាចមានផលល្អដល់ផលប្រយោជន៍សាធារណៈ ត្រង់បានសម្រួលការដឹកជញ្ជូនអ្នកដំណើរ និងអ្នកធ្វើការរកស៊ីក្នុងទីក្រុងជាសាធារណៈទូទៅ។

ឥទ្ធិពលអាក្រក់ គឺមិនស្របនឹងផលប្រយោជន៍សាធារណៈ។ ឧទាហរណ៍: ក្រុមហ៊ុនឯកជនមួយរកស៊ីកាប់ព្រៃឈើ ចង់បានចំណេញច្រើនផ្ទាល់ខ្លួន ក៏ទៅទាក់ទងសូកប៉ាន់មន្ត្រីរាជការ កាប់ព្រៃឈើខុសច្បាប់បន្ថែមលើច្បាប់ដែលខ្លួនមាន។ ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ក្រុមហ៊ុនឯកជននេះ បានបង្កឱ្យមានអំពើពុករលួយ និងមានមហន្តរាយដល់ព្រៃឈើដែលជា អាយុជីវិតនៃប្រទេសជាតិទាំងមូល គឺបណ្តាលឱ្យខូចផលប្រយោជន៍សាធារណៈ។ ផលប្រយោជន៍ទូទៅ ជាការធ្វើឱ្យបានសំរេចនូវអ្វីៗដែលជាការចាំបាច់របស់មនុស្ស រស់នៅរួមគ្នាហើយផលសម្រេចនេះ ទាក់ទងដល់ផលប្រយោជន៍នៃជនម្នាក់ៗ។ ការកសាងដូចជា ការធ្វើផ្លូវថ្នល់ ស្ពាន ជាការធ្វើឡើងសម្រាប់ផលប្រយោជន៍ទូទៅ សម្រាប់ជនទាំងអស់ដែលរស់នៅ ឬមកនៅស្នាក់អាស្រ័យក្នុងប្រទេស។ ជនគ្រប់រូបអាចថ្ងៃណាមួយ ត្រូវការប្រើប្រាស់ផ្លូវថ្នល់ ស្ពាន នេះក្នុងផលប្រយោជន៍ផ្ទាល់ខ្លួនរបស់គេម្នាក់។[4]

រាជការខំស្វែងរកនូវការបម្រើផលប្រយោជន៍ទូទៅឱ្យបានសម្រេច មុនអ្វីៗទាំងអស់។ និយាយនេះ មិនមែនបានន័យថា រាជការមិនគិតគូររឿងគ្រប់គ្រងឱ្យបានត្រឹមត្រូវ បណ្តាលឱ្យមានការខ្ជះខ្ជាយនោះទេ។ ផ្ទុយទៅវិញ រាជការត្រូវខំប្រឹងប្រែង ធ្វើការប្រុងប្រយ័ត្នដើម្បី ការគ្រប់គ្រងឱ្យបានល្អត្រឹមត្រូវមិនខ្ជះខ្ជាយ មិនបំផ្លាញទ្រព្យសម្បត្តិសាធារណៈ មានទ្រព្យ សម្បត្តិរដ្ឋជាដើម។ ប៉ុន្តែរឿងខាតចំណេញ ខាងផ្លូវហិរញ្ញវត្ថុពុំត្រូវចាត់ទុកជាគោលដៅធំបំផុតរបស់រាជការទេ។ ទោះបីខាតក៏រាជការត្រូវតែធ្វើ បើប្រសិនណាផលប្រយោជន៍ទូទៅតម្រូវ ដូចជាការការពារជាតិ ការការពារសន្តិសុខរបៀបរៀបរយសាធារណៈ ការបម្រើខាង វិស័យសុខាភិបាលសាធារណៈជាដើម។ ល។ សព្វថ្ងៃនេះ នៅប្រទេសបារាំងគេកំពុងធ្វើ ការវិវត្តន៍ទៅរកបច្ចេកទេសទំនើបនៃការគ្រប់គ្រងតាមបែបដូចខាងពួកឯកជនដែរ ក្នុងការគ្រប់គ្រងខាងផ្នែកសេដ្ឋកិច្ចរបស់ស្ថាប័នរដ្ឋនានា ដើម្បីកាត់បន្ថយនូវចំណាយឥតប្រយោជន៍។ បារាំងហៅថា បច្ចេកទេសនៃការគ្រប់គ្រងទំនើប (technique de management )។

[3] បណ្ឌិត សាយ បូរី, *នីតិរដ្ឋបាលទូទៅ* (២០០៦), ទំព័រ ១៣។

[4] បណ្ឌិត សាយ បូរី, *នីតិរដ្ឋបាលទូទៅ* (២០០៦), ទំព័រ ១៣។

### ១.១.៣. មធ្យោបាយរបស់រដ្ឋបាល

ដោយសារមានបុព្វសិទ្ធិនៃអំណាចសាធារណៈ រាជការមានអំណាចប្រើកម្លាំងសាធារណៈ ដូចជាកម្លាំងប៉ូលីស និងទាហានជាដើម។ រួមសេចក្ដីមក ជាគោលការណ៍ គ្មានសមភាពគតិយុត្តទេ ក្នុងការទំនាក់ទំនងរវាងរាជការ និងរាស្ត្រ។ ហើយបុព្វសិទ្ធិនៃអំណាចសាធារណៈ ជាមធ្យោបាយសំខាន់មួយរបស់រាជការសម្រាប់បម្រើគោលដៅធំរបស់ខ្លួន គឺផលប្រយោជន៍ទូទៅ។[5]

ការបម្រើផលប្រយោជន៍ទូទៅ ទាមទារឱ្យមានមធ្យោបាយសមស្របផ្ដល់ជូនរាជការ។ ផលប្រយោជន៍ទូទៅ ត្រូវតែមានឧត្ដមភាពលើផលប្រយោជន៍ឯកជន ដូច្នេះមធ្យោបាយរបស់រាជការត្រូវតែធំជាងមធ្យោបាយរបស់ឯកជន។ ពាក្យថា "ធំ" នេះមិនសំដៅ លើទំហំរូបរាងសម្ភារៈ ឬចំនួនបរិមាណនោះទេ គឺសំដៅលើសិទ្ធិអំណាច។

ក្នុងការទំនាក់ទំនងរវាងឯកជន និងឯកជនវិធានចំបងគឺឈរលើគោលការណ៍នៃ សមភាពគតិយុត្ត។ ក្នុងកិច្ចសន្យាអ្វីមួយ ឯកជន និងឯកជនត្រូវមានការព្រមព្រៀងគ្នា ដោយស្មោះស្ម័គ្រដាក់លក្ខខ័ណ្ឌសមស្របឱ្យបានស្មើភាពគ្នាទៅវិញទៅមក ដោយគ្មានអ្នកណាមានប្រៀបជាងអ្នកណាឡើយ។ សិទ្ធិក៏ស្មើគ្នា កាតព្វកិច្ចក៏ស្មើគ្នា។ ភាពស្មើគ្នាខាងផ្លូវច្បាប់នេះហើយ ហៅថាគេសមភាពគតិយុត្ត។ ក្នុងការទំនាក់ទំនង រវាងរាជការ និងឯកជនរាជការមានសិទ្ធិអំណាចធំជាងឯកជន ដោយហេតុថា រាជការជាអ្នកបម្រើ និងការពារផលប្រយោជន៍ទូទៅដូចបាននិយាយរួចមកហើយ។ បើសិនជាឱ្យរាជការ និងឯកជនមានសមភាពគតិយុត្ត រាជការនឹងជួបការលំបាកក្នុងការធ្វើឱ្យសម្រេចនូវគោលដៅនៃផលប្រយោជន៍ទូទៅ ពីព្រោះផលប្រយោជន៍ឯកជនម្នាក់ៗមិនអាចស្របទាំងស្រុងគ្រប់កាលៈទេសៈ ទៅនឹងផលប្រយោជន៍ទូទៅរបស់សង្គមជាតិបានឡើយ ហើយផ្ទុយទៅវិញច្រើនតែប្រឆាំងគ្នានឹងផលប្រយោជន៍ទូទៅ។

សិទ្ធិអំណាចដ៏ធំនេះ គេហៅថាបុព្វសិទ្ធិនៃអំណាចសាធារណៈ។ បុព្វសិទ្ធិនេះ អនុញ្ញាតឱ្យរាជការមានប្រៀបជាងឯកជនជានិច្ចក្នុងការទំនាក់ទំនងសង្គម។ ប៉ុន្តែរាជការមិនអាចនឹងធ្វើអ្វីបានតាមទំនើងចិត្តក្រៅអំពីក្របខ័ណ្ឌច្បាប់បានឡើយ។ យើងនឹងសិក្សាបញ្ហានេះ នៅក្នុងភាគទី១។

ដោយសារមានបុព្វសិទ្ធិនៃអំណាចសាធារណៈ រាជការមានអំណាចប្រើកម្លាំងសាធារណៈដូចជាកម្លាំងប៉ូលីស និងទាហានជាដើម។ រួមសេចក្ដីមកជាគោលការណ៍ គ្មានសមភាពគតិយុត្តទេក្នុងការទំនាក់ទំនងរវាងរាជការ និងរាស្ត្រ។ ហើយបុព្វសិទ្ធិនៃអំណាចសាធារណៈ ជាមធ្យោបាយសំខាន់មួយរបស់រាជការសម្រាប់ប្រើគោលដៅធំរបស់ខ្លួន គឺផលប្រយោជន៍ទូទៅ។[6]

[5] បណ្ឌិត សាយ បូរី, *នីតិរដ្ឋបាលទូទៅ* (២០០៦), ទំព័រ ១៤។

[6] បណ្ឌិត សាយ បូរី, *នីតិរដ្ឋបាលទូទៅ* (២០០៦), ទំព័រ ១៥។

## ១.២. ប្រវត្តិនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា

តាមការសិក្សាស្រាវជ្រាវ ប្រទេសកម្ពុជាមានប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានជាយូរណាស់មកហើយ។ ប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននេះ មានការប្រែប្រួលពីរបបនយោបាយមួយទៅរបបនយោបាយមួយទៀត ផ្អែកទៅតាមស្ថានភាពនយោបាយ ប្រជាសាស្ត្រ ភូមិសាស្ត្រ សេដ្ឋកិច្ច និង សង្គមនៅក្នុងសម័យកាលនីមួយៗ។[7]

### ១.២.១. អភិបាលកិច្ចមូលដ្ឋាននៅកម្ពុជាមុនឆ្នាំ១៩០៨

មុនឆ្នាំ១៩០៨ កម្ពុជាត្រូវបានបែងចែកជាតំបន់គ្រប់គ្រងដោយស្តេចត្រាញ់ដែលជាអ្នកមានមុខមាត់មានកិត្តិយសនៅក្នុងព្រះរាជវាំង។ តំបន់ទាំងនេះ មានខេត្តចំណុះដែលគ្រប់គ្រងដោយ ចៅហ្វាយស្រុក ឬអភិបាលដែលត្រូវបានតែងតាំង។ ចៅហ្វាយស្រុកមានអ្នកនៅក្រោមបង្គាប់ដែលជាភ្នាក់ងារប្រតិបត្តិដូចជា អ្នកទាំងនេះស្នាក់នៅ និងធ្វើការជាមួយ ចៅហ្វាយស្រុក និងជាអ្នកពាំនាំនូវបទបញ្ជា ឬនាំយកនូវការបង្គាប់បញ្ជារបស់ចៅហ្វាយស្រុកទៅឱ្យមេស្រុក។ មេស្រុក ត្រូវបានចាត់ទុកជាអ្នកគ្រប់គ្រងភូមិ និងជាអ្នកតំណាងដែលត្រូវបានជ្រើសរើស ដោយអភិបាល ដើម្បីប្រមូលពន្ធ និងទទួលខុសត្រូវនៅតាមកន្លែងនីមួយៗនៅក្នុងស្រុក ឬខេត្តដែលខ្លួនគ្រប់គ្រង។ ការអនុវត្តការងាររបស់មេស្រុក ពុំមានវិធានរដ្ឋបាលកំណត់ច្បាស់លាស់ទេ។ មេស្រុក ភាគច្រើនមិនចេះអក្សរមិនមានឥទ្ធិពល និងគ្មានអំណាច ហើយការចូលបំពេញការងាររបស់អ្នកទាំងនោះ គឺតាមរយៈទំនាក់ទំនងជាមួយស្តេចត្រាញ់ ឬចៅហ្វាយស្រុក។ នៅពេលនោះ ភូមិមិនមានបុគ្គល ភាពគតិយុត្ត និងមិនមានទ្រព្យសម្បត្តិអ្វីទាំងអស់។ ភូមិ គឺជាតំបន់ដែលកើតឡើងពីការប្រមូលផ្តុំនូវតំបន់តូចៗដាក់បញ្ចូលគ្នា។ កិច្ចការរដ្ឋបាលសាធារណៈទាំងឡាយ គឺធ្វើផ្ទាល់ជាមួយប្រជាជននៅក្នុងភូមិហើយប្រជាពលរដ្ឋមិនមានតំណាងស្របច្បាប់ដើម្បីការពារផលប្រយោជន៍របស់ខ្លួនឡើយ។[8]

### ១.២.២. អភិបាលកិច្ចមូលដ្ឋាននៅកម្ពុជាចាប់ពីឆ្នាំ១៩០៨ ដល់ឆ្នាំ១៩៥៥

ការរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្មី បានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ១៩០៨ តាមរយៈ ការដាក់ឱ្យប្រើនូវក្រឹត្យច្បាប់ស្តីពីការរៀបចំរដ្ឋបាលឃុំ ដែលចូលជាធរមាននៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ ១៩០៨។ ក្រឹត្យនេះបានលុបចោលនូវរបៀបគ្រប់គ្រងដែនដីដោយស្តេចត្រាញ់ ហើយបានរៀបចំឱ្យមាន ប្រព័ន្ធគ្រប់គ្រងតាមឃុំវិញ។ ផ្អែកតាមស្មារតីក្រឹត្យនេះ ទឹកដីកម្ពុជាចែកចេញជាខេត្ត ស្រុក ឃុំ និង ភូមិ។ តាមរយៈការរៀបចំថ្មីនេះ អភិបាលដែលពីមុនហៅថា ចៅហ្វាយស្រុក បានក្លាយទៅជា "ចៅហ្វាយខេត្ត ហើយ មេស្រុក បានក្លាយជា «មេឃុំ»។ ទន្ទឹមនេះ ក្រឹត្យនេះបានតម្រូវឱ្យមេឃុំត្រូវ ធ្វើការបោះឆ្នោតជ្រើសរើសដោយផ្ទាល់ដោយប្រជាជននៅក្នុងឃុំ ដើម្បីបំពេញតួនាទីនៅក្នុងឃុំតាមរយៈមុខងារ និងធនធានដែលផ្តល់ឱ្យដោយក្រឹត្យនេះ។ គួរកត់សម្គាល់ថា មុនឆ្នាំ ១៩០៨ ឃុំពុំទាន់មាននៅឡើយទេ គឺមានតែថ្នាក់ខេត្ត ស្រុក និងភូមិប៉ុណ្ណោះ។

ក្រឹត្យច្បាប់គ្រប់គ្រងឃុំឆ្នាំ១៩០៨ មានភាពខ្វះចន្លោះជាច្រើននៅពេលអនុវត្តជាក់ស្តែង ជាពិសេសការរៀបចំប្រព័ន្ធគ្រប់គ្រងនៅក្នុងក្រឹត្យនេះ មិនអាចធ្វើឱ្យក្រុមប្រឹក្សាឃុំបំពេញតួនាទីប្រកបដោយលទ្ធផលបានឡើយ ដោយសារចំនួនដ៏ច្រើនលើសលប់នៃក្រុមប្រឹក្សាឃុំ។ នៅក្នុងឃុំខ្លះ ចំនួនក្រុមប្រឹក្សាជាប់ឆ្នោតបានកើន

---

[7] ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា* (២០១៨), ទំព័រ ៤។

[8] ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា* (២០១៨), ទំព័រ ៤។

ដល់១៥០រូប។ ម្យ៉ាងទៀត ការការពារផលប្រយោជន៍សមូហភាព ឬការអភិវឌ្ឍនៅមូលដ្ឋានមិនអាចធ្វើទៅបានប្រសើរឡើយ ដោយសារហិរញ្ញវត្ថុឃុំ មិនមានគ្រប់គ្រាន់។

នៅក្នុងឆ្នាំ១៩១៩ ក្រឹត្យច្បាប់គ្រប់គ្រងឃុំឆ្នាំ១៩០៨ ត្រូវបានកែសម្រួលឡើងវិញតាមរយៈ ការបំពេញបន្ថែម និងកែលម្អនូវភាពខ្វះចន្លោះដែលមានកន្លងមក។ ក្រឹត្យច្បាប់គ្រប់គ្រងឃុំកែសម្រួល នេះបានបញ្ជាក់កាន់តែច្បាស់អំពីមុខងារ និងសមត្ថកិច្ចរបស់ឃុំ ព្រមទាំងប្រព័ន្ធត្រួតពិនិត្យអំពីការ អនុវត្តមុខងារ និងសមត្ថកិច្ចរបស់ឃុំ ដោយចៅហ្វាយខេត្ត និងប្រជាជននៅក្នុងឃុំ។ ទន្ទឹមនេះ ក៏បង្កើតឱ្យមានថវិកាឃុំដែលតាមរយៈថវិកាឃុំនេះ មេឃុំអាចធ្វើការជ្រើសរើសបុគ្គលិកមកជួយធ្វើការ ឬបង្ហាត់បង្រៀនអំពីការងារ ដូចជាស្មៀន និងគ្រូបង្រៀនជាដើម ដើម្បីអាចធានាបាននូវដំណើរការ ជាប្រក្រតីនៃកិច្ចការរដ្ឋបាលរបស់ឃុំ។ ចាប់ពីពេលនោះមក មេឃុំមានតួនាទី ជាអ្នកធានាចាត់ចែង និងកាន់កាប់បញ្ជីរដ្ឋបាល និងថែរក្សាឯកសារ លិខិតស្នាមផ្សេងៗរបស់ឃុំ ដោយមានបុគ្គលិកជាប់ កិច្ចសន្យាជួយការងារទូទៅ។ មុខងារពាក់ព័ន្ធនឹងវិស័យអប់រំសាធារណៈត្រូវបានប្រគល់ឱ្យឃុំជា អ្នកគ្រប់គ្រង ដោយប្រើប្រាស់ថវិកា និងប្រភពហិញ្ញវត្ថុផ្សេងៗរបស់ឃុំ ដែលក្នុងនោះឃុំអាចធ្វើការតែងតាំងគ្រូបង្រៀន ក៏ដូចការសាងសង់សាលារៀនបន្ថែម។ ជារួម ការកែសម្រួលនេះបានធ្វើឱ្យប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលឃុំមានលក្ខណៈប្រសើរជាងមុន។[9]

ក្រឹត្យច្បាប់គ្រប់គ្រងឃុំឆ្នាំ១៩១៩នេះ បានកំណត់ច្បាស់អំពីកិច្ចការរបស់ឃុំ។ ក្រឹត្យនេះ បែងចែកជា០៨ជំពូក។ ក្នុងនោះ ០៣ជំពូកដំបូង បញ្ញត្តអំពីវិធានដែលពាក់ព័ន្ធនឹងដែនដី និងរដ្ឋបាល។ ជាពិសេស មាត្រា ១០ កំណត់អំពីការរៀបចំឱ្យមានក្រុមប្រឹក្សាឃុំដែលចំនួនក្រុមប្រឹក្សាឃុំតំណាង ឲ្យប្រជាជន ត្រូវសមាមាត្រទៅនឹងចំនួនភូមិ។ ចំនួនក្រុមប្រឹក្សាឃុំត្រូវបានកំណត់ចាប់ពី០៨រូប ទៅ ១៦រូប អាស្រ័យទៅតាមទំហំនៃឃុំ។ ចំនួនមេឃុំរង ឬជំទប់ ត្រូវបានបង្កើនសម្រាប់ឃុំដែលមាន ភូមិច្រើនជាង១៨ សំដៅជួយសម្រួលដល់ការបំពេញការងាររបស់មេឃុំ ដែលឃុំមួយចំនួនអាចមានជំទប់០២រូប ដើម្បីជួយមេឃុំ។ ទន្ទឹមនេះ ក៏បានរៀបចំឱ្យមានមេភូមិ ដើម្បីជួយដល់អាជ្ញាធរប្រតិបត្តិ ក៏ដូចការបង្កើននូវមធ្យោបាយក្នុងការធ្វើសកម្មភាព។ ជំពូកទី០៤ និងជំពូកទី០៥ ចែងអំពី តួនាទី ភារកិច្ច កាតព្វកិច្ច និងអត្ថប្រយោជន៍សម្រាប់អាជ្ញាធរឃុំ និងបញ្ជាក់អំពីកាតព្វកិច្ចរបស់ប្រជាជននៅក្នុងឃុំ និងផលប្រយោជន៍ដែលប្រជាជនអាចទទួលបាន។ មាត្រា៣២ បានបញ្ញត្តអំពី ការផ្តល់សិទ្ធិឱ្យឃុំធ្វើការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា។ ជំពូកទី០៦ ចែងពាក់ព័ន្ធទៅនឹងទ្រព្យ សម្បត្តិ ទាំងចលនវត្ថុ អចលនវត្ថុរបស់ឃុំ ព្រមទាំងការគ្រប់គ្រងប្រភពចំណូល។ ជំពូកទី០៧ និង ទី០៨ បញ្ញត្តអំពីការរៀបចំថវិកាឃុំដោយមានការចូលរួមពីឃុំ។ ទន្ទឹមនេះ វិធាននៃការរៀបចំ ការ ប្រើប្រាស់ និងការត្រួតពិនិត្យថវិកា គឺមានភាពងាយស្រួល សាមញ្ញ នៅក្នុងគោលគំនិត នៃវិមជ្ឈការ ដែលធ្វើឱ្យមានភាពងាយស្រួលដល់ប្រជាជន និងអាជ្ញាធរមានសមត្ថកិច្ច ក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ប្រតិបត្តិការថវិកាឃុំ។ ក្រឹត្យច្បាប់គ្រប់គ្រងឃុំកែសម្រួលនេះ ត្រូវបានចូលជាធរមាននៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩១៩ និងដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ១៩២០។

[9] ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា* (២០១៨), ទំព័រ ៥។

ម្យ៉ាងទៀត ដើរទន្ទឹមការរៀបចំប្រព័ន្ធយុត្តិធម៌ និងកំណែទម្រង់រដ្ឋបាលសាធារណៈដែលបានចូល ជាធរមាននៅឆ្នាំ១៩២៣ ក្រឹត្យច្បាប់គ្រប់គ្រងឃុំត្រូវបានកែសម្រួលឡើងវិញក្នុងឆ្នាំ១៩២៥ ហើយបានចូល ជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩២៦។ ក្រឹត្យច្បាប់ឆ្នាំ១៩២៦ បានបញ្ជាក់កាន់តែច្បាស់អំពីការជ្រើសរើសក្រុមប្រឹក្សាឃុំ មេឃុំ ការចូលកាន់តំណែង ប្រព័ន្ធគ្រប់គ្រង និងរបៀបរបបការងារនៅរដ្ឋបាលឃុំ ការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិឃុំ ព្រមទាំងការងារយុត្តាធិការរបស់ឃុំ។ នៅក្នុងសម័យនោះ ក្រុមប្រឹក្សាឃុំហៅថា ក្រុមជំនុំឃុំ។ មេឃុំ គឺជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមជំនុំឃុំ ដោយមានជំទប់ដែលជ្រើសរើសចេញពីក្រុមជំនុំឃុំ ជាអ្នកជួយការងារដល់មេឃុំ។ នៅពេលនោះ មេឃុំមានអាណត្តិការងារ០៤ឆ្នាំ។ ការរៀបចំថ្មីនេះមានលក្ខណៈ ស្រដៀងគ្នាទៅនឹងការរៀបចំប្រព័ន្ធគ្រប់គ្រងឃុំបច្ចុប្បន្នដែរ។[10]

ជារួម ការរៀបចំប្រព័ន្ធថ្មីនេះបានធ្វើឱ្យឃុំក្លាយជាថ្នាក់រដ្ឋបាលមួយជាក់លាក់ក្នុងប្រព័ន្ធរដ្ឋបាលនៅកម្ពុជា។ តាមរយៈក្រឹត្យច្បាប់ឆ្នាំ១៩២៦ បានផ្តល់នូវសិទ្ធិអំណាច និងធនធានកាន់តែច្រើនដល់ឃុំ ដើម្បីអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន ដើរទន្ទឹមនឹងការយកចិត្តទុកដាក់ពីរដ្ឋបាលកណ្តាល ក្នុងការពង្រឹង និងលើកស្ទួយការទទួលខុសត្រូវរបស់ឃុំផង។

ប៉ុន្តែ ចាប់ពីឆ្នាំ១៩៤៣មកប្រឈមមុខនឹងសង្គ្រាមឈ្លានពាន ការបោះឆ្នោតនៅឃុំត្រូវបាន ផ្អាកជាបន្តបន្ទាប់  និងត្រូវបានលុបចោលទាំងស្រុង ចាប់ពីឆ្នាំ១៩៤៨។ ពេលនោះ មេឃុំ និងជំទប់ឃុំ ត្រូវតែងតាំងដោយអភិបាលខេត្ត ដោយមានការយល់ព្រមពីរ៉េស៊ីដង់។

### ១.២.៣. អភិបាលកិច្ចមូលដ្ឋាននៅកម្ពុជាចាប់ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧៩

ក្រោយផ្អាកការបោះឆ្នោតនៅថ្នាក់ឃុំប្រមាណ១០ឆ្នាំ មានកិច្ចខិតខំប្រឹងប្រែងដើម្បីឱ្យមានការបោះឆ្នោតនៅថ្នាក់ឃុំឡើងវិញ។ នៅឆ្នាំ១៩៥៥ មានសារាចរណែនាំមួយដែលណែនាំឱ្យរៀបចំ ការបោះឆ្នោតមេឃុំឡើងវិញ ប៉ុន្តែនៅក្នុងការអនុវត្ត ពុំសូវទទួលបានលទ្ធផលឡើយ គឺមានលក្ខណៈគ្រាន់តែជាការបង្គ្រប់កិច្ចតាមច្បាប់ប៉ុណ្ណោះ ដោយសារតែប្រជាពលរដ្ឋពុំសូវសកម្មក្នុងការ ចូលរួម និងពុំមានជំនឿទៅលើសមត្ថភាពដឹកនាំរបស់មេឃុំ។

បន្ទាប់មក នៅក្នុងឆ្នាំ១៩៥៩ មានព្រះរាជក្រមមួយទៀតដែលតម្រូវឱ្យមានការបោះឆ្នោត ជ្រើសរើសក្រុមជំនុំឃុំ ហើយបានផ្តល់ឱ្យឃុំនូវឋានៈជានីតិបុគ្គល ដូចក្នុងឆ្នាំ១៩២៦។ ក្រុមជំនុំឃុំ មានអាណត្តិរយៈពេល០៤ឆ្នាំ។ ផ្អែកតាមក្រមនេះ មេឃុំ និងជំទប់ត្រូវជ្រើសរើសពីក្នុងក្រុមជំនុំឃុំ ដែលជាប់ឆ្នោត ដោយសំឡេងភាគច្រើន។ ចៅហ្វាយខេត្ត គឺជាអ្នកចេញដីកាខេត្តប្រកាសសុពលភាព ហើយតែងតាំងមេឃុំ និងក្រុមជំនុំឃុំ។ ទន្ទឹមនេះ ក្រឹត្យនេះក៏ផ្តល់អំណាចដល់ចៅហ្វាយខេត្តក្នុង ការប្រកាសមោឃភាពលិខិតបទដ្ឋានទាំងឡាយរបស់ឃុំ ដែលមានលក្ខណៈអនីត្យានុកូលភាព ផងដែរ។ ប៉ុន្តែមិនដល់រយៈពេលបីខែផង ព្រះរាជក្រមនេះត្រូវបានដាក់ព្យួរតាមរយៈការធ្វើប្រជាមតិ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៥៩ ហើយមេឃុំ ចៅសង្កាត់ និងជំទប់ ត្រូវតែងតាំងតាមរយៈដីកាខេត្ត តាមសំណើរបស់អភិបាលស្រុក។[11]

---

[10] ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា* (២០១៨), ទំព័រ ៦។

[11] ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា* (២០១៨),ទំព័រ ៧។

គួរកត់សម្គាល់ថា បន្ទាប់ពីការធ្វើសមាជជាតិលើកទី២០ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៦៥ ពាក្យ សង្កាត់ ត្រូវបានចាប់ផ្តើមប្រើប្រាស់សម្រាប់ឃុំនៅក្នុងទីក្រុង។ ក្នុងពេលជាមួយគ្នានោះ ពាក្យ ចៅហ្វាយខេត្ត ក្រុង ស្រុក ក៏ត្រូវផ្លាស់ប្តូរដោយប្រើជំនួសវិញនូវពាក្យ អភិបាល។

នៅក្នុងរបបសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥) ទោះបីរដ្ឋធម្មនុញ្ញនាសម័យនោះព្យាយាម ធ្វើវិមជ្ឈការ នៅគ្រប់ថ្នាក់រដ្ឋបាលនៅថ្នាក់ក្រោមជាតិក៏ដោយ ប៉ុន្តែដោយសារតែសង្គ្រាមស៊ីវិល ការបោះឆ្នោតគ្រប់ថ្នាក់នៅមូលដ្ឋានមិនអាចដំណើរការបានឡើយ ហើយមេឃុំនៅតែបន្តតែងតាំងដោយអភិបាលខេត្ត។

ដោយឡែក ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) រដ្ឋធម្មនុញ្ញនៃរបបនេះមានតែ២១មាត្រាប៉ុណ្ណោះ ដែលខ្លឹមសារភាគច្រើនផ្តោតទៅលើអំណាច "យោធា" និង "អង្គការ"។ មាត្រា៩ នៃរដ្ឋធម្មនុញ្ញនេះបានបញ្ញត្តអំពីរបបដឹកនាំ និងធ្វើការងារជា "របបសមូហភាពដឹកនាំ និងធ្វើការងារ"។ ប៉ុន្តែក្នុងស្ថានភាពជាក់ស្តែង របបនេះមិនបានអនុវត្តតាមរដ្ឋធម្មនុញ្ញ ឬច្បាប់អ្វីទាំងអស់។ ក្នុងរបបនេះ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលសេដ្ឋកិច្ច និងសង្គមត្រូវបានបំផ្លាញចោលទាំងស្រុង ហើយប្រជាពលរដ្ឋនៅទូទាំងប្រទេសត្រូវបានជម្លៀសទៅធ្វើស្រែចម្ការនៅតាមតំបន់ជនបទ និងរស់នៅប្រមូលផ្តុំរបៀបជា "សហករណ៍" ក្រោមការដឹកនាំ និងបញ្ជាផ្តាច់ការពី "អង្គការ"។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាបាត់បង់អាយុជីវិតអស់រាប់លាននាក់ ក្នុងរយៈពេលតែប្រមាណជាងបី ឆ្នាំប៉ុណ្ណោះ។ ទន្ទឹមនេះ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងប្រទេសត្រូវបានបំផ្លាញចោលទាំងស្រុង។[12]

### ១.២.៤. អភិបាលកិច្ចមូលដ្ឋាននៅកម្ពុជាចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣

បន្ទាប់ពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យនាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គមលើគ្រប់វិស័យ រួមទាំងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលផង ត្រូវបានស្តារ និងកសាងឡើងវិញពីលេខសូន្យ។

មកទល់ចុងឆ្នាំ១៩៧៩ មានក្រសួង ស្ថាប័នចំនួន១២ ត្រូវបានបង្កើតឡើង និងមានខេត្តចំនួន១៨ និងក្រុង០២ ត្រូវបានរៀបចំចំណុះក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា។

នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៨១ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជាបានធ្វើការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រដោយមានប្រជាជនចំនួន ៣.៤១៧.៣៣៩នាក់ (៩៧,៨២%) បានចេញទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចំនួន១១៧រូប ក្នុងចំណោមបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដោយមានប្រជាជនចំនួន ៣.៤១៧.៣៣៩នាក់ (៩៧,៨២%) បានចេញទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចំនួន១១៧រូប ក្នុងចំណោមបេក្ខជនឈរឈ្មោះបោះឆ្នោត១៤៨រូប។ ក្នុងចំណោមបេក្ខជនជាប់ឆ្នោតទាំង ១១៧រូប មានស្ត្រីចំនួន ២១រូប។ រដ្ឋសភាបានបើក សម័យប្រជុំលើកទី១ ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១

[12] ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា* (២០១៨), ទំព័រ ៨។

ដោយបានបោះឆ្នោតជ្រើសតាំង សម្តេច ជាស៊ីម ជាប្រធានរដ្ឋសភា។ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨១ រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចូលជាធរមាន។[13]

រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ បានកំណត់ដែនដីរដ្ឋបាលនៅកម្ពុជាដូចខាងក្រោម៖

- ដែនដីនៃប្រទេសកម្ពុជាចែកជាខេត្ត និងក្រុង
- ខេត្តចែកជា ស្រុក
- ស្រុកចែកជា ឃុំ
- ក្រុងចែកជា សង្កាត់។

ដែនដីរដ្ឋបាលនីមួយៗខាងលើ គ្រប់គ្រងដោយអង្គការរដ្ឋអំណាចដែលមានឈ្មោះថា "គណៈកម្មាធិការប្រជាជនបដិវត្តន៍មូលដ្ឋាន"។ សមាជិកគណៈកម្មាធិការប្រជាជនបដិវត្តន៍ឃុំ សង្កាត់ ត្រូវ ជ្រើសតាំងឡើងដោយប្រជាជននៅក្នុងឃុំ សង្កាត់សាមីតាមរយៈការបោះឆ្នោតជាសកល ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសសន្លឹកឆ្នោតជាសម្ងាត់។ តំណាងគណៈកម្មាធិការប្រជាជនបដិវត្តន៍ ឃុំ ជាអ្នកបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការប្រជាជនបដិវត្តន៍ស្រុក។ តំណាងគណៈកម្មាធិការប្រជាជនបដិវត្តន៍ស្រុក ជាអ្នកបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការប្រជាជន បដិវត្តន៍ខេត្ត។ ចំណែកតំណាងគណៈកម្មាធិការប្រជាជនបដិវត្តន៍សង្កាត់ ជាអ្នកបោះឆ្នោតជ្រើសរើស សមាជិកគណៈកម្មាធិការប្រជាជនបដិវត្តន៍ក្រុង។ គណៈកម្មាធិការប្រជាជនបដិវត្តន៍ខេត្ត ក្រុង មានអាណត្តិការងារ០៥ឆ្នាំ។ ចំណែកគណៈកម្មាធិការប្រជាជនបដិវត្តន៍ស្រុក សង្កាត់ ឃុំ មានអាណត្តិការងារ០៣ឆ្នាំ។

នៅដើមឆ្នាំ១៩៨១ សាធារណរដ្ឋប្រជាមានិតកម្ពុជាបានធ្វើការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការប្រជាជនបដិវត្តន៍ឃុំ សង្កាត់ បានប្រមាណ៨៥% នៃឃុំ សង្កាត់ទូទាំងប្រទេសដើម្បីពង្រឹង និងលើកកម្ពស់ការទទួលខុសត្រូវរបស់ឃុំ សង្កាត់ដែលជាថ្នាក់រដ្ឋបាលចុងក្រោយនៅជាប់ផ្ទាល់ ជាមួយប្រជាពលរដ្ឋ។

ក្រោយមក នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានធ្វើវិសោធនកម្មដោយបានកែប្រែឈ្មោះប្រទេសមកជារដ្ឋកម្ពុជាវិញ ក្នុងគោលដៅធ្វើការផ្សះផ្សារ បង្រួបបង្រួមជាតិពីគ្រប់និន្នាការនយោបាយ ដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅកម្ពុជា ឱ្យស្របជាមួយនឹងការវិវត្តប្រែប្រួលនៃសភាពការណ៍នយោបាយ សង្គម សេដ្ឋកិច្ចនៅកម្ពុជាក្នុងតំបន់ និងនៅលើពិភពលោកនាពេលនោះ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ បានធ្វើការកែសម្រួលការបែងចែកទឹកដីដូចខាងក្រោម៖[14]

ដែនដីនៃប្រទេសកម្ពុជាចែកជាខេត្ត និងក្រុង

- ខេត្តបែងចែកជាទីរួមខេត្ត និងស្រុក

[13] ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា* (២០១៨), ទំព័រ ៩។

[14] ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា* (២០១៨), ទំព័រ ១០។

- ទីរួមខេត្តបែងចែកជាសង្កាត់
- ស្រុកបែងចែក ជាឃុំ
- ក្រុងបែងចែកជាខណ្ឌ
- និងស្រុកជាយក្រុង
- ខណ្ឌបែងចែកជា សង្កាត់
- ស្រុកជាយ ក្រុងបែងចែកជាឃុំ ដូចស្រុកចំណុះខេត្ត។

ចំពោះរចនាសម្ព័ន្ធគ្រប់គ្រង និងអាណត្តិការងារនៅតាមដែនដីរដ្ឋបាលនីមួយៗមានលក្ខណៈ ប្រហាក់ប្រហែលគ្នាទៅនឹងការរៀបចំតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ដែរ ដោយគ្រាន់តែប្តូរឈ្មោះពីគណៈកម្មាធិការប្រជាជនបដិវត្តន៍ មកជាគណៈកម្មាធិការប្រជាជនវិញ។

### ១.២.៥. អភិបាលកិច្ចមូលដ្ឋានក្រោយការបោះឆ្នោតជាតិឆ្នាំ១៩៩៣

សង្គ្រាមស៊ីវិលដែលបានអូសបន្លាយប្រមាណបីទសវត្សរ៍ មិនត្រឹមតែបានបន្ទុចបង្អាក់ការអភិវឌ្ឍនៅកម្ពុជាលើគ្រប់វិស័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរនូវរចនាសម្ព័ន្ធ ប្រព័ន្ធនយោបាយរដ្ឋបាលសង្គម សេដ្ឋកិច្ច វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ ជាពិសេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ដល់ដើមឆ្នាំ១៩៧៩។ ក្រោយឆ្នាំ១៩៧៩ សង្គ្រាមស៊ីវិលនៅតែបន្តកើតមាននៅតាមតំបន់មួយចំនួនក្នុងប្រទេស។ ទោះយ៉ាងនេះក្តី រដ្ឋាភិបាលកម្ពុជានាពេលនោះ បានខិតខំរិះរកគ្រប់មធ្យោបាយដើម្បីស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិឡើងវិញលើគ្រប់វិស័យ ក្នុងនោះរួមទាំងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យមានសមត្ថភាពក្នុងការថែរក្សាសន្តិសុខ សុវត្ថិភាពតាមមូលដ្ឋាន ទប់ទល់ការប៉ុនប៉ងវិលត្រឡប់មកកាន់កាប់អំណាចឡើងវិញនូវរបបខ្មែរក្រហមផង និងម្ចាស់ការដោះស្រាយតម្រូវការជីវភាពរបស់ប្រជាជនតាមមូលដ្ឋានរៀងៗខ្លួន ក្នុងពេលដែលកម្ពុជាត្រូវទទួលរងការហ៊ុមព័ទ្ធពីខាងក្រៅ។[15]

ក្នុងគោលបំណងធ្វើការផ្សះផ្សា បង្រួបបង្រួមជាតិបញ្ចប់សង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ ដើម្បីនាំមកនូវសន្តិភាពការឯកភាពជាតិ ឯកភាពទឹកដី សំដៅធ្វើការកសាងជាតិឡើងវិញលើគ្រប់វិស័យ រដ្ឋាភិបាលនៃរដ្ឋកម្ពុជាបានសម្រេចចិត្តធ្វើការចរចាសម្របសម្រួលជាមួយភាគីជម្លោះនានាក្នុងសង្គ្រាមស៊ីវិល នៅកម្ពុជារហូតសម្រេចបានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ស្តីពីដំណោះស្រាយនយោបាយ នៅកម្ពុជានាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។

ផ្អែកលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅខែឧសភា ឆ្នាំ១៩៩៣ កម្ពុជាបានធ្វើការបោះឆ្នោតដោយផ្ទាល់ជ្រើសរើសតំណាងរាស្ត្រ តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សជាលើកដំបូងបន្ទាប់ពីជម្លោះផ្ទៃក្នុង និងសង្គ្រាមស៊ីវិលដែលអូសបន្លាយជិត០៣ទសវត្សរ៍។ ការបោះឆ្នោតនេះ ត្រូវបានរៀបចំឡើងក្រោមការចាត់ចែងរបស់អង្គការសហប្រជាជាតិ និងមានការចូលរួមពីគណបក្សនយោបាយចំនួន២០។

[15] ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា* (២០១៨), ទំព័រ ១១។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលត្រូវបានតាក់តែងរៀបចំជាថ្មីបានកំណត់ថា កម្ពុជាជាប្រទេសប្រកាន់យករបបគ្រប់គ្រងតាមបែបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ តាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងសេដ្ឋកិច្ចទីផ្សារសេរី។ រដ្ឋធម្មនុញ្ញនេះបានបែងចែកដែនដីរដ្ឋបាលដូចខាងក្រោម៖[16]

ដែនដីនៃព្រះរាជាណាចក្រកម្ពុជាចែកជាខេត្ត

- ក្រុងខេត្តចែកជា ស្រុក
- ស្រុកចែកជា ឃុំ
- ក្រុងចែកជា ខណ្ឌ
- ខណ្ឌចែកជា សង្កាត់។

ក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ មានបញ្ហាប្រឈមនានាជាច្រើនដែលត្រូវដោះស្រាយ ក្នុងការរៀបចំប្រព័ន្ធ និងរចនាសម្ព័ន្ធគ្រប់គ្រងប្រទេសឡើងវិញ។ ក្នុងនោះបញ្ហាដំបូងបំផុត គឺការសម្របសម្រួលខាងនយោបាយ ដើម្បីបង្កើតរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី១ នៃរដ្ឋសភាដែលត្រូវការសំឡេងគាំទ្រ ២/៣ ពីរដ្ឋសភា។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ គណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច បានព្រមព្រៀងគ្នារៀបចំរាជរដ្ឋាភិបាលចម្រុះដែលមានសហនាយករដ្ឋមន្ត្រី និងមានក្រសួងសំខាន់ៗចំនួន០៣ ដែលដឹកនាំដោយសហរដ្ឋមន្ត្រី រួមមានទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ។ ក្រសួងស្ថាប័នក្រៅពីនេះ ក៏ត្រូវបានបែងចែកគ្នាគ្រប់គ្រងក្នុងរាជរដ្ឋាភិបាល ចម្រុះផងដែរ។ ទន្ទឹមនេះ កងទ័ព នគរបាល មន្ត្រីរដ្ឋបាលស៊ីវិលពីភាគីគណបក្សហ៊្វុនស៊ិនប៉ិចដែល មានសំឡេងភាគច្រើនក្នុងរដ្ឋសភា និងភាគីគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនាដែលមានអាសនៈលំដាប់ទី៣ក្នុងរដ្ឋសភា ក៏ត្រូវបានធ្វើសមាហរណកម្មជាមួយភាគីអតីតរដ្ឋកម្ពុជាដឹកនាំ ដោយគណបក្សប្រជាជនកម្ពុជា ជាភាគីដែលមានរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងគ្របដណ្ដប់ទឹកដីប្រមាណ ៩០% ឲ្យទៅជាកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងមន្ត្រីរដ្ឋបាលស៊ីវិលតែមួយ ក្រោមដំបូលរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣តែមួយ។

ដោយឡែក នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏បានរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងឡើងវិញ និងធ្វើការបែងចែកមុខតំណែងអភិបាល អភិបាលរងខេត្ត ក្រុង ក្នុងចំណោមគណបក្ស នយោបាយក្នុងរាជរដ្ឋាភិបាលចម្រុះ ក្នុងនោះមានរាជធានីភ្នំពេញ និងខេត្តចំនួន១០ គណបក្សហ៊្វុនស៊ិនប៉ិច ទទួលមុខតំណែងជាអភិបាល និងខេត្តចំនួន១០ទៀត គណបក្សប្រជាជនកម្ពុជាទទួលមុខ តំណែងជាអភិបាល។ ការបែងចែកមុខតំណែងអភិបាល អភិបាលរងក្នុងចំណោមគណបក្សនយោបាយ ក្នុងរាជរដ្ឋាភិបាលចម្រុះនេះ ត្រូវបានបញ្ចប់នៅចុងអាណត្តិទី២ និងដើមអាណត្តិទី៣ នៃរដ្ឋសភា ដោយគណបក្សប្រជាជនកម្ពុជាដែលជាគណបក្សទទួលបានសំឡេងភាគច្រើននៅក្នុងរដ្ឋសភា ជាអ្នកទទួលបានមុខតំណែងអភិបាលរាជធានី ខេត្តទាំងអស់។

[16] ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា* (២០១៨), ទំព័រ ១២។

ចំពោះថ្នាក់ស្រុក ខណ្ឌ ឃុំ សង្កាត់ ក៏បានធ្វើការកែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រង ប៉ុន្តែក្នុងអាណត្តិទី១ និងដើមអាណត្តិទី២ នៃរាជរដ្ឋាភិបាលចម្រុះមិនមានការចុះសម្រុងគ្នាក្នុងការ សម្របសម្រួលខាងនយោបាយ ដើម្បីបែងចែកអំណាចនៅថ្នាក់រដ្ឋបាលទាំងនេះឡើយ។ តាមរយៈការរៀបចំឡើងវិញនេះ បានធ្វើឱ្យរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ មានលក្ខណៈជាការគ្រប់គ្រងបែបមជ្ឈការវិញ។ តួនាទី មុខងារ អំណាច ធនធាន ទាំងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុដែលបានផ្តល់យ៉ាងក្រាស់ក្រែលមុនឆ្នាំ១៩៩៣ ដែលធ្វើឱ្យរដ្ឋបាល ថ្នាក់ក្រោមជាតិជារដ្ឋបាលប្រកបដោយថាពលគ្រប់វិស័យនៅមូលដ្ឋាន ត្រូវបានដកហូតមកក្រោម ការគ្រប់គ្រងរបស់ថ្នាក់ជាតិតាមប្រព័ន្ធខ្សែបណ្តោយវិញ។ សាលាខេត្ត សាលាក្រុង ត្រូវស្ថិតនៅជា ខ្សែបណ្តោយរបស់ក្រសួងមហាផ្ទៃ។ សាលាស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវបានចាត់ទុកជាសាខា ឬអង្គភាពមួយរបស់សាលាខេត្ត ឬសាលាក្រុងសាមី។ តាមប្រព័ន្ធនេះ ទំនាក់ទំនងរវាងថ្នាក់ជាតិជាមួយថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងតែជាមួយខេត្ត ក្រុងតែប៉ុណ្ណោះ។ នៅពេលនោះ រដ្ឋបាលគ្រប់ថ្នាក់នៅថ្នាក់ ក្រោមជាតិមានស្ថានភាពដូចជា រដ្ឋបាលចាំផ្ទះ តែប៉ុណ្ណោះ។ រដ្ឋបាលនីមួយៗនៅថ្នាក់ក្រោមជាតិ ទទួលបានតែប្រាក់បៀវត្សរ៍មន្ត្រី បុគ្គលិកបម្រើការងារតាមសាលាខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងប្រាក់ចំណាយរដ្ឋបាលប្រចាំថ្ងៃតិចតួច ដែលស្ថិតក្នុងថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ។ អាស្រ័យ ដោយតម្រូវការនៃការបែងចែកអំណាចក្នុងក្រសួងមហាផ្ទៃ និងតម្រូវការនៃការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានដាក់ចេញនៅអនុក្រឹត្យលេខ ១៦ អនក្រ។[17]

ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ មុនពេលមាន ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ក្នុងអាណត្តិនៃរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី១ នៃរដ្ឋសភា (ក្រសួងមហាផ្ទៃត្រូវបានបង្កើតឡើងដោយការច្របាច់បញ្ចូលគ្នារវាងក្រសួងមហាផ្ទៃ និងក្រសួង សន្តិសុខជាតិ តាមព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ)។ ផ្អែកលើអនុក្រឹត្យខាងលើនេះ ក្រសួងមហាផ្ទៃបានចេញប្រកាសលេខ០៣១ ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩៤ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្ត ក្រុង។

ស្របពេលដែលរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី១ នៃរដ្ឋសភា ត្រូវរ៉ាប់រងដោះស្រាយបញ្ហាប្រឈមនានា ជាច្រើនដែលបន្សល់ទុកដោយសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ និងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ភាគីកម្ពុជាប្រជាធិបតេយ្យដែលជាភាគីហត្ថលេខីមួយនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស មិនបានអនុវត្តកិច្ចព្រមព្រៀងនេះ និងមិនបានចូលរួមបោះឆ្នោតជាតិនាឆ្នាំ១៩៩៣ឡើយ។ ភាគីនេះ បន្តធ្វើសកម្មភាពប្រដាប់អាវុធប្រឆាំងរាជរដ្ឋាភិបាលស្របច្បាប់ ដែលកើតចេញពីការបោះឆ្នោត ដើម្បីការពារទឹកដីមួយផ្នែកតូចដែលគេបាន និងកំពុងគ្រប់គ្រងនាពេលនោះ និងប៉ុនប៉ងពង្រីកតំបន់ត្រួតត្រាសំដៅឈានទៅគ្រប់គ្រងប្រទេសឡើងវិញ។

ដើម្បីបញ្ចប់សង្គ្រាម នាំមកនូវសន្តិភាពជូនប្រទេសជាតិ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាពេលនោះ ជានាយករដ្ឋមន្ត្រីទី២ បានផ្តួចផ្តើម និងដាក់ចេញនូវនយោបាយ "ឈ្នះ-ឈ្នះ" ដោយចាប់ផ្តើមពីភូមិសាស្ត្រឱរ៉ាល់ បន្តភ្ជាប់ទៅម៉ាឡៃ ប៉ៃលិន សំឡូត កំរៀង សំពៅលូន ភ្នំព្រឹក និងចុងក្រោយទៅអន្លង់វែង ដោយ

[17] ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា* (២០១៨), ទំព័រ ១៣។

បានធ្វើសមាហរណកម្មទាំងស្រុងនូវកម្លាំងកម្ពុជាប្រជាធិបតេយ្យ នាចុងឆ្នាំ១៩៩៨។ ចាប់ពីពេលនោះមក ប្រទេសជាតិមានសន្តិភាពពេញលេញមានការឯកភាពជាតិ ឯកភាពទឹកដី ដែលត្រូវបានគ្រប់គ្រងក្រោមដំបូលរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ តែមួយ។[18]

ក្នុងស្ថានភាពដ៏អំណោយផលនេះ កម្ពុជាមានការតាំងចិត្តខាងនយោបាយយ៉ាងមុតមាំ ដើម្បីរៀបចំចាត់ចែងបោះឆ្នោតជាតិលើកទី២ដោយខ្លួនផ្ទាល់។ ផ្អែកលើការតាំងចិត្តនេះ ច្បាប់បោះឆ្នោតជាតិត្រូវបានរៀបចំតាក់តែងឡើងដោយមន្ត្រីកម្ពុជា ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុមួយផ្នែកពី សហគមន៍អន្តរជាតិ។ ក្រោមច្បាប់បោះឆ្នោតជាតិនេះ ស្ថាប័នឯករាជ្យមួយ ត្រូវបានបង្កើតឡើងសម្រាប់ចាត់ចែងរៀបចំការបោះឆ្នោត គឺគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត «គ.ជ.ប»។

ការបោះឆ្នោតជាតិលើកទី២ បានប្រព្រឹត្តទៅតាមអាណត្តិដែលកំណត់ប្រកបដោយជោគជ័យ នាខែកក្កដា ឆ្នាំ១៩៩៨។ រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី២ នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្រត្រីកោណសម្រាប់ជារបៀបវារៈកំណែទម្រង់ការគ្រប់គ្រងប្រទេសជាតិ។

ទោះបីយ៉ាងនេះក្តី គណបក្សក្នុងរាជរដ្ឋាភិបាលចម្រុះនៅតែទាមទារបែងចែកអំណាចនៅ រដ្ឋបាលស្រុក ឃុំ សង្កាត់ និងនៅតាមភូមិនានាទូទាំងប្រទេស។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ គណបក្សប្រជាជនកម្ពុជាបានផ្តួចផ្តើមឱ្យមានការបោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់ ដើម្បីប្រកួតប្រជែង ការគ្រប់គ្រងឃុំ សង្កាត់តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ គំនិតផ្តួចផ្តើមនេះ ត្រូវបានទទួលយក និងគាំទ្រដោយគណបក្សហ្វ៊ុនស៊ិនប៉ិច។

ផ្អែកលើគំនិតផ្តួចផ្តើមនេះ ការសម្របសម្រួលខាងនយោបាយ ដើម្បីរៀបចំក្របខ័ណ្ឌគោលនយោបាយសម្រាប់ការបោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់ និងការធ្វើវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់រដ្ឋបាលនេះ ត្រូវបានរៀបចំឡើងនាឆ្នាំ១៩៩៩ និងឈានទៅរៀបចំច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវបានរដ្ឋសភាអនុម័ត នាខែមករា ឆ្នាំ២០០១។

នៅឆ្នាំ២០០២ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស ចំនួន១.៦២១ ឃុំ សង្កាត់ ត្រូវបានរៀបចំឡើងតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ចាប់ពីពេលនោះមក កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានធ្វើឡើងនៅថ្នាក់ឃុំ សង្កាត់។ សមិទ្ធផល នៃកំណែទម្រង់ដែលសម្រេចបាននៅថ្នាក់ឃុំ សង្កាត់ បានជំរុញ និងលើកទឹកចិត្តដល់រាជរដ្ឋាភិបាល ដើម្បីពង្រីកដំណើរការកំណែទម្រង់នេះដល់គ្រប់ថ្នាក់រដ្ឋបាលនៅថ្នាក់ក្រោមជាតិតាមរយៈការរៀបចំ ក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឆ្នាំ២០០៥ សម្រាប់ជាមូលដ្ឋាន តាក់តែងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ហើយការបោះឆ្នោតនៅថ្នាក់រដ្ឋបាលទាំងនេះត្រូវបានរៀបចំឡើងនាឆ្នាំ២០០៩។

[18] ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា* (២០១៨), ទំព័រ ១៤។

ផ្អែកលើតម្រូវការនៃការកែទម្រង់នេះ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រូវបានធ្វើវិសោធនកម្ម ដើម្បីរៀបចំឡើងវិញនូវដែនដីរដ្ឋបាលនៅព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម៖[19]

- ដែនដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានីភ្នំពេញ និងខេត្ត
- រាជធានីភ្នំពេញចែកជា ខណ្ឌ
- ខណ្ឌចែកជា សង្កាត់
- ខេត្តចែកជា ក្រុង និងស្រុក។
- ក្រុងចែកជា សង្កាត់។
- ស្រុកចែកជា ឃុំ និងជា សង្កាត់។

ការរៀបចំដែនដីតាមការបែងចែកនេះ គឺសំដៅរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងឲ្យបានជាក់លាក់រវាងតំបន់ទីក្រុង ទីប្រជុំជន និងតំបន់ជនបទ ដែលបានអនុវត្តរហូតមកទល់សព្វថ្ងៃ។

## ១.៣. ប្រព័ន្ធវិមជ្ឈការនិងប្រព័ន្ធវិសហមជ្ឈការ

### ១.៣.១. ប្រព័ន្ធវិមជ្ឈការ

#### ១.៣.១.១. និយមន័យ

វិមជ្ឈការ ជារចនាសម្ព័ន្ធរដ្ឋបាលមួយដែលត្រូវបានរៀបចំឡើងជា នីតិបុគ្គលសាធារណៈ។ នីតិបុគ្គលនេះ អាចជាសមូហភាពដែនដី ដែលគេហៅថា ការរៀបចំរចនាសម្ព័ន្ធរដ្ឋបាលវិមជ្ឈការដែនដី និង អាចជាអង្គការស្វយ័តនៃការ គ្រប់គ្រងសេវាសាធារណៈប្រកបដោយឯកទេសកម្មដែលគេហៅថា ការរៀបចំរចនាសម្ព័ន្ធរដ្ឋបាល « អំណាចក្នុងការសម្រេចរបស់អាជ្ញាធររដ្ឋបាលមូលដ្ឋានដោយមានចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់នានា។ ម្យ៉ាងមួយវិញទៀតយើងអាចនិយាយបានថា គឺជាទម្រង់នៃការរៀបចំរបស់អំណាចនីតិប្រតិបត្តិរបស់រដ្ឋដោយបានធ្វើការទទួលស្គាល់សមូហភាពដែនដីជា នីតិបុគ្គលសាធារណៈផ្សេងទៀត ដែលមានអំណាចនៅក្នុងការសម្រេចនូវរាល់កិច្ចការទាំងឡាយណាដែល ជាអត្ថប្រយោជន៍រួមរបស់ប្រជារាស្ត្ររស់នៅក្នុងសមូហភាពនោះបាន។[20]

វិមជ្ឈការ គឺមានន័យថាសិទ្ធិ អំណាច ការទទួលខុសត្រូវ និងធនធានមួយចំនួនត្រូវបានផ្ទេរពីរាជរដ្ឋាភិបាលថ្នាក់ជាតិ(ថ្នាក់កណ្ដាល) ទៅក្រុមប្រឹក្សាឃុំសង្កាត់ដែលបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋ ឬតាមលក្ខណៈប្រជាធិបតេយ្យ។ ប្រសិនបើរដ្ឋមិនអាចប្រមូលផ្ដុំអំណាចរដ្ឋបាលតែម្នាក់ឯងបាន ហើយទទួលស្គាល់សមូលភាពផ្សេងទៀត មានអំណាចរដ្ឋបានសម្រេចដោយស្វ័យភាពនូវរាល់កិច្ចការផងទាំងពួង ដែលជាផលប្រយោជន៍

---

[19] ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា* (២០១៨), ទំព័រ ១៥។

[20] ហៀង សាង, *នីតិរដ្ឋបាលទូទៅ* (២០២១), ទំព័រ ១៦៦។

ទូទៅរបស់ប្រជាជននៅក្នុងសមូហភាពនោះផ្ទាល់ ការគ្រប់គ្រងរបៀបនេះគេហៅថាការគ្រប់គ្រងបែបវិមជ្ឈការដែនដី។[21]

វិមជ្ឈការ គឺជារបៀបមួយនៃការគ្រប់គ្រងរដ្ឋទោលដែលរបៀបនេះរដ្ឋផ្ទេរអំណាចមួយចំនួនទៅឱ្យសមូហភាពដែនដី និងគ្រឹះស្ថានសាធារណៈមួយកំណត់ជាក់លាក់អមទៅជាមួយនូវមធ្យោបាយរដ្ឋបាលហិរញ្ញវត្ថុ និងការទទួលខុសត្រូវ។ អាចនិយាយម្យ៉ាងទៀតបានថាជាការទទួលស្គាល់ស្វ័យភាពនៃការគ្រប់គ្រងពោលគឺសេរី ភាពនៃការសម្រេចកិច្ចការមូលដ្ឋានផ្ទាល់។ ស្វ័យភាពមិនមែនជាឯករាជ្យភាពទេ ដូចនេះ រដ្ឋ ដើម្បីធានាឱ្យមានឯកភាពជាតិនិងរដ្ឋត្រូវត្រួតពិនិត្យលើការគ្រប់គ្រងរបស់សមូហភាព។

វិមជ្ឈការ មានន័យថាសិទ្ធិពិតប្រាកដ ការទទួលខុសត្រូវហើយធនធានពិតប្រាកដមួយចំនួនត្រូវបានផ្ទេរពីថ្នាក់កណ្ដាលរបស់រាជរដ្ឋាភិបាលទៅក្រុមប្រឹក្សា ឃុំ សង្កាត់ តាមរយៈការបោះឆ្នោតជ្រើសរើសតាមលក្ខណៈប្រជាធិបតេយ្យ ដែលត្រូវបានផ្ដល់ស្វ័យភាពក្នុងការសម្រេចលើកិច្ចការនានា ដែលបានចែងនៅក្នុងច្បាប់។ អត្ថន័យខាងលើនេះក៏ត្រូវបានបង្ហាញភាពស្របគ្នាផងដែរ ពីទីភ្នាក់ងារផ្ដល់ជំនួយសហរដ្ឋអាមេរិចដែលហៅកាត់ថា USAID ដែលបានឲ្យនិយមន័យពាក្យ វិមជ្ឈការថា ដែលត្រូវបានធ្វើជ្រើសតាំងដោយប្រជាពលរដ្ឋ។ ជាដំណើរការផ្ទេរអំណាចទៅឱ្យរដ្ឋបាលថ្នាក់មូលដ្ឋាន។

តាមទស្សនៈរបស់លោក Samaratunge (សាម៉ារ៉ាធុន) បានបង្ហាញថាដោយសារតែវាជាគំនិតមួយដ៏ស្មុគស្មាញ ដូច្នេះហើយទើបវិមជ្ឈការ ត្រូវបានឲ្យនិយមន័យផ្សេងៗគ្នា តាមស្ថានភាពរស់នៅរបស់មនុស្សទៅតាមតំបន់ និងតាមប្រទេសផ្សេងៗគ្នា។

វិមជ្ឈការ ជាដំណើរការនៃការផ្ទេរអំណាចទៅឱ្យរដ្ឋបាលមូលដ្ឋាន ដែលត្រូវបោះឆ្នោតជ្រើសតាំងដោយប្រជាពលរដ្ឋ។ គួរបញ្ជាក់ផងដែរថា សម្រាប់ USAID វិមជ្ឈការទាមទារនូវអត្ថិភាពនៃរដ្ឋបាលមូលដ្ឋាន ដែលត្រូវបានបោះឆ្នោតជ្រើសរើស ពីព្រោះមន្ត្រីមូលដ្ឋានទាំងនោះ នឹងពុំមានស្វ័យភាពទេ ប្រសិនបើពួកគេមិនបានឆ្លើយតបទៅនឹងអ្នកបោះឆ្នោតមូលដ្ឋាន។ វិមជ្ឈការមិនមានពន្យល់នៅក្នុងវចនានុក្រមខ្មែរទេ ព្រោះជាពាក្យថ្មីដែលត្រូវបានបង្កើតនៅក្នុងអំឡុងឆ្នាំ ២០០០ ដោយឥស្សរជនខ្មែរមួយរូប នៃរាជរដ្ឋាភិបាលកម្ពុជា។ ទោះយ៉ាងណា យើងអាចស្វែងយល់បានអំពីអត្ថន័យទូទៅនៃពាក្យនេះ បានតាមរយៈវិធីសាស្ត្របំបែកពាក្យ។

វិមជ្ឈការបានមកពី < វិ > + < មជ្ឈការ > ៖

- **វិ** គឺសំដៅដល់អ្វីដែលមិនមែនជា ឬដែលផ្ទុយពី។
- **មជ្ឈការ** គឺបានន័យថាការធ្វើឲ្យទៅជាកណ្ដាល។

ដូចនេះ វិមជ្ឈការបានសេចក្ដីថា ការធ្វើមិនឱ្យទៅជាកណ្ដាល ឬអាចនិយាយបានថា ការកាត់បន្ថយ ឬការ បញ្ឈប់ឲ្យទៅជាថ្នាក់កណ្ដាល។

[21] បណ្ឌិត សាយ បូរី, *នីតិរដ្ឋបាលទូទៅ* (២០០៦), ទំព័រ ៣៥៣។

ក្នុងប្រព័ន្ធរដ្ឋបាលសាធារណៈ វិមជ្ឈការ សំដៅដល់ការផ្ទេរសិទ្ធិអំណាចសម្រេច ឬស្វ័យភាពសម្រេចក្នុងការគ្រប់គ្រង និងផ្តល់សេវាសាធារណៈ ក្នុងដែនកំណត់មួយ។ ភាគច្រើនគេបែងចែកវិមជ្ឈការជាពីរប្រភេទធំៗ គឺ៖ វិមជ្ឈការបច្ចេកទេស និង វិមជ្ឈការដែនដី។

**១.៣.១.២. ប្រភេទវិមជ្ឈការ**

ប្រជាពលរដ្ឋនៅក្នុង ឃុំ សង្កាត់ មានសិទ្ធិបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ របស់ខ្លួន ហើយប្រជាពលរដ្ឋត្រូវបានផ្តល់សិទ្ធិ និងការទទួលខុសត្រូវឲ្យចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការអភិវឌ្ឍមូលដ្ឋាន ឃុំ សង្កាត់របស់ខ្លួន។ លើសពីនេះទៅទៀត ក្រុមប្រឹក្សា ឃុំ សង្កាត់ទាំងអស់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងតាមលក្ខណៈប្រជាធិបតេយ្យ។[22]

ដូច្នេះក្រុមប្រឹក្សានេះ ជាតំណាងឱ្យពលរដ្ឋនៅក្នុង ឃុំ សង្កាត់របស់ខ្លួន។ ក្រុមប្រឹក្សា ឃុំ សង្កាត់ត្រូវបានកំណត់មានអាណត្តិចំនួន ៥ឆ្នាំ ហើយត្រូវបានផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សា ឃុំ សង្កាត់ ថ្មីចូលកាន់តំណែង។ ហើយក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវបានផ្តល់ការទទួលខុសត្រូវ និងភារកិច្ចជាច្រើនដែលខុសប្លែកទាំងស្រុងពីការទទួលខុសត្រូវ និងភារកិច្ចរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ កាលពីមុនឆ្នាំ ២០០២។ ជាពិសេសភារកិច្ចសំខាន់បំផុតរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ គឺ អភិវឌ្ឍន៍ឃុំ សង្កាត់ ហើយលើកកម្ពស់សុខុមាលភាព និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួនថែមទៀតផង។[23]

ក្រុមប្រឹក្សា ឃុំ សង្កាត់ត្រូវធានាឱ្យបានថា សហគមន៍នៅមូលដ្ឋានចូលរួមយ៉ាងពេញលេញ និងសកម្មនៅ ក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ និងសេចក្តីសម្រេចនានាដែលមានឥទ្ធិពលទៅលើ ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដូចជា សេចក្តីសម្រេចលើការប្រើប្រាស់ធនធានសម្រាប់ការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនជាដើម។ ការធ្វើសេចក្តីសម្រេចដែលមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ នោះទើបសេចក្តីសម្រេចទាំងនោះទទួលបាននូវប្រសិទ្ធភាពខ្ពស់។

ហេតុនេះហើយវាជាការពិតប្រាកដណាស់ អ្វីក៏ដោយបើគ្មានការចូលរួមពីប្រជារាស្ត្រនោះទេ ទោះបីជារដ្ឋខិតខំប្រឹងប្រែងខ្លាំងយ៉ាងណាក៏ដោយ ក៏វាមិនអាចទៅរួមដែរ ដូចជាការងារអភិវឌ្ឍន៍នានាជាដើម។ ជាក់ស្តែងប្រសិនបើរាស្ត្រគ្មានលទ្ធភាពក្នុងការចូលរួមនោះទេ ការអភិវឌ្ឍនោះប្រាកដជាបានត្រឹមតែអភិវឌ្ឍន៍ទៅលើខ្លួនឯងតែប៉ុណ្ណោះ។

ឧទាហរណ៍៖ ក្រុមមន្ត្រីដែលទទួលភារកិច្ចតួនាទីជាអ្នកជួយរាស្ត្រ សម្រាប់ធ្វើការអភិវឌ្ឍកិច្ចការណាមួយ ហើយរាស្ត្រមើលឃើញថា មន្ត្រីនោះបានអភិវឌ្ឍន៍ខ្លួនឯង ជាជាងការអភិវឌ្ឍនៅក្នុងមូលដ្ឋានរបស់ខ្លួនគ្រប់គ្រង ដែរវាអាចសបញ្ជាក់បានថាការអភិវឌ្ឍដែលខ្វះដៃគូរដែលស្គាល់ពីតម្រូវការ និងបញ្ហាប្រឈមមុខដែលកំពុងកើតមានជាក់ស្តែងពាក់ព័ន្ធនឹងការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈ។

[22] បណ្ឌិត សាយ បូរី, *នីតិរដ្ឋបាលទូទៅ* (២០០៦), ទំព័រ ៣៩៣។

[23] បណ្ឌិត សាយ បូរី, *នីតិរដ្ឋបាលទូទៅ* (២០០៦), ទំព័រ ៣៩៤។

តាមរយៈវិមជ្ឈការ រដ្ឋផ្ទេរប្រតិភូកម្មសិទ្ធិអំណាច និងសមត្ថកិច្ចមួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកម្រិតណាមួយដែលអាចជារាជធានី/ខេត្ត ឬ ក្រុង / ស្រុក/ខណ្ឌ ឬ ឃុំ / សង្កាត់ ដែលរដ្ឋយល់ថាការសម្រេច និង ការអនុវត្តដោយផ្ទាល់ដោយអាជ្ញាធរមូលដ្ឋានកម្រិតណាមួយនោះ នឹងមានប្រសិទ្ធភាពជាងការសម្រេចចិត្តដោយរដ្ឋបាលកណ្តាល។

ជាទូទៅ រដ្ឋប្រគល់ជូនសមត្ថកិច្ចគ្រប់គ្រង និងផ្តល់សេវាសាធារណៈដែលជាតម្រូវការមូលដ្ឋានក្នុងជីវភាពប្រចាំថ្ងៃជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជា ទឹក ភ្លើង អប់រំ សុខាភិបាល ផ្លូវ និងសេវាដឹកជញ្ជូនជាដើម។ ក៏ប៉ុន្តែ ទន្ទឹមនេះរដ្ឋតែងតែរក្សាទុកនូវសមត្ថកិច្ចរបស់ខ្លួនលើវិស័យដែលតំណាងឱ្យអធិបតេយ្យរបស់ជាតិ ហើយដែលសិទ្ធិអំណាច និងសមត្ថកិច្ចលើវិស័យទាំងនេះមិនអាចប្រគល់ជូនថ្នាក់ក្រោមជាតិបានឡើយដូចជាសមត្ថកិច្ចលើ នយោបាយការបរទេស វិស័យការទូត យោធា យុត្តិធម៌ រូបិយប័ណ្ណជាដើម។

គេតែងសង្កេតឃើញថារដ្ឋបាលថ្នាក់ក្រោមជាតិ មិនមានស្ថានតំណាងខេត្តរបស់ខ្លួននៅក្រៅប្រទេសឡើយ រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏មិនមានកងទ័ពដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយឡែកនោះដែរ រីឯតុលាការដំបូងនៅតាមបណ្តាខេត្តគឺជាតុលាការរបស់រដ្ឋទាំងមូល ដែលស្ថិតក្រោមគណៈយុត្តាធិការតែមួយរបស់រដ្ឋ និងមិនស្ថិតក្រោមប្បញ្ញត្តិណាមួយរបស់រដ្ឋបាលថ្នាក់ខេត្តឡើយ។ ចុងក្រោយរូបិយប័ណ្ណ គឺមានតែមួយគត់សម្រាប់ការប្រើប្រាស់ទូទាំងប្រទេស បានសេចក្តីថា គ្មានរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយ អាចបោះពុម្ពរូបិយប័ណ្ណដោយឡែកសម្រាប់ការប្រើប្រាស់ដោយឡែកក្នុងរង្វង់ដែនដី។

**១.៣.១.៣. វិមជ្ឈការបច្ចេកទេស**

វិមជ្ឈការបច្ចេកទេស គឺសំដៅដល់ការប្រគល់សិទ្ធិអំណាចសម្រេច ឬ ស្វ័យភាពសម្រេចក្នុងគ្រប់គ្រងលើកិច្ចការជំនាញ ដោយឡែកណាមួយពីរដ្ឋទៅអាជ្ញាធររដ្ឋបាលបច្ចេកទេសណាមួយ។

ឧទាហរណ៍៖ អគ្គិសនីកម្ពុជាក្នុងការគ្រប់គ្រង និងផ្តល់សេវាសាធារណៈផ្នែកអគ្គិសនី។ រដ្ឋាករទឹកស្វយ័ត ក្នុងការគ្រប់គ្រង និងផ្តល់សេវាសាធារណៈផ្នែកផ្គត់ផ្គង់ទឹកស្អាត។ មន្ទីរពេទ្យរដ្ឋសម្រាប់ការគ្រប់គ្រង និងផ្តល់សេវាសាធារណៈ ផ្នែកសុខាភិបាល ឬសាកលវិទ្យាល័យរដ្ឋដែលបានផ្តល់សេវាសាធារណៈផ្នែកអប់រំជាដើម។[24]

**១.៣.១.៤. វិមជ្ឈការដែនដី**

វិមជ្ឈការដែនដី គឺសំដៅដល់ការប្រគល់ជូនអាជ្ញាធរដែនដីនៅថ្នាក់មូលដ្ឋាន ដែលត្រូវបានបោះឆ្នោតដោយប្រជាពលរដ្ឋនូវសមត្ថកិច្ច និងសិទ្ធិសម្រេចដោយឡែកពីសមត្ថកិច្ចរបស់រដ្ឋ ដើម្បីធានានូវតុល្យភាពអំណាចដ៏ប្រសើរនៅក្នុងដែនដីកំណត់មួយ។ ដូចនេះវិមជ្ឈការត្រូវបានសំដៅដល់របាយការណ៍ដែលរដ្ឋាភិបាលប្រគល់ឱ្យ ក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធានដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវរបស់ថ្នាក់មូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហានេះ។[25]

[24] ហៀង សាង, *នីតិរដ្ឋបាលទូទៅ* (២០២១), ទំព័រ ១៧៥។

[25] ហៀង សាង, *នីតិរដ្ឋបាលទូទៅ* (២០២១), ទំព័រ ១៦៧។

### ១.៣.១.៥. គោលបំណងនៃធ្វើវិមជ្ឈការ

ជាទ្រឹស្តី រដ្ឋជានីតិបុគ្គលសាធារណៈមុនគេបង្អស់ និងតែមួយគត់។ ក៏ប៉ុន្តែភាពផ្តាច់មុខនៃនីតិបុគ្គលភាពសាធារណៈរបស់រដ្ឋមិនអាចធ្វើឱ្យការគ្រប់គ្រងរដ្ឋដំណើរការទៅបានប្រកប ដោយប្រសិទ្ធភាពនោះឡើយ។ ស្ថានភាពដែលរាល់សេចក្តីសម្រេចសាធារណៈត្រូវធ្វើដោយថ្នាក់កណ្តាល ឬរដ្ឋនឹងពន្លឿតល្បឿននៃការអភិវឌ្ឍ និងធ្វើឱ្យបាត់បង់ប្រសិទ្ធភាព និងភាពទាន់ពេលវេលាក្នុងការគ្រប់គ្រង និងផ្តល់សេវាសាធារណៈតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

ហេតុនេះ រដ្ឋបង្កើតឱ្យមាននូវនីតិបុគ្គលផ្សេងទៀតដាច់ចេញពីរដ្ឋ ដោយបំពាក់ជូននីតិបុគ្គលទាំងនោះនូវស្វ័យភាព សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវតាមច្បាប់ជាធរមាន។ រដ្ឋមានសមត្ថកិច្ចលើគ្រប់វិស័យ តែរដ្ឋធ្វើវិមជ្ឈការ ដោយចែករំលែកសិទ្ធិអំណាច និងសមត្ថកិច្ចរបស់ខ្លួនមួយចំនួន ហើយប្រគល់ជូននូវមុខងារ និង ធនធាន (ហិរញ្ញវត្ថុ និង ធនធានមនុស្ស) ទៅឱ្យអាជ្ញាធរនៅថ្នាក់មូលដ្ឋានដែលនៅជិតប្រជារាស្ត្រប្រចាំថ្ងៃ និងដែលស្គាល់ពីតម្រូវការ និងបញ្ហាប្រឈមមុខដែលកំពុងកើតមានជាក់ស្តែងពាក់ព័ន្ធនឹងការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈ។

តាមរយៈវិមជ្ឈការ រដ្ឋធ្វើប្រតិភូកម្មសិទ្ធិអំណាច និងសមត្ថកិច្ចមួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកម្រិតណាមួយដែលអាចជារាជធានី/ខេត្ត ឬ ក្រុង / ស្រុក ខណ្ឌ ឬ ឃុំ / សង្កាត់ ដែលរដ្ឋយល់ថាការសម្រេច និង ការអនុវត្តដោយផ្ទាល់ដោយអាជ្ញាធរមូលដ្ឋានកម្រិតណាមួយនោះនឹងមានប្រសិទ្ធភាពជាងការសម្រេចចិត្តដោយរដ្ឋបាលកណ្តាល។ ជាទូទៅរដ្ឋប្រគល់ជូនសមត្ថកិច្ចគ្រប់គ្រង និងផ្តល់សេវាសាធារណៈ ដែលជាតម្រូវការមូលដ្ឋានក្នុងជីវភាពប្រចាំថ្ងៃជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជា ទឹក ភ្លើង អប់រំ សុខាភិបាល ផ្លូវ និងសេវាដឹកជញ្ជូនជាដើម។ ក៏ប៉ុន្តែទន្ទឹមនេះរដ្ឋតែងតែរក្សាទុកនូវសមត្ថកិច្ចរបស់ខ្លួនលើវិស័យដែលតំណាងឱ្យអធិបតេយ្យរបស់ជាតិ ហើយដែលសិទ្ធិអំណាច និងសមត្ថកិច្ចលើវិស័យទាំងនេះ មិនអាចប្រគល់ជូនថ្នាក់ក្រោមជាតិបានឡើយដូចជាសមត្ថកិច្ចលើនយោបាយការបរទេស វិស័យការទូត យោធា យុត្តិធម៌ រូបិយប័ណ្ណ ជាដើម។[26]

គេតែងសង្កេតឃើញថារដ្ឋបាលថ្នាក់ក្រោមជាតិ មិនមានស្ថានតំណាងខេត្តរបស់ខ្លួននៅក្រៅប្រទេសឡើយរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏មិនមានកងទ័ពដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយឡែកនោះដែរ រីឯតុលាការដំបូងនៅតាមបណ្តាខេត្ត គឺជាតុលាការរបស់រដ្ឋទាំងមូល ដែលស្ថិតក្រោមគណៈយុត្តាធិការតែមួយរបស់រដ្ឋ និងមិនស្ថិតក្រោមប្បញ្ញត្តិណាមួយរបស់រដ្ឋបាលថ្នាក់ខេត្តឡើយ។ ចុងក្រោយរូបិយប័ណ្ណ គឺមានតែមួយគត់សម្រាប់ការប្រើប្រាស់ទូទាំងប្រទេសបានសេចក្តីថា គ្មានរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយ អាចបោះពុម្ពរូបិយប័ណ្ណដោយឡែកសម្រាប់ការប្រើប្រាស់ដោយឡែកក្នុងរង្វង់ដែនដី។

### ១.៣.២. វិមជ្ឈការនៅកម្ពុជានាពេលបច្ចុប្បន្ន

វិមជ្ឈការ គឺជាការងារកែទម្រង់ស៊ីជម្រៅមួយ នៃរដ្ឋបាលសាធារណៈខ្មែរ ដែលរហូតមកដល់មុនឆ្នាំ ២០០១ ត្រូវបានចាត់ទុកថាជា រដ្ឋបាលមជ្ឈការ។ ការកែទម្រង់នេះផងដែរ បានផ្លាស់ប្តូររចនាសម្ព័ន្ធនៃការ

[26] លី រ៉ុង, *វិមជ្ឈការនៅប្រទេសកម្ពុជា* (២០១៧), ទំព័រ ៤។

គ្រប់គ្រងដែនដី។ រាជធានី ចែកចេញជាខណ្ឌ រីឯខណ្ឌចែកចេញសង្កាត់។ ដោយឡែក ខេត្ត ចែកចេញ ជាស្រុក និងក្រុង។ ខេត្តមានក្រុងយ៉ាងហោចណាស់មួយ ហើយក្រុងនោះគឺជា មជ្ឈមណ្ឌលរដ្ឋបាល សេដ្ឋកិច្ច ពាណិជ្ជកម្ម របស់ខេត្ត។

លើសពីនេះ ក្រៅពីទីក្រុងដែលជាទីប្រជុំជនរបស់ខេត្តហើយនោះ ខេត្តខ្លះ ក៏មានក្រុងលើសពីមួយដែរ ដូចជា ខេត្តកំពង់ចាម មានក្រុងសួង រីឯ ខេត្តស្វាយរៀង មានក្រុងបាវិត។ ចំណែកឯ ក្រុង ចែកចេញជា សង្កាត់ ហើយស្រុក ចែកចេញជា សង្កាត់ និងឃុំ។[27]

### ១.៣.២.១. រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

កំណែទម្រង់រដ្ឋបាលសាធារណៈតាមរយៈនយោបាយវិមជ្ឈការ មិនបានបញ្ឈប់ត្រឹមកម្រិតឃុំ សង្កាត់ នោះទេ។ ៧ឆ្នាំក្រោយការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ពោលគឺនៅឆ្នាំ ២០០៨ វិមជ្ឈការបានឈានទៅដល់ដំណាក់កាលទី២ ជាមួយនឹងការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុម ប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។[28]

នៅកម្រិតឃុំ សង្កាត់យើងបានដឹងថា ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំអង្គប្រជុំ ក្នុងនាមជាប្រធានក្រុមប្រឹក្សាផង និងជាប្រមុខដឹកនាំអង្គប្រតិបត្តិរបស់ឃុំ ដើម្បីអនុវត្តការសម្រេចរបស់ក្រុមប្រឹក្សាផង។ ផ្ទុយទៅវិញនៅកម្រិតរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានក្រុមប្រឹក្សា មិនមែនជាប្រមុខដឹកនាំអង្គប្រតិបត្តិទេ។ ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ច ត្រឹមជាប្រធានដែលដឹកនាំអង្គប្រជុំរបស់ក្រុមប្រឹក្សា និងជាអ្នកសម្របសម្រួលកិច្ចការមួយចំនួននៃអង្គប្រជុំរបស់ក្រុមប្រឹក្សាតែប៉ុណ្ណោះ។

ដោយឡែក តួនាទីជាប្រមុខដឹកនាំអង្គប្រតិបត្តិរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានប្រគល់ទៅឱ្យគណៈអភិបាលនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នោះ។ ដូចនេះ គណៈអភិបាលជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។ ចំណុចនេះអាចចាត់ទុកថាជាចំណុចពិសេសមួយ នៃវិមជ្ឈការនៅក្នុងប្រទេសកម្ពុជា។

ម្យ៉ាងវិញទៀត ក្នុងនាមជាក្រុមប្រឹក្សាគណៈអភិបាល គឺត្រូវចាត់វិធានការ ដើម្បីធានាឱ្យមន្ត្រី អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សាបំពេញនូវតួនាទី ភារកិច្ចរបស់ខ្លួន និងបំពេញការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា ព្រមទាំងអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រកបដោយប្រសិទ្ធភាព។

គណៈអភិបាលមិនមែន ជាស្ថាប័នដែលបានកើតចេញពីក្រុមប្រឹក្សាដែលបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋនៅមូលដ្ឋាននោះទេ ហើយក៏មិនមែនកើតចេញពីក្រុមប្រឹក្សាដែលបោះឆ្នោតផ្តល់សេចក្តីទុកចិត្តនោះដែរ។ គណៈអភិបាលដែលត្រូវបានតែងតាំងឡើងដោយរដ្ឋបាលកណ្តាលដែលមាន ការតែងតាំង ដោយព្រះមហាក្សត្រ (ព្រះរាជក្រឹត្យ ) ការតែងតាំងដោយនាយករដ្ឋមន្ត្រី (អនុក្រឹត្យ ) និងរួមទាំងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ (ប្រកាស)។

---

[27] លី វ៉ុង, *វិមជ្ឈការនៅប្រទេសកម្ពុជា* (២០១៧),ទំព័រ ៧។

[28] លី វ៉ុង, *វិមជ្ឈការនៅប្រទេសកម្ពុជា* (២០១៧), ទំព័រ ៨។

រីឯអភិបាល អភិបាលរង ដែលជាអង្គប្រតិបត្តិរបស់ក្រុមប្រឹក្សា គឺមិនមែនជាសមាជិកក្រុមប្រឹក្សាឡើយ។ ដូចនេះ អភិបាល អភិបាលរង មិនមានសិទ្ធិក្នុងការបោះឆ្នោតក្នុងក្រុមប្រឹក្សាទេ។ ចំណុចនេះខុសគ្នាពីករណី ឃុំ សង្កាត់ ព្រោះមេឃុំ ចៅសង្កាត់ ក៏ជាសមាជិករបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែរ ដែលហេតុនេះគាត់មានសិទ្ធិបោះឆ្នោតក្នុងក្រុមប្រឹក្សា។

គណៈអភិបាល គឺត្រូវផ្តល់យោបល់ជូនក្រុមប្រឹក្សា រាយការណ៍ជូនក្រុមប្រឹក្សា និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ។ គណៈអភិបាល ត្រូវរៀបចំដាក់ជូនក្រុមប្រឹក្សាពិនិត្យ និង អនុម័តនូវកម្មវិធីវិនិយោគ៣ឆ្នាំរំកិលប្រចាំឆ្នាំ និងគម្រោងថវិកាប្រចាំឆ្នាំ ផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ និងក្របខណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នជារៀងរាល់ឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាដែលត្រូវរាយការណ៍ជូនប្រជាពលរដ្ឋរបស់ខ្លួន។

ចំណែកឯក្រុមប្រឹក្សាវិញ ត្រូវពិនិត្យមើលសកម្មភាព និងការអនុវត្តរបស់គណៈអភិបាល និង អភិបាលគណៈអភិបាល ឬអភិបាលដែលបានសម្រេច ឬអនុវត្តកិច្ចការណាមួយដែលស្ថិតក្នុងដែនដីសមត្ថកិច្ចរបស់ក្រុមប្រឹក្សាតែពុំទទួលបានការសម្រេចពីក្រុមប្រឹក្សា ការសម្រេចនោះពុំមានសុពលភាពទេ ។[29]

### ១.៣.២.២. រដ្ឋបាលឃុំ សង្កាត់

យោងនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ជំពូកទី១៣ថ្មី អំពីការគ្រប់គ្រងរដ្ឋបាល មាត្រា១៤៥បានចែងថាៈ ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមាត្រា១៤៦បានចែងថា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គ្រប់គ្រងតាមលក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់រៀបចំអង្គការ។[30]

របបគតិយុត្តថ្មីនៃរដ្ឋបាលឃុំ សង្កាត់ ត្រូវគ្រប់គ្រងដោយច្បាប់ស្តីពីការ គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ រីឯការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានបើកផ្លូវដោយ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ ច្បាប់ទាំងពីរនេះត្រូវបានអនុម័ត និងប្រកាសឱ្យប្រើនៅក្នុងឆ្នាំ ២០០១។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានរៀបចំចំនួន៥អាណត្តិរួចមកហើយ។ រីឯសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋផ្ទាល់។

នៅថ្នាក់ក្រោមជាតិ ក៏ដូចជានៅថ្នាក់ជាតិសមត្ថកិច្ចនៃការគ្រប់គ្រងត្រូវបានបែងចែករវាងអំណាចនីតិប្បញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ។ នៅថ្នាក់ក្រោមជាតិ អំណាចនីតិប្បញ្ញត្តិ បានន័យថា អំណាចចេញសេចក្តីសម្រេចជារបស់ក្រុមប្រឹក្សា រីឯអំណាចក្នុងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាត្រូវបានផ្តល់ទៅឱ្យអង្គប្រតិបត្តិមួយរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់។[31]

[29] លី វ៉ុង, *វិមជ្ឈការនៅប្រទេសកម្ពុជា* (២០១៧), ទំព័រ ៩។

[30] *រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣, វិសោធកម្មច្បាប់ថ្មីឆ្នាំ២០០៨, មាត្រា ១៤៥,១៤៦។*

[31] លី វ៉ុង, *វិមជ្ឈការនៅប្រទេសកម្ពុជា* (២០១៧), ទំព័រ ១០។

### ១.៣.២.៣. ទំហំនៃវិមជ្ឈការដែលរៀបចំនៅកម្ពុជា

ដើម្បីអនុវត្តប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ ក្រសួងមហាផ្ទៃត្រូវបានរៀបចំច្បាប់ពីរ ដែលមានទំនាក់ទំនងផ្សាភ្ជាប់គ្នា គឺច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលបានអនុម័តនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០០១ ហើយត្រូវបានប្រកាសឱ្យបានប្រើនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័តនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០១ ហើយត្រូវបានប្រកាសឱ្យ ប្រើនៅថ្ងៃទី១៩ ខែ មីនា ឆ្នាំ២០០១។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គឺជាការបង្ហាញនូវគំនិត និងទំហំវិមជ្ឈការនៅកម្ពុជា។ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាការកម្រិតនៃបែបបទ និងនីតិវិធីក្នុងការបោះឆ្នោតក្នុងលក្ខខណ្ឌសេរីត្រឹមត្រូវ យុត្តិធម៌ និងឈរលើគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស។

ដំណើរការវិមជ្ឈការ ត្រូវបានរៀបចំបង្កើតដោយមានអាជ្ញាធរមូលដ្ឋាននៅក្នុងឃុំ សង្កាត់នីមួយៗដែលខុសពីរដ្ឋបាលថ្នាក់ជាតិ និងដឹកនាំដោយតំណាងឃុំ សង្កាត់ដែលជាប់ឆ្នោត ដើម្បីអនុវត្តដែនសមត្ថកិច្ច របស់ខ្លួនក្នុងក្របខ័ណ្ឌឃុំ សង្កាត់។

នៅក្នុងដំណើរការឃុំ សង្កាត់ចាំបាច់ត្រូវការមានទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីបណ្តុះបណ្តាលធនធានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំកសាងផែនការអភិវឌ្ឍមូលដ្ឋាន និងថវិកាឃុំ សង្កាត់ ឱ្យមានការទទួលខុសត្រូវ តម្លាភាព និងអភិបាលកិច្ចល្អស្របតាមគោលការណ៍នយោបាយរបស់រាជរដ្ឋាភិបាល។

### ១.៣.៣. ប្រព័ន្ធវិសហមជ្ឈការ

### ១.៣.៣.១. និយមន័យ

វិសហមជ្ឈការ គឺជាការដែលរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលធ្វើប្រតិភូកម្ម មុខងារ សិទ្ធិអំណាច និងធនធានទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន។ អង្គភាព ឬក្រុមប្រឹក្សានោះត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នដែលបានធ្វើប្រតិភូកម្មនោះ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអនុវត្តកិច្ចការទាំងនោះតាមការណែនាំ ឬចង្អុលបង្ហាញពីរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន ហើយការទទួលខុស ត្រូវចុងក្រោយចំពោះការអនុវត្តកិច្ចការទាំងនេះនៅតែជារបស់រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នដែលបានធ្វើប្រតិភូកម្មដដែល។[32]

វិសហមជ្ឈការ គឺជាបច្ចេកទេសគ្រប់គ្រងរដ្ឋបាលមួយដែលអាជ្ញាធររដ្ឋបាលកណ្តាល បានរំលែកកិច្ចការមួយចំនួនទៅឱ្យអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមធ្វើការសម្រេច ដោយខ្លួនឯងផ្ទាល់តាមការកំណត់ហើយសេចក្តីសម្រេចនានានោះតាំងនាមឱ្យអាជ្ញាធរ រដ្ឋបាលកណ្តាល។ ម្យ៉ាងទៀតនៅក្នុងក្របខណ្ឌវិសហមជ្ឈការ គឺញញួរតែមួយដែល ក៏ប៉ុន្តែគេគ្រាន់តែកាត់ដងវាឱ្យខ្លីប៉ុណ្ណោះ។

យើងឃើញថា ជានិច្ចកាលគឺរដ្ឋធ្វើសកម្មភាពប៉ុន្តែដើម្បីឱ្យមានប្រសិទ្ធភាពរដ្ឋបានបង្ខិតអាជ្ញាធរមួយចំនួនរបស់ខ្លួនឱ្យមកកៀកប្រជារាស្ត្រ។

[32] សាលាជាតិរដ្ឋបាលមូលដ្ឋាន,*ការគ្រប់គ្រងរដ្ឋបាលស្រុកតាមបែបវិមជ្ឈការ* (២០១៩), ទំព័រ ៣។

ដូច្នេះ អាជ្ញាធរថ្នាក់ក្រោមនេះធ្វើការសម្រេចកិច្ចការចាំបាច់ និងបន្ទាន់ខ្លះៗនៅនឹងកន្លែង (មូលដ្ឋាន) ដោយមិនចាំបាច់សុំការអនុញ្ញាតនៅក្នុងការសម្រេចពីអាជ្ញាធរ រដ្ឋបាលកណ្តាលដូចមុនឡើយ។ ពីព្រោះថា អាជ្ញាធរថ្នាក់ក្រោមនៅពេលនេះទទួលបាន នូវសិទ្ធិអំណាចក្នុងការសម្រេចតាមការកំណត់ឱ្យនៅក្នុងលក្ខខណ្ឌ ដែលចែងច្បាស់លាស់ ដោយអត្ថបទគតិយុត្តទៅហើយ។[33]

**១.៣.៣.២. ចរិតលក្ខណៈ**

នៅក្នុងការគ្រប់គ្រងរដ្ឋបាលតាមបច្ចេកទេសនេះ (វិសហមជ្ឈការ) គឺជាការគ្រប់គ្រងតាមឋានុក្រមរដ្ឋបាល ដែលអំណាចកណ្តាលបានផ្តល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោម សម្រេចតាមលំដាប់ថ្នាក់រៀងៗខ្លួន។

គ្រប់លំដាប់ថ្នាក់នេះ គឺតាំងតំណាងរបស់អំណាចកណ្តាលដោយគ្មានការបោះឆ្នោតជ្រើសតាំងទេ។ ពោលគឺអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមទាំងនេះ កើតមានឡើងនូវសិទ្ធិក្នុងការសម្រេច គឺអាស្រ័យដោយសប្បុរសធម៌របស់អាជ្ញាធររដ្ឋបាលកណ្តាលប៉ុណ្ណោះ។ នៅក្នុងការប្រើប្រាស់ថវិកាវិញ គឺថវិកាជាតិដែលផ្តល់ឱ្យ ដោយអាជ្ញាធររដ្ឋបាលកណ្តាលដើម្បីបំពេញនូវសេចក្តីត្រូវការរបស់រាស្ត្រប្រជាស្របតាមដំណើរការប្រព្រឹត្តទៅរបស់រដ្ឋបាលថ្នាក់ក្រោម។ និយាយរួម អាជ្ញាធរថ្នាក់ក្រោមនេះមិនទាន់មានសិទ្ធិក្នុង ការទទួលចំណូលដើម្បីធ្វើការចំណាយដោយខ្លួនឯងទេ។ ប្រសិនបើមានវិញ លុះត្រាតែអាជ្ញាធរនៃអំណាចកណ្តាលប្រគល់សិទ្ធិឱ្យ(វិមជ្ឈការហិរញ្ញវត្ថុ)។

ចំណែកឯបុគ្គលិកដែលបម្រើការនៅក្នុងរដ្ឋបាលថ្នាក់ក្រោមនេះវិញ ត្រូវបានតែងតាំងឱ្យដោយអាជ្ញាធរនៃអំណាចរដ្ឋបាលកណ្តាល។ អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមនេះ គឺគ្មានសិទ្ធិជ្រើសរើសបុគ្គលិកទាំងនេះដោយខ្លួនឯងបាននោះទេ។ បុគ្គលិកទាំងអស់ត្រូវតែ គោរពទៅតាមព្រំដែនសមត្ថកិច្ច និងត្រូវគោរពឋានានុក្រមជានិច្ច។

យើងដឹងស្រាប់ហើយថា អាជ្ញាធររដ្ឋបាលកណ្តាលជាអ្នកសម្រេចនូវរាល់កិច្ចការទូទៅរបស់រដ្ឋ ឯអាជ្ញាធររដ្ឋបាលមូលដ្ឋានវិញដែលទទួលបាននូវសិទ្ធិអំណាចក្នុងការសម្រេច គឺត្រូវធ្វើត្រឹមតែការកំណត់ប៉ុណ្ណោះ ដោយក្នុងគោលដៅដើម្បីកាត់បន្ថយនូវផលអាក្រក់ទាំងឡាយរបស់ប្រព័ន្ធមជ្ឈការ។

ឧទាហរណ៍ៈ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្មបានផ្តល់សិទ្ធិឱ្យលោកប្រធាន មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តចេញនូវលិខិតអនុញ្ញាតមានរយៈពេលមួយឆ្នាំដល់សិប្បករ។ តែបើសិប្បករ ត្រូវការលិខិតអនុញ្ញាតរយៈពេលពីរឆ្នាំវិញនោះលោកប្រធាន មន្ទីរគ្មានសមត្ថកិច្ចឡើយ។

បច្ចេកទេសវិសហមជ្ឈការ គឺរាល់ការសម្រេចពោរពេញទៅដោយ វិចារណញ្ញាណ ហើយមានប្រសិទ្ធភាពឆាប់រហ័ស ដែលប្រទេសជាច្រើននៅលើសាកលលោកបាននឹងកំពុងអនុវត្តនូវរូបមន្តរំលែកអំណាចកណ្តាលបែងនេះ។

ដូច្នេះយើងឃើញថា វិសហមជ្ឈការ គឺជាបច្ចេកទេសមួយ ជារបៀបរៀបចំមួយ ដែលមានសមត្ថភាពគ្រប់គ្រាន់ នៅក្នុងការសម្របសម្រួលបេសកកម្មនៃការបម្រើសេវាសាធារណៈរបស់ខ្លួនជាមួយនឹងតម្រូវការរបស់

[33] ហៀង សាង, *នីតិរដ្ឋបាលទូទៅ* (២០២១), ទំព័រ ១៥៤។

រាស្ត្រប្រជានិងជារដ្ឋបាលសាធារណៈមួយដែលខិតជិតរាស្ត្រប្រជា។[34]

**១.៣.៣.៣. វិធីសាស្ត្រក្នុងការរំលែកអំណាចកណ្តាលបែង**

ការរំលែកអំណាចកណ្តាលបែងនៅក្នុងការសម្រេចនេះ គេប្រើវិធីសាស្ត្រមួយហៅថាប្រតិភូកម្ម។ ប្រតិភូកម្មចែកចេញជាពីរគឺ៖[35]

- ប្រតិភូកម្មអំណាច
- ប្រតិភូកម្មហត្ថលេខា

វិធីសាស្ត្រនេះ ជួនកាលគេបញ្ជាក់ដោយពាក្យទូទៅមួយដែលហៅថា ប្រតិភូកម្មសមត្ថកិច្ច ដើម្បីជាបម្រើបម្រាស់នៅក្នុងការប្រព្រឹត្តទៅនៃរដ្ឋបាលសាធារណៈ។

**១. ប្រតិភូកម្មអំណាច**

ប្រតិភូកម្មអំណាច គឺជាការផ្ទេរសមត្ថកិច្ចមួយផ្នែកទៅឱ្យអាជ្ញាធររដ្ឋបាលទាំងឡាយនៅក្នុងឋានានុក្រមរដ្ឋបាលរបស់ខ្លួនប៉ុណ្ណោះ។ ប្រតិភូកម្មអំណាចនេះ ធ្វើទៅបាន លុះត្រាតែមានលិខិតបទដ្ឋានគតិយុត្តចែងប៉ុណ្ណោះ។ ប្រតិភូកម្មអំណាច ពុំអាចធ្វើតាមការនឹកឃើញហើយ ក៏ពុំអាចធ្វើទាំងស្រុងដែរ។នីតិវិធីនៃការធ្វើប្រតិភូកម្មអំណាចនេះ គឺត្រូវផ្សព្វផ្សាយជាសាធារណៈហើយយុទ្ធសាស្ត្រទាមទារឱ្យមានការសរសេរជាលាយលក្ខណ៍អក្សរឱ្យបានច្បាស់លាស់។ ពីព្រោះវិបាកនៃប្រតិភូកម្មអំណាចនេះ វាជាក់លាក់ណាស់ ដូចជា៖

វានាំឱ្យមានការផ្ទេរអំណាចមួយផ្នែកយ៉ាងពិតប្រាកដ គឺថាប្រតិភូនាយក ( អ្នក ផ្ទេរអំណាច ) ក្លាយទៅជាអសមត្ថកិច្ចលើផ្នែកដែលបានផ្ទេរហើយអំណាចតទៅវាជាសិទ្ធិក្នុងការសម្រេចរបស់ប្រតិភូ (អ្នកទទួលការផ្ទេរអំណាច)។ សេចក្តីសម្រេចរបស់ប្រតិភូលើផ្នែកដែលបានផ្ទេរមកនេះ គឺមានអានុភាពគតិយុត្តស្មើថ្នាក់របស់ខ្លួន។ឧទាហរណ៍ៈ ប្រតិភូនាយក ជានាយករដ្ឋមន្ត្រីទៅឱ្យប្រតិភូជារដ្ឋមន្ត្រី។ ដូច្នេះ រដ្ឋមន្ត្រី សម្រេចលើផ្នែកដែលផ្ទេរមកនេះដោយចេញប្រកាស។

សម្គាល់៖ ប្រតិភូកម្មអំណាច ធ្វើឡើងដោយអង្គការមួយទៅអង្គការមួយនៅក្នុងឋានានុក្រមនៃរដ្ឋបាលសាធារណៈ។[36]

**២.ប្រតិភូកម្មហត្ថលេខា**

ប្រតិភូកម្មហត្ថលេខា គឺជាវិធីមួយដែលតាមរយៈនេះអាជ្ញាធររដ្ឋបាលនីមួយៗ បានប្រគល់ទៅឱ្យសហការីណាម្នាក់របស់ខ្លួននូវការចុះហត្ថលេខាជំនួសទៅលើសេចក្តីសម្រេចខ្លះៗដែលនេះជាភាពងាយស្រួលមួយផ្នែកការងារគ្រប់គ្រងរដ្ឋបាល ដោយពុំចាំបាច់ធ្វើប្រតិភូកម្មអំណាចទៀតទេ។ សហការីនេះ មិនអាចផ្ទេរការចុះ

[34] ហៀង សាង, *នីតិរដ្ឋបាលទូទៅ* (២០២១), ទំព័រ ១៥៥។

[35] ហៀង សាង, *នីតិរដ្ឋបាលទូទៅ* (២០២១), ទំព័រ ១៥៦។

[36] ហៀង សាង, *នីតិរដ្ឋបាលទូទៅ* (២០២១), ទំព័រ ១៥៧។

ហត្ថលេខាជំនួសនេះទៅឱ្យជនទីបីបានឡើយ។ ប្រតិភូកម្មហត្ថលេខានេះ ត្រូវប្រគល់ឲ្យចំឈ្មោះបុគ្គល ដែលជាសហការីដោយបញ្ជាក់ពី៖[37]

- ឋានៈ
- មុខងារ
- និងតួនាទីឱ្យបានច្បាស់លាស់ ហើយត្រូវធ្វើសាជាថ្មីប្រសិនបើមានការផ្លាស់ប្តូរនូវ បុគ្គល (អាចជាប្រតិភូនាយក ឬ ប្រតិភូ)។

ការធ្វើប្រតិភូកម្មនេះ មានតែលើការចុះហត្ថលេខាប៉ុណ្ណោះ ដោយគ្មានការប៉ះពាល់ដល់ការបែងចែកអំណាចទេ។ អាជ្ញាធរ ដែលបានផ្ទេរហត្ថលេខារបស់ខ្លួននេះអាចរក្សាសិទ្ធិចុះហត្ថលេខាវិញនៅគ្រប់ពេលវេលា។ តាមផ្លូវច្បាប់ រាល់សេចក្តីសម្រេចទាំងឡាយរបស់ប្រតិភូគឺជាសេចក្តីសម្រេចរបស់ប្រតិភូនាយក។ ដូច្នេះ ប្រតិភូនាយកនៅតែជា ម្ចាស់នៃអំណាចហើយនៅតែជាអ្នកទទួលខុសត្រូវដដែល។ លើកលែងតែក្នុងករណីដែលអ្នកទទួលការផ្ទេរហត្ថលេខានេះ បានប្រព្រឹត្តផ្ទុយទៅនឹងសេចក្តីសម្រេចរបស់ប្រតិភូនាយកប៉ុណ្ណោះ។ នៅក្នុងករណីនេះប្រតិភូត្រូវទទួលខុសត្រូវដោយខ្លួនឯង។ ហេតុដូច្នេះ បានជាផ្លូវច្បាប់តម្រូវឱ្យរាល់ការចុះហត្ថលេខាជំនួសនេះត្រូវទុកជាឯកសារឱ្យអាជ្ញាធរ ផ្ទេរហត្ថលេខាធ្វើការត្រួតពិនិត្យគ្រប់ពេលវេលា និងគ្រប់ករណី។

សម្គាល់ ប្រតិភូកម្មហត្ថលេខា គឺជាវិធីសាស្ត្រមួយទន់ភ្លន់ជាងប្រតិភូកម្មអំណាចនៅក្នុងការអនុវត្តនៃរដ្ឋបាលសារធាណៈ។[38]

**១.៣.៣.៤. អំណាចឋានានុក្រម**

ការគ្រប់គ្រងរដ្ឋបាលនៃប្រព័ន្ធមជ្ឈការ បានបញ្ចេញបច្ចេកទេសវិសហមជ្ឈការនេះ គឺស្ថិតនៅក្រោមការគ្រប់គ្រងមួយដែលគេហៅថា នាយចៅហ្វាយ។

អំណាចឋានានុក្រមនេះ គឺទទួលស្គាល់ដោយអាជ្ញាធរកណ្តាល ហើយធ្វើការដឹកនាំលើមន្ត្រីក្រោមឱវាទទាំងអស់តាមលំដាប់។ បានន័យថា អ្នកមានស័ក្តិខ្ពស់ត្រួតត្រា និងដឹកនាំអ្នកមានបុណ្យស័ក្តិទាបជាងខ្លួន ហើយអ្នកមានបុណ្យស័ក្តិទាបនេះ ក៏ត្រួតត្រា និងដឹកនាំអ្នកក្រោមឱវាទដែលគ្មានបុណ្យស័ក្តិបន្ត។ អំណាចឋានានុក្រម មានតាំងពីនៅក្នុងម៉ាក្រូអង្គភាព និងចុះរហូតទៅដល់មីក្រូអង្គភាព។

ម៉ាក្រូអង្គភាព គឺសំដៅទៅលើអង្គភាពធំៗដែលមាននៅថ្នាក់ជាតិដូចជា៖[39]

- ក្រសួង
- រដ្ឋលេខាធិការដ្ឋាន
- អាជ្ញាធររដ្ឋបាលឯករាជ្យជាដើម។

មីក្រូអង្គភាព គឺសំដៅទៅលើអង្គភាពតូចៗដែលមាននៅថ្នាក់ជាតិ ដូចជា៖

[37] ហៀង សាង, *នីតិរដ្ឋបាលទូទៅ* (២០២១), ទំព័រ ១៥៨។

[38] ហៀង សាង, *នីតិរដ្ឋបាលទូទៅ* (២០២១), ទំព័រ ១៦០។

[39] ហៀង សាង, *នីតិរដ្ឋបាលទូទៅ* (២០២១), ទំព័រ ១៦១។

- អគ្គនាយកដ្ឋាន
- នាយកដ្ឋាន
- ការិយាល័យ និង ផ្នែកជាដើម។

នៅថ្នាក់ក្រោមជាតិ ដូចជា៖

- មន្ទីរជំនាញ
- ការិយាល័យជំនាញ
- និង ផ្នែកជំនាញជាដើម។

អំណាចឋានានុក្រមនេះ គឺមានអត្ថបទច្បាប់បានកំណត់ច្បាស់លាស់ពីការដឹកនាំ និងត្រួតពិនិត្យលើភ្នាក់ងារទាំងលើបុគ្គល និងទាំងលើសកម្មភាព។

**ក.ការត្រួតពិនិត្យលើបុគ្គលជាភ្នាក់ងារ**

អំណាចឋានានុក្រមនេះ គឺមានសិទ្ធិត្រួតពិនិត្យលើបុគ្គលដែលជាភ្នាក់ងារទោះតាមរយៈខ្សែបណ្ដោយក្ដី ឬ ខ្សែទទឹងក្ដី។

នៅក្នុងករណីនេះវាទាក់ទងទៅនឹង៖

- ការដាក់ពិន្ទុ
- ការមូល វិចារណ៍
- ការស្នើដំឡើងឋានន្តរស័ក្តិ
- ការជូនមតិលើកសំណើតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ច
- ការដាក់ទណ្ឌកម្មជាដើម។

**ខ.ការត្រួតពិនិត្យលើសកម្មភាពរបស់ភ្នាក់ងារ**

អំណាចឋានានុក្រមនេះ មានសិទ្ធិលើកទិសដៅដាក់ឱ្យមន្ត្រីរាជការនៅថ្នាក់ក្រោមឱវាទអនុវត្តឱ្យបានល្អស្របតាមគោលនយោបាយរបស់រដ្ឋ។

ការដាក់ឱ្យមន្ត្រីរាជការថ្នាក់ក្រោមអនុវត្តន៍នេះ តាមរយៈការចេញបទបញ្ជា ការណែនាំ ហើយធ្វើការត្រួតពិនិត្យឡើងវិញទៅលើលទ្ធផលនៃសកម្មភាព។ ទន្ទឹមនេះដែរ អំណាចឋានានុក្រមក៏មានភារកិច្ចនៅក្នុងការតម្រែតម្រង់មន្ត្រីរាជការថ្នាក់ក្រោម ប្រសិនបើមានទង្វើមិនសមស្របតាមទិសដៅ និងស្មារតីនៃច្បាប់។

សម្គាល់៖ ភ្នាក់ងារ អនុវត្តន៍តាមបញ្ជាទៅលើសកម្មភាពទាំងឡាយណាដែលស្ថិតនៅក្នុង សមត្ថកិច្ចរបស់ខ្លួនហើយត្រូវស្របច្បាប់ផង។[40]

[40] ហៀង សាង, *នីតិរដ្ឋបាលទូទៅ* (២០២១), ទំព័រ ១៦២។

### ១.៣.៣.៥. គុណសម្បត្តិ និងគុណវិបត្តិ

ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមបែបវិសហមជ្ឈការ ក៏មានគុណសម្បត្តិ និងគុណវិបត្តិផងដែរដូចជា៖[41]

- **គុណសម្បត្តិ**
  - កាត់បន្ថយការប្រើអំណាចជ្រុលហួសហេតុរបស់អាជ្ញាធរនៃប្រព័ន្ធមជ្ឈការ
  - អាជ្ញាធរថ្នាក់ក្រោម សម្រេចបញ្ហានៅនឹងកន្លែងនូវកិច្ចការមួយចំនួនតាមការកំណត់
  - ការងារឆាប់រហ័ស ចំណេញពេលវេលា និងការចំណាយ។
- **គុណវិបត្តិ**
  - ខ្វះលទ្ធិប្រជាធិបតេយ្យដដែល ព្រោះវិសហមជ្ឈការនេះអាជ្ញាធររដ្ឋបាលកណ្តាល នៅតែរក្សាអំណាចតែងតាំង និងអំណាចចាត់ចែងថវិកា។

[41] ហៀង សាង, *នីតិរដ្ឋបាលទូទៅ* (២០២១), ទំព័រ ១៥៩។

# ជំពូកទី២

# ការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់

# ជំពូកទី២

# ការគ្រប់គ្រងរដ្ឋបាលឃុំសាន់គ

## ២.១. ប្រវត្តិ និងស្ថានភាពទូទៅ

បានលើកឡើងតៗគ្នាថា កាលជំនាន់ដើមឃុំសាន់គនេះ ត្រូវបានបុព្វបុរសខ្មែរយើងដាក់ឈ្មោះថាឃុំសែងគង់ ដោយកាលនោះវត្តមួយដែលស្ថិតនៅក្នុងទឹកដី ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ សព្វថ្ងៃបានចាប់ផ្ដើមកសាង ហើយបុព្វបុរសជំនាន់មុនបានធ្វើការជីកកាយយកដីដើម្បីកសាងវត្ត ហើយក៏ជីកឃើញគង់មួយដែលសាងពីលោហៈធាតុ ហើយបុព្វបុរសជំនាន់មុនបាននាំគ្នា សែងគង់នោះមករក្សាទុកនៅក្នុងទឹកដីឃុំសាន់គសព្វថ្ងៃ។ បន្ទាប់មកក៏បុព្វបុរសជំនាន់មុនដាក់ឈ្មោះ ឃុំសាន់គសព្វថ្ងៃ ថាឃុំសែងគង់ ដោយអស់កាលជាយូរមក មនុស្សពីមួយជំនាន់ទៅមួយជំនាន់បានហៅក្លាយថាឃុំសាន់គវិញ និងប្រើរហូតមកដល់សព្វថ្ងៃនេះ។

គ្មានឯកសារណាដែលបានចងក្រងអំពីប្រវត្តិឃុំសាន់គឡើយ តែប្រវត្តិខាងលើគ្រាន់ជាការស្រង់សម្ដីពីចាស់ៗ ដែលគាត់បានដឹងតៗគ្នាមក។

### ២.១.១. ស្ថានភាពភូមិសាស្ត្រនិងប្រជាសាស្ត្រ

❖ **ស្ថានភាពភូមិសាស្ត្រ**

ឃុំសាន់គ ជាឃុំមួយក្នុងចំណោមឃុំទាំង១១ ស្ថិតនៅប៉ែកខាងលិចនៃសាលាស្រុកកំពង់ស្វាយ និងមានចម្ងាយ១២គីឡូម៉ែត្រពីទីរួមស្រុក ដែលមានព្រំប្រទល់ខាងជើងទល់ឃុំដំរីស្លាប់ ខាងត្បូងទល់ឃុំកំពង់គោ ឃុំជាត់សណ្ដាយ ខាងកើតទល់ឃុំត្បែង ខាងលិចទល់និងឃុំចំណារក្រោមស្រុកស្ទោង ខេត្តកំពង់ធំ។ ឃុំមានផ្ទៃដីសរុប ២២,២១៩ហិកតា ក្នុងនោះផ្ទៃដីលំនៅដ្ឋានមាន៧០០ហិកតា ផ្ទៃដីស្រែមាន១៨,៥១៣ហិកតា ដីចំការ ៩០ ហិកតា និងផ្ទៃដីផ្សេងៗ(ដីព្រៃ បឹង )មាន២,៩៦០ហិកតា។ ឃុំសាន់គមាន១៤ភូមិ គឺភូមិអំពិល,ភូមិបល្ល័ង្ក,ភូមិវាល,ភូមិតាំងក្រូច,ភូមិសាន់គ(ក),ភូមិសារី,ភូមិសំពៅមាស,ភូមិសាន់គ(ខ),ភូមិប្រាសាទ,ភូមិជ័យ,ភូមិស្លែងខ្ពស់,ភូមិក្បិល,ភូមិក្រសាំង(ក)និងក្រសាំង(ខ)។[42]

❖ **ស្ថានភាពប្រជាសាស្ត្រ**

មានប្រជាពលរដ្ឋសរុបចំនួន១៨,៦៨០នាក់, ស្រី៩,៥៥២នាក់ គ្រួសារសរុប៣,៦៣៩គ្រួសារ ផ្ទះ៣,០២៧ខ្នង ប្រជាពលរដ្ឋ១៨ ឆ្នាំឡើងមានចំនួនសរុប ៩,៩៨២ នាក់ ស្រី ៥,២៥០ នាក់។ ប្រជាពលរដ្ឋមានឈ្មោះ ក្នុងបញ្ជីបោះឆ្នោតផ្លូវការក្នុងឆ្នាំ២០២០ មានចំនួន៨,៣២២នាក់ ,ស្រី៤,៥៧៦នាក់។ បើធៀបនិងប្រជាពលរដ្ឋអាយុ១៨ឡើងមាន៨៣,៣៧%។

---

[42] *ឯកសារស្ដីពីជីវប្រវត្តិនៃការកកើតឃុំសាន់គ។*

### ២.១.២. ស្ថានភាពសេដ្ឋកិច្ចនិងសង្គមកិច្ច

❖ **ស្ថានភាពសេដ្ឋកិច្ច**

ឃុំសាន់គ មាន ១៤ភូមិ មានប្រជាជនសរុប ១៩,៦៦៤នាក់, ស្រីមានចំនួន ៩,៧២៧នាក់, ដែលមានគ្រួសារសរុប ចំនួន ៣,៧០២គ្រួសារ ក្នុងនោះគ្រួសារដែលប្រកបមុខរបរកសិកម្មជាចម្បង(៨១,១០%) មានមុខរបរធ្វើសិប្បកម្មជាចម្បង(២,00%) គ្រួសារដែលមានសមាជិកមានមុខរបរសេវាកម្មជាចម្បងមានចំនួន ៣៤២គ្រួសារ ស្មើ (៩,៨0%)។ គ្រួសារដែលមានសមាជិកធ្វើការក្នុងក្របខ័ណ្ឌរដ្ឋមាន ២៦៤គ្រួសារ ស្មើ(៧,២១%) គ្រួសារមានសមាជិកជាបុគ្គលិកកម្មករនៅតាមសហគ្រាសឯកជន (៥,៥0%) ។ ចំនួនមនុស្សដែលចេញទៅរកស៊ីក្រៅស្រុកហើយមានមុខរបរច្បាស់លាស់(១,៥0%) អ្នកចេញទៅរកស៊ីក្រៅស្រុកដែលមិនដឹងមុខរបរពិតប្រាកដ មាន (0,២0%) ។[43]

- **កសិកម្ម៖** ប្រជាពលរដ្ឋមួយចំនួនមានការយល់ដឹងពីបច្ចេកទេសដំណាំស្រូវហើយចេះជ្រើសរើស ពូជសុទ្ធដែលមានទិន្នផលខ្ពស់ ធ្វើឱ្យជីវភាពរបស់ប្រជាពលរដ្ឋប្រសើរជាងមុន។
- **ដំណាំស្រូវ៖** នៅឆ្នាំ២០២៣ ផ្ទៃដីស្រូវវស្សាមានចំនួន ១១,៨៦៦ ហ.ត ទិន្នផលមធ្យម ពី ២ ត/ហាត ដល់ ៣ត/ហាត។ ផ្ទៃដីស្រូវរដូវប្រាំងមានចំនួន ៦,៦៤៧ហ/ត ទិន្នផលមធ្យមពី ៣,៥ហ/តដល់៤ហ/ត ហើយតម្លៃស្រូវនៅលើទីផ្សារលក់ចេញជាមធ្យមស្មើនឹង ៧០០រៀល ក្នុង/គីឡូក្រាម។ ចំពោះមុខរបរនេះមានកសិករជាច្រើនបានចាប់អារម្មណ៍ខ្ពស់ជាងមុនចំពោះ កម្មវិធីបង្កើនផលិតភាពកសិកម្មហើយជាមួយការចាប់អារម្មណ៍នេះប្រជាពលរដ្ឋក្នុងឃុំសាន់គមួយចំនួនមានគ្រឿងចក្រភ្ជួរដី(ត្រាក់ទ័រ៩៤គ្រឿង, គោយន្ត៣៨៧គ្រឿង) និងមានម៉ាស៊ីនបូមទឹក,ម៉ាស៊ីនច្រូតស្រូវ។ ថ្វីត្បិតតែមានការរីកចម្រើនបែបនេះក្តី តែចំពោះចំណេះដឹងរបស់ប្រជាពលរដ្ឋទៅលើការងារកសិកម្មនេះពួកគាត់មិនមានជំនាញគ្រប់គ្រាន់ទេពោល គឺនៅមានកម្រិត។
- **ការចិញ្ចឹមសត្វ៖** គ្រួសារចិញ្ចឹមសត្វគោ,ក្របី សរុប ៩១៦ គ្រួសារ (២៥,៤៣% នៃគ្រួសារមានមុខរបរកសិកម្មជាចម្បងចំនួន ២,១២៤ គ្រួសារ)។ សរុបចំនួន គោចិញ្ចឹមមាន ២,១២៨ ក្បាល និងក្របីចំនួន ២១៩ ក្បាល។ គ្រួសារចិញ្ចឹមជ្រូក ២០៥គ្រួសារ ចិញ្ចឹមលើលពី ៣ក្បាលឡើងទៅចំនួន ៣៦គ្រួសារ។ សរុបចំនួនជ្រូកបា មានចំនួន ៣២៣ក្បាល,ជ្រូកមេ មានចំនួន ១២៥ក្បាល។ ចិញ្ចឹមមាន់៧៨៤គ្រួសារ (២០,៥០%នៃចំនួនគ្រួសារសរុបក្នុងឃុំ) ក្នុងនោះមាន៤៥៨គ្រួសារដែលចិញ្ចឹមមាន់មេលើសពី ៣ក្បាល

[43] *សៀវភៅស្តីពីស្ថានភាពសេដ្ឋកិច្ចនិងសង្គមកិច្ចនៅឃុំសាន់គ។*

ឡើងទៅ។ ក្រៅពីនេះ ប្រជាពលរដ្ឋយើងមានចិញ្ចឹមទាយកសាច់ ទាយកពង និងចិញ្ចឹមក្ងានមួយចំនួន។ នៅតាមភូមិនីមួយៗភាគច្រើន មានពេទ្យសត្វភូមិដែលបានទទួលការបណ្តុះបណ្តាលជាបឋម ដើម្បីផ្តល់ប្រឹក្សាដល់ប្រជាពលរដ្ឋជួយចាក់ថ្នាំបង្ការ និងជួយព្យាបាលសត្វ។

- **គមនាគមន៍៖** ឃុំមានផ្លូវសំខាន់ៗចំនួន ៤៩ខ្សែ ដែលជាដង្ហើមសេដ្ឋកិច្ចដ៏ចាំបាច់សម្រាប់ជាមធ្យោបាយដឹកជញ្ជូនកសិផល និងធ្វើដំណើរ ក្នុងនោះមាន៖
  - ➢ ផ្លូវកៅស៊ូឆ្លងកាត់ឃុំមានចំនួន ០១ខ្សែ មានប្រវែង ១,២០០ម៉ែត
  - ➢ ផ្លូវលំក្រាលគ្រួសក្រហមចំនួន ០៩ខ្សែ មានប្រវែង ១៥,៧៤០ម៉ែត្រ
  - ➢ ផ្លូវលំដីសលើករួចចំនួន ០៨ខ្សែ មានប្រវែង ១៣,៥០០ម៉ែត្រ
  - ➢ ផ្លូវលំដីធម្មតាចំនួន ០៣ខ្សែ មានប្រវែង ៤,៥០០ម៉ែត្រ
- **អំពីប្រព័ន្ធធារាសាស្ត្រ៖** ឃុំសាន់គ មានប្រព័ន្ធប្រឡាយមេ ០១ខ្សែ (ប្រឡាយ ៣០កញ្ញា)តភ្ជាប់ពីឃុំដំរីស្លាប់មានប្រវែងជាង៨គីឡូម៉ែត្រ និងមានប្រព័ន្ធប្រឡាយរងចំនួន០៤ខ្សែមានប្រវែង១,៦៦០ម៉ែត្រព្រមទាំងមានប្រឡាយតូចៗដែលក្រុមកសិករបានធ្វើជាលក្ខណៈជាក្រុមសរុបចំនួន០៧កន្លែង និងអាងទឹកឯកជនដែលបានសាងសង់សម្រាប់ការស្រោចស្រពដំណាំស្រូវមានចំនួន ០៦កន្លែង។
- **សេវាកម្ម៖** ប្រព័ន្ធប្រឡាយមេ គឺមានគណៈកម្មការគ្រប់គ្រងទឹកសម្រាប់ក្រុមកសិករប្រើប្រាស់។

❖ ***ស្ថានភាពសង្គមកិច្ច***

- **ផ្នែកអប់រំ៖** ស្ថានភាពបុគ្គលិក ក្នុងឆ្នាំសិក្សា ២០២៣-២០២៤ នេះមានដូចតទៅ៖

➢ ទីតាំងសាលាបឋមសិក្សាមានចំនួន ១០ កន្លែង មានអគារ ១៧ ខ្នង ស្មើ ៧៥ បន្ទប់ និង១០០ថ្នាក់ ដែលមានបុគ្គលិកអប់រំចំនួន៥៩ នាក់ (ស្រី៣១នាក់) ដែលមានសិស្សសរុប ៣,៦៦៩ នាក់ ស្រី ១,៦១២ នាក់។

១. បុគ្គលិកមត្តេយ្យសិក្សា សរុប០២នាក់ ស្រី០២នាក់

២. បុគ្គលិកបឋមសិក្សា សរុប៦០នាក់ ស្រី៣២នាក់

➢ ទីតាំងសាលាអនុវិទ្យាល័យមានចំនួន០២កន្លែង មានអគារ០៤ខ្នងស្មើ១៧បន្ទប់និង១២ថ្នាក់ដែលមានបុគ្គលិកអប់រំចំនួន៣០នាក់(ស្រី១៥នាក់) ដែលមានសិស្សសរុប៥៩៩នាក់ ស្រី៣១៧នាក់។

➢ សាលារៀនសរុប២១សាលា ក្នុងនោះ៖

១. មត្តេយ្យសិក្សា សរុប០១សាលា មាន០១ថ្នាក់

២. បឋមសិក្សា សរុប១៧ សាលា៧៥ បន្ទប់ ស្មើ១០០ ថ្នាក់

៣. អនុវិទ្យាល័យ សរុប០២សាលា មាន០៤ខ្នង ១៧ បន្ទប់ ស្មើ ១២ ថ្នាក់

➢ សាលាមត្តេយ្យសិក្សាសហគមន៍៖ មានចំនួន០៥ កន្លែង មាន០៥ ថ្នាក់ ដោយមានបុគ្គលិកបង្រៀន០៥ នាក់ ស្រី០៥ នាក់ ដែលមានសិស្សសរុប៩៨ នាក់ ស្រី ៥០ នាក់។

- **ផ្នែកខាភិបាល**៖ នៅក្នុងឃុំសាន់គយើងខ្ញុំ មានមណ្ឌលសុខភាព០១កន្លែងដោយបានធ្វើការបម្រើសេវាសុខភាពជូនប្រជាពលរដ្ឋបានគ្រប់ម៉ោងធ្វើការ នៅមណ្ឌលសុខភាពបានទទួលសេវាល្អ។ ដើម្បីបម្រើសេវាសុខភាពជូនប្រជាពលរដ្ឋ ហើយឃុំបានយកចិត្តទុកដាក់ និងចុះផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋយល់ដឹងពីសុខភាពអនាម័យពីការហូបស្អាតផឹកស្អាត និងរស់នៅស្អាតព្រមទាំងជម្រុញឱ្យពួកគាត់ទៅទទួលសេវា និងពិនិត្យតាមដានសុខភាពជាប្រចាំ។ ចំណែកមរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ ០១ខែ ដោយឆ្មបបុរាណមាន ០០នាក់ និងចំនួនមរណភាពទារកក្នុងចន្លោះអាយុ ០-១ ខែដោយឆ្មបបុរាណចំនួន ០០នាក់ ចំនួនមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ (គិតពីអាយុ១ខែ ឡើងទៅ) មាន ០០នាក់។ កុមារដែលមានអាយុចន្លោះពី ៩-១២ខែ បានចាក់ថ្នាំបង្ការគ្រប់ចំនួន៨៨នាក់ ស្រី៤៦ នាក់ ស្មើនឹង១០០% ក្រៅពីនេះក៏នៅមានមរណភាពដោយបញ្ហាផ្សេងៗអាយុក្រោម១៨ឆ្នាំចំនួន០៣ នាក់។ ក្នុងនោះមរណភាពដោយជំងឺរបេងចំនួន ០០នាក់ មរណភាពបណ្ដាលមកពីលង់ទឹកចំនួន ០២ នាក់ ស្លាប់បណ្ដាលមកពីជំងឺអេដស៍ចំនួន០០នាក់ មរណភាពបណ្ដាលមកពីគ្រោះថ្នាក់ចរាចរណ៍ចំនួន ០១នាក់។

- **ការប្រើប្រាស់ទឹកស្អាត និងអនាម័យ**

➢ **ការប្រើប្រាស់ទឹកស្អាត**៖ ទូទាំងឃុំសាន់គ បច្ចុប្បន្នមានអណ្ដូងចម្រុះចំនួន២,៥៧៦គ្រួសារ មានអណ្ដូងចំនួន ២៧៨អណ្ដូង ក្នុងនោះមានអណ្ដូងស្នប់ជ្រៅចំនួន០៦ អណ្ដូង គ្រួសារប្រើប្រាស់ទឹកស្រះសហគមន៍ ទឹកបឹងត្រពាំង មានចំនួន១៧៦ គ្រួសារ, គ្រួសារប្រើប្រាស់ទឹកស្អាត និងចម្រោះទឹកស្អាតមានចំនួន ៨៥០ គ្រួសារ។

➢ **ការប្រើប្រាស់បង្គន់អនាម័យ**៖ ចំនួនបង្គន់អនាម័យសាងសង់ដោយខ្លួនឯង និងមានជួយឧបត្ថម្ភពីដៃគូរអភិវឌ្ឍន៍មានចំនួន១,៥៨៦ បង្គន់។ ជាមួយនេះដែរ បានធ្វើការអប់រំអំពីអនាម័យសុខភាព និងការថែទាំប្រើប្រាស់អណ្ដូង និងបង្គន់ដល់ប្រជាពលរដ្ឋ។

- **បញ្ហាយុវវ័យ**៖ នៅមានក្មេងទំនើងមួយចំនួន និងមួយចំនួនទៀតប្រើប្រាស់គ្រឿងញៀន ហើយការស្លៀកពាក់បែបសម័យខុសប្រពៃណីខ្មែរ និងប្រើប្រាស់សម្ភារៈនិយម។

- **សុខភាពបន្តពូជ៖** ឃុំបានធ្វើការផ្សព្វផ្សាយពីបញ្ហាសុខភាពបន្តពូជដល់ប្រជាពលរដ្ឋជារៀងរាល់ឆ្នាំ ដើម្បីឱ្យទៅទទួលសេវាសុខភាពពីមណ្ឌលសុខភាព ជាពិសេសស្ត្រីដែលទើបរៀបអាពាហ៍ពិពាហ៍រួច។
- **យេនឌ័រ៖** កាលនៅក្នុងអាណត្តិទី៥របស់ក្រុមប្រឹក្សាឃុំ បានធ្វើការបែងចែកមុខងារតួនាទីដល់ក្រុមប្រឹក្សាឃុំជាស្ត្រីដើម្បីបញ្ចេញសមត្ថភាព និងចំណេះដឹងក្នុងការបំពេញការងាររបស់ខ្លួនជាពិសេស សមាជិកក្រុមប្រឹក្សាឃុំជាស្ត្រីដែលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំដែលមានការងារច្រើនត្រូវធ្វើ ដូចជាការផ្សព្វផ្សាយពីសុខភាពបន្តពូជ សុខភាព និងអនាម័យការលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ,ជម្រុញមាតាបិតានាំកូនទៅរៀនអប់រំតាមខ្នងផ្ទះក្រុមម៉ែៗ។ ដូច្នេះឃុំមានគោលដៅដូចខាងក្រោម៖
  - ជម្រុញប្រជាពលរដ្ឋចូលរួមក្នុងកិច្ចប្រជុំឲ្យបានច្រើន
  - ជម្រុញស្ត្រីឱ្យមានការចូលរួមបញ្ចេញមតិយោបល់
  - ជម្រុញស្ត្រីឱ្យមានភាពអង់អាចក្លាហានក្នុងការសម្រេចចិត្តធ្វើអ្វីមួយ។

មិនតែប៉ុណ្ណោះនៅក្នុងរចនាសម្ព័ន្ធថ្នាក់ដឹកនាំភូមិ ក៏មានស្ត្រីជាអ្នកដឹកនាំផងដែរ។ ម្យ៉ាងវិញទៀតស្ត្រីមួយចំនួនមិនទាន់យល់អំពីតួនាទី និងភារកិច្ចរបស់ខ្លួននៅឡើយទេ។

- **ភាពក្រីក្រ៖** ប្រជាពលរដ្ឋមានជីវភាពក្រីក្រដោយសារមានកូនច្រើន ចំណាកស្រុក មិនមានមុខរបរច្បាស់លាស់ ហើយគ្រួសារក្រីក្រមួយចំនួនដែលមិនអាចកែលម្អជីវភាពរបស់ពួកគេបាន ដោយសារខ្វះចំណេះដឹងមានអំពើហិង្សាក្នុងគ្រួសារ មានមុខរបរមិនច្បាស់លាស់ កូនច្រើន និងគ្រួសារក្រីក្រមួយចំនួនទៀតបានកែលម្អជីវភាពខ្លួនដោយសារការខិតខំប្រឹងប្រែងរកស៊ី គ្មានអំពើហិង្សា ចូលរួមការងារសង្គម និងប្រកបមុខរបរដោយមានការបទបែនទៅតាមរដូវកាល។
- **សាសនា៖** នៅក្នុងឃុំសាន់គ មានវត្តចំនួន 5 ដោយវត្តនីមួយៗបានកសាងបន្ថែមទៀតមានធម្មទាន កសាងកុដិសម្រាប់ព្រះសង្ឃ និងទិញជាសម្ភារៈផ្សេងៗទៀតដែលធ្វើឱ្យមានការរីកចម្រើនជាងមុន។[44]

### ២.១.៣. ការគ្រប់គ្រងធនធានធម្មជាតិបរិស្ថាន និងការប្រែប្រួលអាកាសធាតុ

❖ **ស្ថានភាពនៃការគ្រប់គ្រងធនធានធម្មជាតិបរិស្ថាន៖**

[44] *សៀវភៅនិងឯកសារតម្កល់រយៈពេល៥ឆ្នាំរបស់ឃុំសាន់គ។*

- **ការប្រើប្រាស់ដីធ្លី៖** ប្រជាពលរដ្ឋបាននឹងកំពុងចាប់ប្រើប្រាស់ដីលំនៅដ្ឋាន និងដីកសិកម្ម ដោយស្របច្បាប់ គឺភូមិមួយចំនួនបានចាប់ផ្តើមធ្វើប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីជាផ្លូវការហើយ គឺទើបនឹងចាប់ផ្ញើឯកសារស្នើសុំទៅជំនាញជាលក្ខណៈជាប្រព័ន្ធ។
- **ធនធានធម្មជាតិ៖** ឃុំសាន់គ មានធនធានធម្មជាតិសំខាន់ៗដែលមានដូចជា ដីធ្លី ធនធានជលផល បឹង អូរ ស្ទឹងផ្សេងៗ ដែលជាសម្បត្តិធម្មជាតិ ស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនហើយ ប្រជាពលរដ្ឋពឹងផ្អែកលើធនធានទាំងនេះ សម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់។ បន្ថែមពីលើនេះទៀតគឺឃុំសាន់គ មានសហគមន៍នេសាទចំនួនពីរ (ទី១ សហគមន៍នេសាទសាមគ្គីខ្សែងខ្លែង-កក់ធំ និងទី២ សហគមន៍នេសាទសាមគ្គីអភិវឌ្ឍន៍បឹងស្ពុង) ដែលជាភ្នែកច្រមុះ និងជាក្តីរំពឹងក្នុងការបន្តនិរន្តរភាពពូជមច្ឆាជាតិ។
- **បរិស្ថាន៖** ជាពលរដ្ឋមានការយល់ដឹងប្រសើរជាងមុនពាក់ព័ន្ធនឹងបរិស្ថាន ចេះសម្អាតចេះថែរក្សាការពារបរិស្ថានបានល្អ និងយល់ដឹងពីសារៈសំខាន់នៃបរិស្ថាន។
- **ការប្រែប្រួលអាកាសធាតុ៖** នៅក្នុងឃុំ អាកាសធាតុមានការប្រែប្រួលភ្លៀងមិនទៀងទាត់ជួនមានទឹកជំនន់ ភាពរាំងស្ងួត សីតុណ្ហភាពឡើងខ្ពស់ កម្រិតទឹកភ្លៀងមិនទៀងទាត់ដែលបណ្តាលឱ្យប៉ះពាល់ដល់ការរស់នៅ និងប្រកបមុខរបរប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ជាពិសេសប៉ះពាល់ដល់សុខភាពរបស់ពួកគាត់។ ម្យ៉ាងទៀតឃុំបានផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋចេះរស់នៅដោយបន្សុំទៅនឹងការប្រែប្រួលអាកាសធាតុ មានការផ្គត់ផ្គង់ទឹកសម្រាប់សហគមន៍ គ្រួសារ ផ្នែកកសិកម្ម ការដាំកូនឈើឡើងវិញ។

### ២.១.៤. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

❖ ***ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល***

- **អភិបាលកិច្ច៖** ឃុំបានធ្វើការដឹកនាំការងារប្រកបដោយប្រសិទ្ធិភាពតម្លាភាព និងមានគណនេយ្យភាពចំពោះការងារនឹងប្រជាពលរដ្ឋរបស់ខ្លួន មិនតែប៉ុណ្ណោះឃុំបានធ្វើការបែងចែកការគ្រប់គ្រងការងារទៅតាមទីតាំង និងមណ្ឌលសំខាន់ៗ ដើម្បីងាយស្រួលគ្រប់គ្រង និងដឹកនាំចាត់ចែងការងារឱ្យបានល្អ និងទាន់តាមតម្រូវការរបស់ថ្នាក់លើ។
- **ការគ្រប់គ្រងស្ថិតិ ៖** រាល់លិខិតបទដ្ឋាន ឃុំបានប្រកាស ឬបិទផ្សាយជាបន្តបន្ទាប់។ ចំណែកឯការងារអត្រានុកូលដ្ឋាន គឺប្រជាពលរដ្ឋខ្វះការយកចិត្តទុកដាក់នៅឡើយ លុះត្រាមានការចាំបាច់ទើបទៅសាលាឃុំ ហើយឃុំបានផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋមកចុះបញ្ជីអត្រានុកូលដ្ឋាននៅសាលាឃុំ។

ការចុះបញ្ជីអត្រានុកូលដ្ឋានឆ្នាំ ២០២២

- ចុះសំបុត្រកំណើត ចំនួន២៤៥ នាក់
- ចុះលិខិតបញ្ជាក់កំណើត ចំនួន៨៧៥ នាក់
- ចុះលិខិតអាពាហ៍ពិពាហ៍ ចំនួន៣៧១ នាក់
- ចុះលិខិតមរណភាព ចំនួន៤៦ នាក់

- **ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**

ចំពោះបញ្ហាសន្តិសុខមិនសូវចោទជាបញ្ហាប៉ុន្មានទេ ដោយឃុំបានរៀបចំកម្លាំងប្រជាការពារតាមភូមិរួមសហការណ៍ជាមួយ កម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំចុះល្បាតតាមភូមិពេលមានហេតុការណ៍អ្វីកើតឡើងរាយការណ៍បានទាន់ពេលវេលា។ ម្យ៉ាងទៀតឃុំបានផ្សព្វផ្សាយគោលនយោបាយភូមិឃុំមានសុវត្ថិភាពទាំង ៩ចំណុចនៅតាមភូមិក្នុងឃុំ។

## ២.២ ការរៀបចំ និងការប្រព្រឹត្តនៃរដ្ឋបាលឃុំសាន់គ

### ២.២.១ រចនាសម្ព័ន្ធ




ដើម្បីបម្រើសេវាដល់វិស័យសាធារណៈឱ្យកាន់តែងាយស្រួល និងមានប្រសិទ្ធភាពតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំសាន់គបានធ្វើការបែងចែក និងរៀបចំសមាសភាពក្រុមប្រឹក្សាឃុំដូចខាងក្រោមៈ

**សមាភាពក្រុមប្រក្សាឃុំសាន់គមាន ចំនួន ១១រូប រួមមានៈ**[45]

១. លោក　ជូ សួន　ប្រធានក្រុមប្រឹក្សាឃុំ និងជាមេឃុំ

២. លោក　ជីម ស៊ុនលី　ជំទប់ទី១

៣. លោក　ខ្វៃ ឆាំ　ជំទប់ទី២

---

[45] *ប្រកាស លេខ២៤៨១៥ ប្រ.ក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃស្តីពីការសម្រេចទទួលស្គាល់សមាសភាពជាប្រធានក្រុមប្រឹក្សាឃុំ សមាជិកក្រុមប្រឹក្សាឃុំ ឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។*

៤. លោក សៅ ផ្លយ សមាជិកក្រុមប្រឹក្សាឃុំ

៥. លោក ភិន ឃាត សមាជិកក្រុមប្រឹក្សាឃុំ

៦. លោក ទូច ធារ័ត្ន សមាជិកក្រុមប្រឹក្សាឃុំ

៧. លោក ហ៊ឹម សម្ព័ស សមាជិកក្រុមប្រឹក្សាឃុំ

៨. លោក រ័ត្ន ប៉ូលីន សមាជិកក្រុមប្រឹក្សាឃុំ

៩. លោក ហ៊ុត ហ៊ត សមាជិកក្រុមប្រឹក្សាឃុំ

១០. លោក ឈិន ឆង សមាជិកក្រុមប្រឹក្សាឃុំ

១១. លោក ឌី គក់ សមាជិកក្រុមប្រឹក្សាឃុំ

- **នៅឃុំសាន់គមានស្មៀនចំនួន ០១រូប គឺលោក ជា ណារ៉ុង**

១. កញ្ញា ឈួន វលក្ខណ៍ ជំនួយការហិរញ្ញវត្ថុ

២. លោក ឈាន លីហួត ជំនួយការរដ្ឋបាលឃុំ

៣. លោក ឆេង ដេត មេភូមិអំពិល

៤. លោក ហួន យ៉ន មេភូមិបល្ល័ង្គ

៥. លោក មាន សុភ័ន មេភូមិវាល

៦. លោក ភិន សុង មេភូមិតាំងក្រូច

៧. លោក លីម ប៊ុនថុល មេភូមិសាន់គ(ក)

៨. លោក ភិន ផល មេភូមិសារី

៩. លោក សូ សេងហន មេភូមិសំពៅមាស

១០. លោក អ៊ឹម រ៉ន មេភូមិសាន់គ(ខ)

១១. លោក ហេង ហយ មេភូមិប្រាសាទ

១២. លោក ប៊ុត តៃ មេភូមិជ័យ

១៣. លោក ធាវ ធឿន មេភូមិស្លែងខ្ពស់

១៤. លោក ខឹម ហ៊ាន់ មេភូមិក្បិល

១៥. លោក សឿន ឈាង មេភូមិក្រសាំង(ក)

១៦. លោក ស៊ុន សៅ មេភូមិក្រសាំង(ខ)

### ២.២.២. ការបង្កើតគណៈកម្មាធិការឃុំ

នៅក្នុងអាណត្តិទី៥ ក្រុមប្រឹក្សាឃុំសាន់គបានបង្កើតគណៈកម្មាធិការចំនួន០៤ និងគណៈកម្មការមួយចំនួន០២ដូចខាងក្រោម៖

- **គណៈកម្មាធិការកសាងផែនការនិងថវិការ**

គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំសាន់គ ដែលមានសមាសភាពដូចខាងក្រោម៖ [46]

| | | | |
|---|---|---|---|
| ១. | លោក ជួ សួន | មេឃុំ | ជាប្រធាន |
| ២. | លោក ជឹម ស៊ុនលី | ជំទប់ទី១ | ជាសមាជិកអចិន្ត្រៃយ៍ |
| ៣. | លោក ខ្វៃ ឆាំ | ជំទប់ទី២ | ជាសមាជិក |
| ៤. | លោក សៅ ផ្លួយ | សមាជិកក្រុមប្រឹក្សា | ជាសមាជិក |
| ៥. | លោក ភិន ឃាត | សមាជិកក្រុមប្រឹក្សា | ជាសមាជិក |
| ៦. | លោក ទូច ធារ័ត្ន | សមាជិកក្រុមប្រឹក្សា | ជាសមាជិក |
| ៧. | លោក ហ៊ឹម សម្ផស | សមាជិកក្រុមប្រឹក្សា | ជាសមាជិក |
| ៨. | លាក ធាតុ កុសល | សមាជិកក្រុមប្រឹក្សា | ជាសមាជិក |
| ៩. | លោក ហ៊ុត ហ៊ត | សមាជិកក្រុមប្រឹក្សា | ជាសមាជិក |
| ១០. | លោក ឈិន ឆង | សមាជិកក្រុមប្រឹក្សា | ជាសមាជិក |
| ១១. | លោក ឌី គក់ | សមាជិកក្រុមប្រឹក្សា | ជាសមាជិក |
| ១២. | លោក ជា ណារ៉ុង | ជាលេខាធិការ | ជាសមាជិក |

[46] *សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំសាន់គ,លេខ២០០៦/២០២២/ស.ស.រ, ១២ កក្កដា ២០២២, ប្រការ១។*

| | | | |
|---|---|---|---|
| ១៣. | លោកស្រី ទូច ធារ័ត្ន | ទទួលបន្ទុកកិច្ចការនារីនិងកុមា | ជាសមាជិក |
| ១៤. | លោក លោកស្រី | មេភូមិទាំង១៤ ភូមិ | ជាសមាជិក |
| ១៥. | លោក លោកស្រី | អនុភូមិទាំង១៤ ភូមិ | ជាសមាជិក |
| ១៦. | លោក សន សឿន | តំណាងប្រជាពលរដ្ឋ | ជាសមាជិក |
| ១៧. | លោក ភិន ខាយ | តំណាងប្រជាពលរដ្ឋ | ជាសមាជិក |

គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំសាន់គ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ជួយមេឃុំក្នុងការរៀបចំកសាងផែនការអភិវឌ្ឍន៍ឃុំ កម្មវិធីវិនិយោគឃុំនិងថវិកាប្រចាំឆ្នាំ
- ត្រូវអនុវត្តវិធីសាស្ត្រ កសាងផែនការអភិវឌ្ឍន៍ឃុំ កម្មវិធីវិនិយោគឃុំ និងគម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំតាមអភិក្រមមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ
- ជួយមេឃុំក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ឃុំ
- ធ្វើរបាយការណ៍ រាយការណ៍ជូនលោកប្រធាន និងជូនអង្គប្រជុំក្រុមប្រឹក្សាឃុំ។[47]

❖ **គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសាន់គ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. | លោក ជួ សួន | មេឃុំ | ជាប្រធាន |
| ២. | លោក ខ្វៃ ឆាំ | ជំទប់ទី២ | ជាសមាជិក |
| ៣. | លោកស្រី ទូច ធារ័ត្ន | អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ | ជាសមាជិក |
| ៤. | លោក ហ៊ុត ហ៊ត | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៥. | លោក ជា ណារ៉ុង | ស្មៀនឃុំ | ជាសមាជិក |
| ៦. | លោក គៀត ទៀង | ប្រធានមណ្ឌលសុខភាពឃុំសាន់គ | ជាសមាជិក |

[47] *សេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសាន់គលេខ០០៦/២០២២/ស.ស.រ, ១២កក្កដា ២០២២, ប្រការ១។*

| | | | |
|---|---|---|---|
| ៧. | លោក សូ សារ៉ន | នាយនគរបាលរដ្ឋបាលឃុំសាន់គ | ជាសមាជិក |
| ៨. | លោក ឈូ ម៉ៅ | ប្រធានកម្រង | ជាសមាជិក |
| ៩. | លោក លោកស្រី | មេភូមិទាំង១៤ ភូមិ | ជាសមាជិក |
| ១០. | លោក លោកស្រី | អនុភូមិទាំង១៤ ភូមិ | ជាសមាជិក |
| ១១. | លោកស្រី រ័ត្ន ប៉ូ លីន | តំណាងសមាគមមនុស្សចាស់ | ជាសមាជិក |
| ១២. | លោក យាន យន់ | តំណាងជនពិការ | ជាសមាជិក |
| ១៣. | កញ្ញា ឈួន វលក្ខណ៍ | ជំនួយការសេវាសង្គម | ជាលេខាធិការ |

គណៈកម្មការគ្រប់គ្រងគម្រោងឃុំ មានតួនាទី និងភារៈកិច្ចដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គណកម្មាធិការជូនក្រុមប្រឹក្សាឃុំអនុម័ត។
- ផ្តល់ប្រឹក្សាយោបល់ និងជួយក្រុមប្រឹក្សាឃុំ និងមេឃុំចំពោះការងារពាក់ព័ន្ធកិច្ចការនារី និងកុមារនៅឃុំ។
- អប់រំដល់ប្រជាពលរដ្ឋអោយយល់ដឹងអំពីច្បាប់គោលនយោបាយនានារបស់រដ្ឋនៅឃុំ និងបំផុសចលនាសហគមន៍លើវិស័យសុខភាពអប់រំ កិច្ចការពារ និងការអភិវឌ្ឍកុមារព្រមទាំងការចុះបញ្ជីអត្រានុកូលដ្ឋានជូនទារក និងកុមារ។
- ទាក់ទាញការគាំទ្រដើម្បីឱ្យនារីបានចូលរួមធ្វើសេចក្តីសម្រេចលើការអភិវឌ្ឍនៅមូលដ្ឋានឃុំ។
- បង្កើន និងពង្រឹងនូវការប្រាស្រ័យទាក់ទងកិច្ចសហការណ៍ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្ម និងអ្នកភូមិដែលធ្វើសកម្មភាពជួយនារី និងកុមារនៅឃុំរបស់ខ្លួន។
- ជួយក្រុមប្រឹក្សាឃុំ ក្នុងការប្រមូលវិភាគទិន្នន័យពាក់ព័ន្ធ និងបញ្ហា និងតម្រូវការរបស់នារី និងកុមារ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ និងកម្មវិធីវិនិយោគឃុំ។
- ចូលរួមអនុវត្តពិនិត្យតាមដាន និងវាយតម្លៃផែនការសកម្មភាពឃុំ ពាក់ព័ន្ធស្ថានភាពនារី និងកុមារ

- តាមដានស្ថានភាពនារី និងកុមារនៅក្នុងឃុំ និងធ្វើរបាយការណ៍ទៀងទាត់ជូនក្រុមប្រឹក្សាឃុំព្រម ទាំងដាក់ បញ្ចូលក្នុងរបាយការណ៍ឃុំ។

❖ **គណៈកម្មាធិការយេនឌ័រ**

គណៈកម្មាធិការយេនឌ័រ ឃុំសាន់គ ដែលមានសមាសភាពដូចខាងក្រោម៖[48]

| | | | | |
|---|---|---|---|---|
| ១. | លោក | ជូ សួន | មេឃុំ | ជាប្រធាន |
| ២. | លោក | ខ្វៃ ឆាំ | ជំទប់ទី២ | ជាអនុប្រធាននិងជាសមាជិកអចន្ត្រៃយ៍ |
| ៣. | លោក | សូ សារ៉ន | នាយប៉ុស្តិ៍នគបាលឃុំ | ជាសមាជិក |
| ៤. | លោក | ឈូ ម៉ៅ | ប្រធានកម្រង | ជាសមាជិក |
| ៥. | លោក | គាត ទៀត | ប្រធានមណ្ឌលសុខភា | ជាសមាជិក |
| ៦. | លោក | លោកស្រី | មេភូមិគ្រប់ភូមិ | ជាសមាជិក |
| ៧. | លោក | ជា ណារ៉ុង | ស្មៀនឃុំ | ជាលេខាធិការ |

គណៈកម្មាធិការនេះមានភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម ៖

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គណៈកម្មាធិការជូនក្រុមប្រឹក្សាឃុំអនុម័ត
- ផ្តល់ប្រឹក្សាយោបល់ និងជួយក្រុមប្រឹក្សាឃុំ និងមេឃុំចំពោះការងារពាក់ព័ន្ធកិច្ចការងារយេនឌ័រ
- អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យបានយល់ដឹងអំពីច្បាប់ គោលនយោបាយនានា របស់រដ្ឋពាក់ព័ន្ធ យេនឌ័រនៅឃុំ និងបំផុសចលនាសហគមន៍លើវិស័យសុខភាព អប់រំ កិច្ចការពារ និងអភិវឌ្ឍន៍យេនឌ័រ
- ទាក់ទាញការគាំទ្រដើម្បីឱ្យបុរសនារីបានចូលរួមធ្វើសេចក្តីសម្រេចចិត្តលើការអភិវឌ្ឍនៅមូលដ្ឋានឃុំ
- បង្កើន និងពង្រឹងនូវការប្រាស្រ័យទាក់ទងកិច្ចសហការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្ម និងអ្នកភូមិដែលធ្វើសកម្មភាពជួយការងារយេនឌ័រនៅក្នុងឃុំរបស់ខ្លួន

[48] *សេចក្តីសម្រេចស្តីពីការតែងតាំងគណៈកម្មាធិការយេនឌ័រ,លេខ០០៨/២០២២/ស.ស.រ, ១២ កក្កដា ២០២២, ប្រការ១។*

- ជួយក្រុមប្រឹក្សាឃុំក្នុងការប្រមូលវិភាគព័ត៌មាន ទិន្នន័យពាក់ព័ន្ធ និងបញ្ហា និងតម្រូវការរបស់នារី និងកុមារដើម្បីដាក់បញ្ចូល ទៅក្នុងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគឃុំ
- ចូលរួមអនុវត្តន៍ និងពិនិត្យតាមដាន និងវាយតម្លៃផែនការសកម្មភាពឃុំពាក់ព័ន្ធស្ថានភាពយេនឌ័រ
- តាមដានស្ថានភាពយេនឌ័រក្នុងឃុំ និងធ្វើរបាយការណ៍ទៀងទាត់ជូនក្រុមប្រឹក្សាឃុំ ព្រមទាំងដាក់បញ្ចូលក្នុងរបាយការណ៍ឃុំ
- មេឃុំដែលជាប្រធានគណៈកម្មាធិការ ត្រូវមានការទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំរបស់ខ្លួន
- គណៈកម្មាធិការត្រូវសម្របសម្រួល និងសហការយ៉ាងជិតស្និទ្ធជាមួយអ្នកផ្តល់សេវាកម្មនានាផ្នែកសង្គមកិច្ច
- អ្នកស្ម័គ្រភូមិ និងសហគមន៍នៅក្នុងឃុំដើម្បីបំពេញតួនាទី ភារកិច្ចខាងលើឱ្យមានប្រសិទ្ធភាព។

❖ **គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំសាន់គ ដូចមានរាយនាមខាងក្រោម ៖[49]

| | | | | |
|---|---|---|---|---|
| ១. លោក | ជួ សួន | ប្រធានក្រុមប្រឹក្សា | ប្រធាន គ.គ.ម.យ | |
| ២. លោក | ជីម ស៊ុនលី | ជំទប់ទី១ | អនុប្រធាន គ.គ.ម.យ | |
| ៣. លោក | ឆាំ ខ្វាំ | ជំទប់ទី២ | ទទួលបន្ទុកកិច្ចការនារីនិងកុមា | សមាជិក |
| ៤. លោក | សៅ ផ្លួយ | សមាជិកក្រុមប្រឹក្សាឃុំ | សមាជិក | |
| ៥. លោក | ភិន ឃាត | សមាជិកក្រុមប្រឹក្សាឃុំ | សមាជិក | |
| ៦. លោក | ទូច ធារ័ត្ន | សមាជិកក្រុមប្រឹក្សាឃុំ | សមាជិក | |
| ៧. លោក | ហ៊ុត ហ៊ត | សមាជិកក្រុមប្រឹក្សាឃុំ | សមាជិក | |
| ៨. លោក | ហ៊ឹម សម្ផស | សមាជិកក្រុមប្រឹក្សាឃុំ | សមាជិក | |
| ៩. លោក | ជា ណារ៉ុង | លេខាអចិន្ត្រៃ | | |

[49] *សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំសាន់គ,លេខ០០២/២០២២/ស.ស.រ, ១២ កក្កដា ២០២២, ប្រការ១។*

១០. លោក សូ សារ៉ន នាយកប៉ុស្តិ៍នគបាលរដ្ឋបាល សមាជិក

១១. លោក ជង ចាយ នាយកកម្រង សមាជិក

១២. លោក គាត ទៀង ប្រធានមណ្ឌលសុខភាព សមាជិក

១៣. លោក លាង សៀង ភ្នាក់ងារសុខភាពសត្វ សមាជិក

១៤. លោក ឈាន លីហួ អ្នកស្មគ្រចិត្ត និងយុវជនកាកបាទក្រហម សមាជិក

១៥.លោក ភឹម ភន ព្រឹទ្ធាចារ្យ សមាជិក

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

អនុវត្តគោលនយោបាយដែលទាក់ទងទៅនឹងការគ្រប់គ្រងគ្រោះមហន្តរាយ

- កសាងផែនការត្រៀមបង្ការកាត់បន្ថយគ្រោះថ្នាក់ ត្រៀមរៀបចំដើម្បីការពារអាយុជីវិតមនុស្សសត្វ
- សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព ផលិតផលកសិកម្ម សេវាសាធារណៈ បរិស្ថាន និងអនុវត្តដើម្បីកាត់បន្ថយគ្រោះភ័យនៅពេលមានមុខសញ្ញាគ្រោះថ្នាក់ពីធម្មជាតិ និងពីមនុស្សកើតឡើង
- សម្របសម្រួលផែនការខាងលើជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក
- រៀបចំបង្កើត និងគ្រប់គ្រងទីសុវត្ថិភាព
- រៀបចំគោលការណ៍ណែនាំ អនុវត្ត និងគាំទ្រសកម្មភាពគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍
- ជាសេនាធិការរបស់គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ក្នុងការងារកាត់បន្ថយគ្រោះមហន្តរាយ និងផ្តល់យោបល់ពីសកម្មភាពរបស់ស្ថាប័នពាក់ព័ន្ធ សមាគមជាតិ ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ដែលរួមចំណែកក្នុងការកាត់បន្ថយគ្រោះមហន្តរាយ និងភាពងាយរងគ្រោះនៅមុនពេលក្នុងពេល និងក្រោយពេលមានគ្រោះមហន្តរាយ។

រៀបចំចងក្រងក្រុមប្រតិបត្តិការសម្រាប់ធ្វើសកម្មភាពរួមមាន៖

១. ក្រុមសន្តិសុខ និងរុករកសង្គ្រោះ

២. ក្រុមសុខភាព និងអនាម័យ

៣. ក្រុមឆ្លើយតប និងពត៌មាន

- ជ្រើសរើសអ្នកស្ម័គ្រចិត្តចូលរួមបំពេញការងារក្នុងក្រុមប្រតិបត្តិទាំង ០៣ខាងលើ។
- រៀបចំកម្មវិធីបណ្តុះបណ្តាលដល់ក្រុមប្រតិបត្តិការទាំង ០៣ លើជំនាញទទួលខុសត្រូវព្រមទាំងអប់រំ ផ្សព្វផ្សាយការយល់ដឹងជាសាធារណៈដល់មូលដ្ឋានសហគមន៍ពីគ្រោះភ័យនៃគ្រោះមហន្តរាយមុខ សញ្ញាគ្រោះថ្នាក់ វិធានការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ។
- លើកគម្រោងប្រើប្រាស់ថវិកា សម្ភារៈបរិក្ខារ មធ្យោបាយប្រើប្រាស់ និងកម្លាំងសម្រាប់ធ្វើសកម្មភាព តាមដំណាក់នីមួយៗ នៃការគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីដាក់ស្នើតាមលំដាប់ថ្នាក់របស់ខ្លួន និង អង្គការ នានា។
- ធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ខណ្ឌ អំពីស្ថានភាព ដែលនឹងអាច កើតមាន និងកើតមានមុខសញ្ញាគ្រោះថ្នាក់នៅមូលដ្ឋានសហគមន៍របស់ខ្លួន។
- រាយការណ៍អំពីសភាពការណ៍គ្រោះមហន្តរាយជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក។
- ផ្តល់ព័ត៌មានដល់ថ្នាក់លើរបស់ខ្លួនអំពីការកើតឡើង នូវមុខសញ្ញាគ្រោះថ្នាក់ឱ្យបានលឿន និង បន្ទាន់បំផុត។
- ធ្វើការប្រជុំ១ខែម្តង ជាទៀងទាត់ ដើម្បីត្រួតពិនិត្យសកម្មភាពរបស់ក្រុមទាំង ០៣ និងដោះស្រាយ បញ្ហាដែលកើតមានរបស់ក្រុមទាំង ០៣ តាមការកោះអញ្ជើញរបស់ប្រធាន និងក្នុងលក្ខណៈមាន គ្រោះអាសន្ន ត្រូវមានការកោះអញ្ជើញប្រជុំបន្ទាន់។

❖ **គណៈកម្មការលទ្ធកម្ម**

គណៈកម្មការលទ្ធកម្មឃុំសាន់គ ដែលមានសមាសភាពដូចខាងក្រោម ៖[50]

| | | | |
|---|---|---|---|
| ១. លោក | ជួ សួន | មេឃុំ | ជាប្រធាន |
| ២. លោក | ជឹម ស៊ុនលី | ជំទប់ទី១ | ជាសមាជិក |
| ៣. លោក | ភិន យាគ | សមាជិកក្រុមប្រឹក្សាឃុំជា | សមាជិក |
| ៤. លោក | ជា ណារ៉ុង | ស្មៀនឃុំ | ជាលេខាធិការ |

[50] *សេចក្តីសម្រេចស្តីពីការតែងតាំងគណៈកម្មការលទ្ធកម្មឃុំសាន់គ,លេខ០០៧/២០២២/ស.ស.រ, ១២ កក្កដា ២០២២, ប្រការ១។*

គណៈកម្មការលទ្ធកម្មឃុំមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំរបាយការណ៍ដេញថ្លៃគម្រោង និងព័ត៌មានដេញថ្លៃគម្រោងកិច្ចសន្យាជូនទីចាត់ការផែនការនិងវិនិយោគខេត្តបន្ទាប់ពីដេញថ្លៃរួច
- ជ្រើសរើសអ្នកម៉ៅការ ឬអ្នកផ្គត់ផ្គង់ ទៅតាមលទ្ធកម្មនៃការប្រជុំដេញថ្លៃ
- ឯកភាពលើផែនការ ការងាររបស់អ្នកទទួលការ
- ចុះកិច្ចសន្យាគម្រោង ជាមួយអ្នកទទួលការ
- តាមដានអ្នកទទួលការ អនុវត្តកិច្ចសន្យាជាប្រចាំ
- ត្រូវធ្វើរបាយការណ៍ ការងារដែលអ្នកទទួលការអនុវត្តបាន ជូនអង្គប្រជុំក្រុមប្រឹក្សាឃុំ
- ត្រូវរៀបចំកិច្ចប្រជុំគណៈកម្មការលទ្ធកម្ម ដើម្បីធ្វើការវាយតម្លៃលើគម្រោងអនុវត្តបាន
- ប្រជុំចេញអាណត្តិ បើកប្រាក់ជូនអ្នកម៉ៅការ។

❖ **គណៈកម្មការ ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ**

គណៈកម្មការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការដែលមានសមាសភាពដូចខាងក្រោម៖[51]

| | | | |
|---|---|---|---|
| ១. លោក | ជួ សួន | មេឃុំ | ជាប្រធាន |
| ២. លោក | ជឹម ស៊ុនលី | ជំទប់ទី១ | ជាសមាជិក |
| ៣. លោក | ខ្វៃ ឆាំ | ជំទប់ទី២ | ជាសមាជិក |
| ៤. លោក | សៅ ផ្លយ | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៥. លោក | ភិន ឃាគ | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៦. លោកស្រី | ទូច ធារ័ត្ន | អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ | ជាសមាជិក |
| ៧. លោក | លោកស្រី | មេភូមិទាំង១៤ភូមិ | ជាសមាជិក |
| ៨. លោក | សន សឿន | ប្រជាពលរដ្ឋ | ជាសមាជិក |

[51] *សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការឃុំសាន់គ,លេខ០០៥/២០២២/ស.ស.រ, ១២ កក្កដា ២០២២, ប្រការ១។*

៩. លោក ភិន ខាយ ប្រជាពលរដ្ឋ ជាសមាជិក

គណៈកម្មការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការឃុំសាន់គមានតួនាទី និងភារកិច្ចដូចខាងក្រោមៈ

- ផ្សព្វផ្សាយជូនដល់ប្រជាពលរដ្ឋឱ្យយល់ជ្រួលជ្រាបរាល់លិខិតបទដ្ឋាននានាដែលពាក់ព័ន្ធ និងទំនាស់។
- ជួយកិច្ចការឃុំក្នុងការប្រមូលព័ត៌មានពាក់ព័ន្ធ និងផលប្រយោជន៍ ព្រមទាំងពិនិត្យតាមដានការអនុវត្តសកម្មភាពដែលពាក់ព័ន្ធ និងទំនាស់។
- ពង្រឹងនូវការប្រាស្រ័យទាក់ទងកិច្ចសហការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាឃុំ និងអ្នកភូមិដែលធ្វើសកម្មភាព។
- ធ្វើរបាយការណ៍ទៀងទាត់ រាយការណ៍ជូនលោកមេឃុំ និងជូនអង្គប្រជុំក្រុមប្រឹក្សាឃុំពាក់ព័ន្ធការងាររបស់គណៈកម្មការដោះស្រាយទំនាស់។

### ២.២.៣. តួនាទីនិងភារកិច្ច

❖ **ប្រធានក្រុមប្រឹក្សាឃុំ**

ឃុំសង្កាត់នីមួយត្រូវមានក្រុមប្រឹក្សាមួយហៅថា ក្រុមប្រឹក្សាឃុំសង្កាត់។ ក្រុមប្រឹក្សាឃុំជាអង្គការដំណាងឱ្យប្រជាពលរដ្ឋក្នុងឃុំសង្កាត់របស់ខ្លួន និងមានបេសកម្មបម្រើផលប្រយោជន៍ទូទៅនៅក្នុងឃុំសង្កាត់របស់ខ្លួន។ ក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវជ្រើសឡើងតាមការបោះឆ្នោតដោយប្រជាពលរដ្ឋនៅឃុំសង្កាត់របស់ខ្លួនស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់។ ប្រធានក្រុមប្រឹក្សាឃុំសង្កាត់មានតួនាទីភាកិច្ចដូចតទៅៈ[52]

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំសង្កាត់របស់ខ្លួន
- ធានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំសង្កាត់យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ធានាឱ្យកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំរបស់ខ្លួនដំណើរការបានយ៉ាងត្រឹមត្រូវទៅតាមវិធាន និងបទបញ្ជាដូចបានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំសង្កាត់ និងបទប្បញ្ញត្តិដូចមានចែងនៅក្នុងមាត្រា ២៣ នៃច្បាប់នេះ
- រក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ។

[52] *មាត្រា១៣, ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ ២០០១*

❖ **មេឃុំ**

មេឃុំចៅសង្កាត់បំពេញតួនាទីភារកិច្ចដូចខាងក្រោម៖[53]

- អនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អនុវត្តនូវបទប្បញ្ញត្តិ និងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំសង្កាត់
- ធ្វើសេចក្ដីរាយការណ៍អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំ សង្កាត់ របស់ខ្លួនយ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ផ្ដល់យោបល់ផ្សេងៗនិងជួយដល់ក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការរៀបចំផែនការហិរញ្ញវត្ថុ និងក្នុងការចាត់ចែងអនុវត្តនូវតួនាទី មុខងារ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាឃុំសង្កាត់ព្រមទាំងកិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាឃុំសង្កាត់របស់ខ្លួនប្រគល់ឱ្យ។

❖ **ជំទប់ទី១និងជំទប់ទី២**

ជំទប់ ឬចៅសង្កាត់រងជាជំនួយការរបស់មេឃុំ ចៅសង្កាត់ក្នុងការអនុវត្តភារកិច្ច ដែលមេឃុំ ចៅសង្កាត់ប្រគល់ឱ្យ និងជំនួសមេឃុំចៅសង្កាត់ទៅតាមឋានានុក្រមនៃជំទប់ ឬចៅសង្កាត់រង នៅពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន។ ជំទប់ ឬចៅសង្កាត់រង ត្រូវធ្វើការបែងចែកការកិច្ចដូចខាងក្រោម៖[54]

- ជំទប់ទី១ឬចៅសង្កាត់រងទី១ ៖ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ជំទប់ទី២ ឬចៅសង្កាត់រងទី២ ៖ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈ និងសណ្ដាប់ធ្នាប់សាធារណៈ។[55]

មេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែកខាង លើនេះដល់ជំទប់ ឬចៅសង្កាត់រងរបស់ខ្លួន ។

❖ **មេភូមិ**

ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់ ក្រុមប្រឹក្សា ឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់ សម្រាប់ភូមិនីមួយៗចំណុះឃុំសង្កាត់របស់ខ្លួន។ មេភូមិត្រូវរៀបចំចាត់តាំងឱ្យមានអនុប្រធានមួយរូបនឹងសមាជិកមួយរូបជា ជំនួយការ។ មេភូមិមានភារកិច្ច :

---

*[53] មាត្រា៣៩, ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ ២០០១*

*[54] មាត្រា ៣៩, ច្បាប់ស្ដីពីការគគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់។*

*[55] មាត្រា ៤០, ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់២០០១។*

- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ ប្រគល់ឱ្យដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ។
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន។
- ស្នើសុំយោបល់នៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដើម្បីចាត់ចែងនឹងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំបន្ថែមអំពីរបៀបរបបធ្វើការងារ និងភារកិច្ចរបស់ភូមិឱ្យបានសមស្រប

### ២.៣. ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ឃុំសាន់គ

ឃុំមានគណៈកម្មការគ្រប់គ្រងហិរញ្ញវត្ថុរបស់ឃុំបានត្រឹមត្រូវ ព្រមទាំងលើកផែនការអនុវត្តសាច់ប្រាក់ទៅតាមសកម្មភាពនីមួយៗដែលបានកំណត់រួចជាស្រេច ព្រមទាំងតាមដានត្រួតពិនិត្យសកម្មភាពនីមួយៗ ធ្វើយ៉ាងណាឱ្យមានតម្លាភាព។

#### ២.៣.១. ការរៀបចំ និងអនុម័តថវិកាឃុំ

នៅពេលប្រើប្រាស់ថវិកា លើសកម្មភាពនីមួយៗឃុំបានប្រជុំក្រុមប្រឹក្សា និងគណៈកម្មការឱ្យអនុម័តអ្នកប្រើប្រាស់ថវិកានោះឱ្យបានចំទិសដៅដែលបានកំណត់។ មេឃុំ ចៅសង្កាត់ត្រូវធានាឱ្យមានការចូលរួមពីសាធារណៈជនមូលដ្ឋានក្នុងដំណើរការរៀបចំថវិកាតាម រយៈវិធានការទាំងឡាយដូចខាងក្រោម៖

- គម្រោងថវិកាត្រូវតែប្រកាសផ្សាយជាសាធារណៈ យ៉ាងតិច២សប្តាហ៍ មុនពេលកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់
- អង្គប្រជុំរបស់គណៈកម្មាធិការកសាងផែនការ និងថវិកាត្រូវបើកចំហដល់សាធារណជនដែលចាប់អារម្មណ៍លើការពិនិត្យគំរោងថវិកានេះ
- ប្រជាពលរដ្ឋត្រូវតែបានផ្តល់កាលានុវត្តភាពក្នុងការចូលរួមសម័យប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលសម្រេចលើ គម្រោងថវិកា
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបង្កើតនូវយន្តការផ្សេងៗដើម្បីជំរុញឱ្យមានការចូលរួមពីសាធារណជនលើ កិច្ចការមូលដ្ឋាន។
- មេឃុំ ចៅសង្កាត់ត្រូវបញ្ជូនគម្រោងថវិកាដែលបានអនុម័តរួចទៅអភិបាលខេត្ត ក្រុងអោយបានមុនថ្ងៃទី៥ខែវិច្ឆកា ដើម្បីបញ្ជាក់ទទួលស្គាល់។ គម្រោងថវិកាត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោម៖

- របាយការណ៍សង្ខេបស្ដីពី មូលដ្ឋានក្នុងការរៀបចំចំណូល និងចំណាយព្រមទាំងកម្រិតចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំថវិកា
- របាយការណ៍ស្ដីពីការអនុវត្តន៍ថវិកានៃឆ្នាំដំណើរការ
- តារាងសង្ខេបនៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលបានបញ្ជាក់ក្នុងផែនការអភិវឌ្ឍឃុំសង្កាត់ប្រសិនបើមាន
- កំណត់ហេតុស្ដីពីកិច្ចប្រជុំអនុម័តលើគម្រោងថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

## ២.៣.២. កំណត់ហេតុប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាឃុំសាន់គ

កំណត់ហេតុស្ដីពី ការប្រជុំវិសាមញ្ញលើកទី៤របស់ក្រុមប្រឹក្សាឃុំអាណត្តិទី៥ ដើម្បីពិភាក្សាគ្នា និងអនុម័តលើគម្រោងថវិកាឆ្នាំពីរពាន់ម្ភៃបួនពុទ្ធសករាជពីរពាន់ប្រាំរយហុកសិបប្រាំពីរ បញ្ចាស័ក ឆ្នាំថោះ ខែស្រាពណ៍ ដប់មួយរោច ថ្ងៃចន្ទ ត្រូវនឹងគ្រិស្តសករាជពីរពាន់ម្ភៃបី ខែកញ្ញា ថ្ងៃទីដប់មួយ វេលាម៉ោងប្រាំពីរនឹងសាមសិបនាទីព្រឹក នៅសាលាឃុំសាន់គ បានរៀបចំកិច្ចប្រជុំវិសាមញ្ញលើកទីបួនរបស់ក្រុមប្រឹក្សាឃុំអាណត្តិទី៥ ដើម្បីពិភាក្សា និងអនុម័តលើគម្រោងថវិកាប្រចាំឆ្នាំពីរពាន់ម្ភៃបី ក្រោមអធិបតីភាពលោក ជូ សួន ប្រធានក្រុមប្រឹក្សាឃុំ ជាប្រធានអង្គប្រជុំ។ សមាសភាពចូលរួមដូចមានជូនមកជាមួយនឹងបញ្ជីវត្តមាននេះស្រាប់ ។

**វារៈទី១៖ នៃអង្គប្រជុំ**

១. ការពិភាក្សាគ្នា លើសេចក្ដីព្រាងគម្រោងថវិកាឆ្នាំពីរពាន់ម្ភៃបួន

២. អនុម័តលើគម្រោងថវិកាឆ្នាំពីរពាន់ម្ភៃបួន

ជាកិច្ចចាប់ផ្ដើមនៃកម្មវិធីអង្គប្រជុំទើបលោកប្រធានបើកអង្គប្រជុំ និងបានថ្លែងអំណរគុណចំពោះវត្តមានអ្នកចូលរួមទាំងអស់ក្នុងពេលនេះផងដែរ។ បន្តមកទៀតទើបស្មៀនពិនិត្យក្វ៉ុមឃើញថា សមាជិកក្រុមប្រឹក្សាឃុំអញ្ជើញចូលរួមទាំងអស់នាពេលនេះ មានចំនួន ដប់មួយរូបលើដប់មួយរូប អង្គប្រជុំដំណើរការជាបន្តបន្ទាប់ដូចតទៅៈ

លោក ជូ សួន ប្រធានអង្គប្រជុំបានលើកយករបៀបវារៈ ដែលត្រូវធ្វើការប្រជុំនាពេលនេះមកអានជូនសមាជិកអង្គប្រជុំស្ដាប់ម្ដងមួយៗ ដើម្បីឱ្យសមាជិកទាំងអស់នោះបានជ្រាប ក្រែងមានសមាជិកណាមួយចង់បន្ថែមរបៀបវារៈថ្មីបន្តទៀត ប៉ុន្តែដោយពុំមានសមាជិកអង្គប្រជុំណាចង់បន្ថែមរបៀបវារៈទៀតនោះទើបលោកប្រធានដាក់ជូនឱ្យសមាជិក ធ្វើការអនុម័តដោយលើកដៃ ពេលនោះសមាជិកបានអនុម័តលើរបៀបវារៈនេះ មាន

ចំនួនដប់មួយរូបលើដប់មួយរូបទើបដំណើរការពិភាក្សាគ្នា ទៅលើសេចក្តីព្រាងគម្រោងថវិកាប្រចាំឆ្នាំពីរពាន់ ម្ភៃបួនដូចតទៅ ។

ក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំបានគ្រោងថវិកាចំណូលតាមជំពូក គណនី អនុគណនី នីមួយៗក្នុង ឧបសម្ព័ន្ធ១ និងអនុស្សរណៈ ស្តីពីការរៀបចំគម្រោងថវិកាឆ្នាំពីរពាន់ម្ភៃបួន ដើម្បីបង្កើត បានជាគម្រោងថវិកាឃុំសម្រាប់អនុវត្តឆ្នាំពីរពាន់ម្ភៃបួនរួមមាន៖

១. អនុគណនី ៧៥០១១ ឧបត្ថម្ភពីក្រសួង ស្ថាប័នចំនួនៈ៤៣៤,០០០,០០០៛

២. អនុគណនី ៧៥០៣១ ការចូលរួមពីសមាសភាគអភិវឌ្ឍន៍មូលដ្ឋានចំនួនៈ៥១,៦០០,០០០៛

៣. អនុគណនី ៧៥១១១ ឧបត្ថម្ភកពីថ្នាក់ជាតិសម្រាប់ចំណាយវិនិយោគចំនួនៈ២៧១,០០០,០០០៛

បន្ទាប់មកទៀតទើបក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការក៏បានគ្រោងថវិកាឱ្យតាមជំពូក គណនី អនុគណនី នីមួយៗក្នុង ឧបសម្ព័ន្ធ២ និងអនុស្សរណៈ ស្តីពីការរៀបចំគម្រោងថវិកា ឆ្នាំពីរពាន់ម្ភៃបួនដើម្បីបង្កើតបានជាគម្រោងថវិកាឃុំសម្រាប់អនុវត្តឆ្នាំពីរពាន់ម្ភៃពីររួមមានៈ

១. ជំពូក៦០ ការទិញចំនួន៣៨,៦៦៨,០០០ រៀល

២. ជំពូក៦១ សេវាកម្មចំនួនៈ៧៣,៣០២,០០០រៀល,

៣. ជំពូក៦២ អត្ថប្រយោជន៍សង្គមចំនួន១៣,១២៣,២០០រៀល

៤. ជំពូក៦៤ បន្ទុកបុគ្គលិកចំនួន ៣៥៤,៣៤០,០០០រៀល

៥. ជំពូក៦៩ ចំណាយមិនបានគ្រោងទុកចំនួន ២៣,០០០,០០០រៀល

៦. ជំពូក២១ អចលនកម្មរូបី ចំនួន ៧២១,៧២៥,៩២៦ រៀល

លទ្ធផលគ្រោងថវិកាដូចមានក្នុងសេចក្តីព្រាងក្នុងតារាងថវិកាលម្អិត ឧបសម្ព័ន្ធ១ ឧបសម្ព័ន្ធ២ និង អនុស្សរណៈស្តីពីការរៀបចំគម្រោង ថវិកាឆ្នាំពីរពាន់ម្ភៃពីរ ដែលបានគ្រោងរួច។

**វារៈទី២៖** ការពិភាក្សាគ្នាលើសេចក្តីព្រាងគម្រោងថវិកាប្រចាំឆ្នាំពីរពាន់ម្ភៃបួន ទើបលោក **ជា ណារ៉ុង** ស្មៀនឃុំសាន់គ បានលើកយកសេចក្តីព្រាងគម្រោងថវិកា ដែលបានព្រាងរួចដូចមានក្នុងតារាងថវិកាលម្អិត អនុស្សរណៈស្តីពីការរៀបចំគម្រោងថវិកាឆ្នាំពីរពាន់ម្ភៃបួន ឧបសម្ព័ន្ធ១ ឧបសម្ព័ន្ធ ២ ទៅតាមជំពូក គណនី អនុគណនី នីមួយៗ ទាំងផ្នែកថវិកាចំណូល និងថវិកាចំណាយមកអានជូនសមាជិក នៃអង្គប្រជុំបានជ្រាប និង ពិភាក្សាគ្នាទៅតាមតារាងថវិកាលម្អិតជូនភ្ជាប់នេះស្រាប់។ ជាកិច្ចបន្តមកទៀត ទើបលោកប្រធានដាក់ជូន

ឱ្យសមាជិក ធ្វើការពិភាក្សាគ្នាអស់ជាច្រើននាទីទៅតាម ជំពូក គណនី និងអនុគណនីនីមួយៗដោយបញ្ជាក់ថាពិតជាត្រឹមត្រូវ ទៅតាមទិសដៅដែលក្រុមប្រឹក្សាឃុំ គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ និងប្រជាពលរដ្ឋទាំងអស់គ្នាចង់បាន។

**វារៈទី៣៖** ការអនុម័តលើម្រោងថវិកាប្រចាំឆ្នាំពីរពាន់ម្ភៃបួនដោយសមាជិកទាំងអស់ មានការឯកភាពព្រមព្រៀងគ្នាហើយនោះ ទើបលោកប្រធាន ធ្វើការបូកសរុបនៅលទ្ធផលអង្គប្រជុំរួម និងដាក់ជូនឱ្យសមាជិកធ្វើការអនុម័តដោយលើកដៃលើគម្រោងថវិកាប្រចាំឆ្នាំពីរពាន់ម្ភៃពីរ នេះសមាជិកក្រុមប្រឹក្សាឃុំបានអនុម័តមានចំនួនដប់មួយរូបលើដប់មួយរូប ទើបលោកប្រធានចុះហត្ថលេខាជា ផ្លូវការ។[56]


ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បញ្ជីវត្តមាន

[illegible] ឆ្នាំ ២០២៤

ថ្ងៃទី០៤ ខែ[illegible]២០២៣

| ល.រ | ឈ្មោះ | ភេទ | តួនាទី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|---|
| 1 | [illegible] | ប | មេឃុំ | សាលាឃុំ[illegible] | [illegible] |
| 2 | [illegible] | ប | ជំទប់ទី1 | -ll- | [illegible] |
| 3 | [illegible] | ប | ជំទប់ទី2 | -ll- | [illegible] |
| 4 | [illegible] | ប | ក្រុមប្រឹក្សាឃុំ | -ll- | [illegible] |
| 5 | [illegible] | ប | ក្រុមប្រឹក្សាឃុំ | -ll- | [illegible] |
| 6 | [illegible] | ប | -ll- | -ll- | [illegible] |
| 7 | [illegible] | ប | -ll- | -ll- | [illegible] |
| 8 | [illegible] | ប | -ll- | -ll- | [illegible] |
| 9 | [illegible] | ស | -ll- | -ll- | Thearothy |
| 11 | [illegible] | ប | -ll- | -ll- | [illegible] |
| 12 | [illegible] | ប | -ll- | -ll- | [illegible] |
| 13 | [illegible] | ប | ស្មៀនឃុំ | -ll- | [illegible] |
| 14 | [illegible] | ស | ជំនួយការរដ្ឋបាល[illegible] | -ll- | [illegible] |

[56] *កំណត់ហេតុនៃការប្រជុំវិសាមញ្ញលើកទី៤របស់ក្រុមប្រឹក្សាឃុំអាណត្តិទី៥ ។*

### ២.៣.៣. ចំណូលនិងចំណាយថវិកាឃុំសាន់គ

ដោយយោងតាមអនុស្សរណៈស្តីពីការរៀបចំគម្រោងថវិការឆ្នាំ២០២២របស់ឃុំសាន់គស្ថានភាពចំណូលចំណាយមានដូចតទៅ៖

**ក. ចំណូល**

- ចំណូលចរន្ត(សម្រាប់ចំណាយរដ្ឋបាល) ៤១៩,២១០,០០០រៀល(បួនរយដប់ប្រាំបួនលានពីរសែនមួយរយរៀល
- ចំណូលចរន្ត(សម្រាប់ចំណាយលើអភិវឌ្ឍន៍) ៣៧៩,០០១,៥០០រៀល(បីរយចិតសិបប្រាំបួនលានមួយពាន់ប្រាំរយ)រៀល
- សរុប ៧៩៨,២១១,៥០០រៀល(ប្រាំពីរកៅសិបប្រាំបីលានពីរសែនមួយម៉ឺនមួយពាន់ប្រាំរយ)រៀល

**ខ. ចំណាយ**

- ចំណាយចរន្ត ៣៨០,៣២៩,៥០០រៀល(បីរយប៉ែតសិបលានបីសែនពីរម៉ឺនប្រាំបួនពាន់ប្រាំរយ)រៀល
- ចំណាយមូលធន ៨៣,៥៥៦,៤៩០រៀល(ប៉ែតសិបបីលានប្រាំសែនប្រាំម៉ឺនប្រាំមួយពាន់បួនរយកៅសិប)រៀល
- សរុប ៤៦៣,៨៨៥,៩៩០រៀល(បួនរយហុកសិបបីលានប្រាំបីសែនប្រាំបីម៉ឺនប្រាំពាន់ប្រាំបួនរយកៅសិប)រៀល។[57]

ដោយយោងតាមអនុស្សរណៈស្តីពី ការរៀបចំគម្រោងថវិការឆ្នាំ២០២៣ របស់ឃុំសាន់គស្ថានភាពចំណូលចំណាយមានដូចតទៅ៖

**ក. ចំណូល**

- ចំណូលចរន្ត(សម្រាប់ចំណាយរដ្ឋបាល) ៤៦៦,៨៣០,៣០០រៀល (បួនរយហុកសិបប្រាំមួយលានប្រាំបីសែនបីម៉ឺនបីរយ)រៀល
- ចំណូលចរន្ត(សម្រាប់ចំណាយលើអភិវឌ្ឍន៍) ៤៧៣,១១០,០០០រៀល (បួនរយចិតសិបបីលានមួយសែនមួយម៉ឺន) រៀល
- សរុប ៩៣៩,៩៤០,៣០០រៀល(ប្រាំបួនរយសាបសិបប្រាំបួនលានប្រាំបួនសែនបួនម៉ឺនបីរយ)រៀល

---

[57] *របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២។*

**ខ. ចំណាយ**

- ចំណាយចរន្ត៤៥០,៤៩០,០០០រៀល(បួនរយហាសិបលានបួនសែនប្រាំបួនម៉ឺន)រៀល
- ចំណាយមូលធន១,០៧៩,២១៦,៥៥៨រៀល(មួយពាន់ចិតសិបប្រាំបួនលានពីរសែនមួយម៉ឺនប្រាំមួយពាន់ប្រាំរយហាសិបប្រាំបី)រៀល
- សរុប១,៥៣០,១០៦,៥៥៨រៀល(មួយពាន់ប្រាំរយសាបសិបលានមួយម៉ឺនប្រាំមួយពាន់ប្រាំរយហាសិបប្រាំបី)រៀល។[58]

**២.៣.៣.១. ប្រាក់ឧបត្ថម្ភប្រចាំខែរបស់មន្ត្រីរាជការ និងមន្ត្រីភូមិ**

អនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ ស្ដីពីការកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងប្រធានការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាលក្រុងស្រុកខណ្ឌ មានដូចតទៅ៖

- មេឃុំ-ចៅសង្កាត់ = ១៣២០០០០រ
- ជំទប់ទី១ = ៩៨០០០០រ
- ជំទប់ទី២ = ៩៨០០០០រ
- សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ = ៨៧០០០០រ
- មេភូមិ = ៥៥០០០០រ
- អនុភូមិ = ៤៣០០០០រ
- សមាជិកភូមិ = ៤០០០០០រ

**២.៣.៣.២. ផ្នែកមូលនិធិឃុំ**

- ឆ្នាំ២០២២៖ កសាងផ្លូវគ្រួសក្រហមបានប្រវែង៣,០២០ម៉ែត្រអស់ទឹកប្រាក់៨៣,៥៥៦,៤៩០រ
- ឆ្នាំ២០២៣៖ កសាងផ្លូវគ្រួសក្រហមបានប្រវែង៩,៦២៩ម៉ែត្រអស់ទឹកប្រាក់៦១៩,៣៣៧,១៥៤រ
- ឆ្នាំ២០២៣៖ កសាងផ្លូវគ្រួសក្រហមបានប្រវែង៦,៤៧៦ម៉ែត្រអស់ទឹកប្រាក់២០៧,០០០,០០០រ

[58] *របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣។*

### ២.៣.៣.៣. ប្រព័ន្ធទូទាត់ គណនេយ្យ

គណនេយ្យហិរញ្ញវត្ថុ គឺជាកិច្ចបញ្ជីការរាល់ចំណូលចំណាយនៅក្នុងប្រព័ន្ធគណនេយ្យ។ ហើយអ្នកដែលមានភារកិច្ចអនុវត្តន៍គណនេយ្យហិរញ្ញវត្ថុ គឺគណនេយ្យនៅរតនាគារខេត្តកំពង់ធំ។ គណនេយ្យថវិកា គឺការតាមដាន និងរាយការណ៍អំពីការអនុវត្តចំណូលចំណាយ និងថវិកាដែលមានអនុម័ត។ អ្នកដែលមានភារកិច្ចក្នុងការទទួលខុសត្រូវក្នុងការអនុវត្តគណនេយ្យថវិកាគឺលោក លោក ជូ សួន ដែលជា មេឃុំ នៃឃុំសាន់គ។[59]

ប្រព័ន្ធគណនេយ្យឃុំ សង្កាត់ត្រូវបំរើដល់គោលបំណងទាំងឡាយដូចខាងក្រោម៖

- បញ្ជីការរាល់ប្រតិបត្តិការហិរញ្ញវត្ថុរបស់ឃុំសង្កាត់
- ធ្វើរបាយការណ៍ហិរញ្ញវត្ថុជាក់ស្តែងឱ្យទាន់ពេលវេលា ដែលអាចជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់
- ផ្តល់មូលដ្ឋានសម្រាប់តាមដានការអនុវត្តន៍ថវិការបស់ឃុំសង្កាត់។

[59] *មាត្រា១២ច្បាប់ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ឃុំសង្កាត់ ឆ្នាំ២០០២។*

# ជំពូកទី៣

# សមិទ្ធផល បញ្ហាប្រឈម

# និងដំណោះស្រាយ

# ជំពូកទី៣

# សមិទ្ធផល បញ្ហាប្រឈម និងដំណោះស្រាយ

## ៣.១. សមិទ្ធផល

ក្នុងដំណើរការនៃការគ្រប់គ្រងរដ្ឋបាលក្នុងឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំក្នុងអាណត្តិទី៥ របស់ក្រុមប្រឹក្សានិងអាជ្ញាធរគ្រប់កម្រិតថ្នាក់មកទល់បច្ចុប្បន្ននេះ គឺបានចំនួនពីរឆ្នាំជាងមកហើយ ដែលទទួលបានសមិទ្ធផលមួយចំនួនដូចខាងក្រោម។[60]

### ៣.១.១. សមិទ្ធផលក្នុងឆ្នាំ២០២២

❖ **ស្ថិតិក្រុមប្រឹក្សាឃុំ និងបុគ្គលិកៈ**

១. សមាជិកក្រុមប្រឹក្សាឃុំ សរុប ១១ នាក់, ស្រី ០១ នាក់

២. សមាជិកក្រុមប្រឹក្សាឃុំ ដែលបានផ្លាស់ប្តូរ  0 នាក់

៣. មេឃុំ ០១ នាក់, ស្រី 0 នាក់

៤. ជំទប់ទី១  ០១ នាក់ ,ស្រី 0 នាក់

៥. ជំទប់ទី២  ០១ នាក់, ស្រី 0 នាក់

៦. ស្មៀនឃុំ ០១ នាក់, ស្រី 0 នាក់

៧. បុគ្គលិកកិច្ចសន្យាសរុប ៤ នាក់, ស្រី ០១នាក់

៨. បុគ្គលិកកិច្ចសន្យាឃុំ ( គម្រោងTSSD-AF) ០១ នាក់, ស្រី ០១ នាក់

៩. មេភូមិ ១៤ នាក់, ស្រី 06 នាក់

១០. អនុប្រធានភូមិ ១៤ នាក់, ស្រី ០៣ នាក់

១១. សមាជិកភូមិ ១៤នាក់, ស្រី ០៦ នាក់

❖ **ដីកា សេចក្តីសម្រេច និងលិខិតៈ**

១. ដីកាដែលបានដាក់ចេញចំនួន 0

២. សេចក្តីសម្រេចដែលបានដាក់ចេញចំនួន ១៩

៣. លិខិតរដ្ឋបាលដែលបានដាក់ចេញចំនួន ១១៩៦

៤. លិខិតដែលបានទទួលចំនួន ២៦

[60] *របាយការណ៍បូកសរុបសមិទ្ធផលប្រចាំឆ្នាំ២០២២។*

❖ **កិច្ចប្រជុំក្រុមប្រឹក្សាសង្កាត់ និង គ.ក.ន.ក**

១. កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាចំនួន ១២

២. កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាចំនួន ៥

៣. កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សាចំនួន ០

៤. កិច្ចប្រជុំ គ.ក.ន.ក ចំនួន ១២

❖ **គម្រោងវិនិយោគដែលមានការសន្យាគាំទ្រដោយថវិកាសង្កាត់**

១. សេដ្ឋកិច្ច ចំនួនគម្រោង០១ តម្លៃគម្រោង ៦១៨,៩៦៩,០០០

២. សង្គមកិច្ច ចំនួនគម្រោង០៧ តម្លៃគម្រោង ៤០,៣០០,០០០

៣. ធនធានធម្មជាតិ និងបរិស្ថាន ចំនួនគម្រោង ០ តម្លៃគម្រោង ០

៤. សេវាកម្មរដ្ឋបាល និងសន្តិសុខ ចំនួនគម្រោង ០១ តម្លៃគម្រោង ២៧,០០០,០០០

៥. យេនឌ័រ ចំនួនគម្រោង ០ តម្លៃគម្រោង ០

សរុប ០៩ គម្រោង = ៦៨៦,២៦៩,០០០

❖ **ការអនុវត្តគម្រោងឃុំ សង្កាត់**

| ល.រ | ផ្នែក | សរុប | ស្ថានភាពនៃការអនុវត្ត | | |
|---|---|---|---|---|---|
| | | | មិនទាន់ | កំពុង | បញ្ចប់ |
| ១ | សេដ្ឋកិច្ច | ១ | ០ | ១ | ១ |
| ២ | សង្គមកិច្ច | ៧ | ០ | ៧ | ៧ |
| ៣ | ធនធានធម្មជាតិ និងបរិស្ថាន | ០ | ០ | ០ | ០ |
| ៤ | សេវាកម្មរដ្ឋបាល និងសន្តិសុខ | ១ | ០ | ១ | ១ |
| ៥ | យេនឌ័រ | ០ | ០ | ០ | ០ |
| សរុប | | ៩ | ០ | ៩ | ៩ |

❖ **ផ្នែកសេដ្ឋកិច្ចៈ**

- គម្រោងមូលនិធិឃុំឆ្នាំ២០២២ ជួសជុលផ្លូវគ្រួសក្រហមប្រវែង ៩,៦២៩ម៉ែត្រ ទទឹង ៥ម៉ែត្រ នៅភូមិក្រសាំង(ខ) ភូមិស្លែងខ្ពស់និងភូមិក្រសាំង(ក) អនុវត្តដោយក្រុមហ៊ុន វេង ប៊ុនធឿន

៦១៨,៩៦៩,០០០រៀល។

❖ **ផ្នែកសង្គមកិច្ចៈ**

- ឧបត្ថម្ភស្ត្រីមានផ្ទៃពោះទៅពិនិត្យ និងសម្រាលកូននៅមណ្ឌលសុខភាពបានចំនួន៤០នាក់ចំណាយថវិកាឃុំផ្នែកសេវាសង្គម ចំនួន ៣,០០០,០០០រៀល។
- ឧបត្ថម្ភស្បៀងអាហារដល់គ្រួសារក្រីក្រងាយរងគ្រោះបានចំនួន ៥០នាក់ ចំណាយថវិកាឃុំផ្នែកសេវាសង្គមចំនួន ៥,០០០,០០០ រៀល ។
- ឧបត្ថម្ភគ្រូមត្តេយ្យសិក្សាសហគនមន៍ ចំនួន ០៥ ថ្នាក់ ៥នាក់ ចំណាយថវិកាសេវាសង្គមចំនួន ១៥,០០០,០០០០ រៀល ។
- ឧបត្ថម្ភសម្ភារៈថ្នាក់មត្តេយ្យសិក្សាសហគនមន៍ចំនួន ០៥ ថ្នាក់ចំណាយថវិកាសេវាសង្គម ចំនួន ២,៨០០,០០០០ រៀល ។
- ឧបត្ថម្ភស្បៀងអាហារដល់គ្រួសារក្រីក្រងាយរងគ្រោះ ដោយគ្រោះមហន្តរាយបានចំនួន ៦០នាក់ ចំណាយថវិកាឃុំ ផ្នែកសេវាសង្គមចំនួន ៦,០០០,០០០ រៀល ។
- ចុះប្រជុំផ្សព្វផ្សាយសុខភាពមាតា និងទារកចំណាយថវិកាឃុំផ្នែកសេវាសង្គមចំនួន ៤,០០០,០០០ រៀល ។
- ប្រជុំប្រចាំខែ គ.ក.ន.ក ចំណាយថវិកាឃុំផ្នែកសេវាសង្គមចំនួន ៤,៥០០,០០០ រៀល ។

❖ **ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ**

- ឧបត្ថម្ភជំនួយការរដ្ឋបាល០១នាក់ និងជំនួយការហិរញ្ញវត្ថុ ចំនួន ១នាក់ និងអ្នកអនាម័យឃុំចំនួន០២ នាក់ ចំណាយថវិការដ្ឋបាល ចំនួន ២៧,០០០,០០០ រៀល ។

❖ **ការអនុវត្តថវិកា ឃុំ/សង្កាត់**

| ល.រ | ការបរិយាយ | អនុម័ត | ជាក់ស្តែង |
|---|---|---|---|
| ១ | ចំណូលសរុប | ១,៤៣២,៣១៦,២៤៣ | ៩៦២,៣០៩,២៤៣ |
| ២ | ចំណាយសរុប | ១,១២៤,៤៣៩,២៤៣ | ៩៦២,៣០៩,២៤៣ |

❖ **ការគ្រប់គ្រងទ្រព្យសម្បត្តិ សង្កាត់**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ទ្រព្យសម្បត្តិឃុំ សង្កាត់ ដែលបានទិញ ឬទទួល (ថ្មី) | 0 |
| ២ | ទ្រព្យសម្បត្តិឃុំ សង្កាត់ដែលបានកាត់ចេញ | 0 |

❖ **ការអភិវឌ្ឍសមត្ថភាព**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | វគ្គសិក្សា | ១៤ |
| ២ | សិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា | ៣៦ |
| ៣ | សិក្ខាកាមជាស្ត្រីដែលបានចូលរួមវគ្គសិក្សា | ១១ |

❖ **សកម្មភាពសេវាសង្គម**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | មត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការដែលគាំទ្រពីឃុំ សង្កាត់ | ០៥ |
| ២ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់សម្រាប់កែលម្អអនាម័យ(ការលាងដៃនឹងសាប៊ូ) | 0 |
| ៣ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានទឹកស្អាតប្រើប្រាស់ | 0 |
| ៤ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានបង្គន់អនាម័យប្រើប្រាស់ | 0 |
| ៥ | គ្រួសារងាយរងគ្រោះដែលឃុំ សង្កាត់ចុះកំណត់អត្តសញ្ញាណ ( សេវាសង្គម ) | 0 |
| ៦ | ស្ត្រីរងគ្រោះដោយអំពើហឹង្សាក្នុងគ្រួសារដែលទទួលការគាំទ្រពីឃុំ សង្កាត់ | 0 |

❖ **ការសម្រុះសម្រួលទំនាស់**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយឃុំ សង្កាត់ | ១៤ |
| ២ | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | ០១ |

❖ **ការងារអត្រានុកូលដ្ឋាន**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សំបុត្រកំណើត | ៧៦ |
| ២ | សំបុត្របញ្ជាក់កំណើត | ១៩៣ |
| ៣ | សេចក្តីចម្លងសំបុត្រកំណើត | ៩០ |
| ៤ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ៨២ |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍ | ៤០ |
| ៦ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ៩៣ |
| ៧ | សំបុត្រមរណភាព | ២០ |
| ៨ | សេចក្តីចម្លងសំបុត្រមរណភាព | ៦១ |

❖ **ការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ប្រជាពលរដ្ឋដែលបានចុះឈ្មោះថ្មី | ០ |
| ២ | ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត | ០ |
| ៣ | ប្រជាពលរដ្ឋសរុបដែលមានឈ្មោះបោះឆ្នោត (ចាស់ និងថ្មី) | ៩,២១៦ |

❖ **បញ្ហាប្រឈមដែលរដ្ឋបាល សង្កាត់បានជួបប្រទះ**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| | | |
| ១ | ក្រុមហ៊ុនអាជីកម្មដឹកដី និងខ្សាច់មួយចំនួនមិនគោរពតាមកិច្ចសន្យាធ្វើឱ្យខូចផ្លូវពិបាកធ្វើដំណើរ | ថ្នាក់ខេត្ត/ស្រុក ជួយវិធានការណ៍ |

### ៣.១.២ សមិទ្ធផលក្នុងឆ្នាំ២០២៣

សម្រាប់ការបូកសរុបសមិទ្ធផលក្នុងឆ្នាំ២០២៣ សមិទ្ធដែលទទួលបានមានដូចខាងក្រោម៖[61]

❖ **ស្ថិតិក្រុមប្រឹក្សាឃុំ និងបុគ្គលិក**

១. សមាជិកក្រុមប្រឹក្សាឃុំ សរុប ១១ នាក់, ស្រី ០១ នាក់

២. សមាជិកក្រុមប្រឹក្សាឃុំ ដែលបានផ្លាស់ប្តូរ 0 នាក់

៣. មេឃុំ ០១ នាក់, ស្រី 0 នាក់

៤. ជំទប់ទី១ ០១ នាក់ ,ស្រី 0 នាក់

៥. ជំទប់ទី២ ០១ នាក់, ស្រី 0 នាក់

៦. ស្មៀនឃុំ ០១ នាក់, ស្រី 0 នាក់

៧. បុគ្គលិកកិច្ចសន្យាសរុប ៤ នាក់, ស្រី ០១នាក់

៨. បុគ្គលិកកិច្ចសន្យាឃុំ ( គម្រោងTSSD-AF) ០១ នាក់, ស្រី ០១ នាក់

៩. មេភូមិ ១៤ នាក់, ស្រី 06 នាក់

១០. អនុប្រធានភូមិ ១៤ នាក់, ស្រី ០៣ នាក់

១២. សមាជិកភូមិ ១៤នាក់, ស្រី ០៦ នាក់

❖ **ដីកា សេចក្តីសម្រេច និងលិខិត**

១. ដីកាដែលបានដាក់ចេញចំនួន ០

២. សេចក្តីសម្រេចដែលបានដាក់ចេញចំនួន ១៩

៣. លិខិតរដ្ឋបាលដែលបានដាក់ចេញចំនួន ១១២៥

៤. លិខិតដែលបានទទួលចំនួន ២៦

❖ **កិច្ចប្រជុំក្រុមប្រឹក្សា សង្កាត់ និង គ.ក.ន.ក**

១. កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាចំនួន ១២

២. កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាចំនួន ៦

៣. កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សាចំនួន 0

៤. កិច្ចប្រជុំ គ.ក.ន.កចំនួន ១២

---

[61] *របាយការណ៍បូកសរុបសមិទ្ធផលក្នុងឆ្នាំ២០២៣។*

❖ **គម្រោងវិនិយោគដែលមានការសន្យាគាំទ្រដោយថវិកាសង្កាត់**

១. សេដ្ឋកិច្ច ចំនួនគម្រោង ០១ តម្លៃគម្រោង ៥១១,៣៨៥,០០០

២. សង្គមកិច្ច ចំនួនគម្រោង ០៧ តម្លៃគម្រោង ៤០,៣០០,០០០

៣. ធនធានធម្មជាតិ និងបរិស្ថាន ចំនួនគម្រោង ០ តម្លៃគម្រោង ០

៤. សេវាកម្មរដ្ឋបាល និងសន្តិសុខ ចំនួនគម្រោង ០១ តម្លៃគម្រោង ២៧,០០០,០០០

៥. យេនឌ័រ ចំនួនគម្រោង ០ តម្លៃគម្រោង ០

សរុប ០៩ គម្រោង = ៥៧៨,៦៨៥,០០០

❖ **ការអនុវត្តគម្រោងឃុំ សង្កាត់**

| ល.រ | ផ្នែក | សរុប | ស្ថានភាពនៃការអនុវត្ត | | |
|---|---|---|---|---|---|
| | | | មិនទាន់ | កំពុង | បញ្ចប់ |
| ១ | សេដ្ឋកិច្ច | ១ | ០ | ០ | ១ |
| ២ | សង្គមកិច្ច | ៦ | ០ | ០ | ៦ |
| ៣ | ធនធានធម្មជាតិ និងបរិស្ថាន | ០ | ០ | ០ | ០ |
| ៤ | សេវាកម្មរដ្ឋបាល និងសន្តិសុខ | ០ | ០ | ០ | ០ |
| ៥ | យេនឌ័រ | ០ | ០ | ០ | ០ |
| សរុប | | ៧ | ០ | ០ | ៧ |

❖ **ផ្នែកសេដ្ឋកិច្ចៈ**

- គម្រោងមូលនិធិឃុំឆ្នាំ២០២៣ ជួសជុលផ្លូវគ្រួសក្រហមប្រវែង ៦៤៧៦ម៉ែត្រ ទទឹង ៦ម៉ែត្រ នៅភូមិអំពិល និងភូមិសំពៅមាស អនុវត្តដោយក្រុមហ៊ុន ហៀង វាន់ធី ៦១៨,៦៩៦,៣០២រៀល។

❖ **ផ្នែកសង្គមកិច្ចៈ**

- ឧបត្ថម្ភស្ត្រីមានផ្ទៃពោះទៅពិនិត្យ និងសម្រាលកូននៅមណ្ឌលសុខភាព បានចំនួន ៥០នាក់ចំណាយថវិកាឃុំផ្នែកសេវាសង្គម ចំនួន ៤,០០០,០០០រៀល។
- ឧបត្ថម្ភស្បៀងអាហារដល់គ្រួសារក្រីក្រងាយរងគ្រោះ បានចំនួន ៦០នាក់ ចំណាយថវិកាឃុំផ្នែកសេវាសង្គមចំនួន ៦,០០០,០០០ រៀល។
- ឧបត្ថម្ភគ្រូមត្តេយ្យសិក្សាសហគនមន៍ ចំនួន ០៥ ថ្នាក់ ៥នាក់ ចំណាយថវិកាសេវាសង្គមចំនួន ១៥,០០០,០០០០ រៀល។

- ឧបត្ថម្ភសម្ភារៈថ្នាក់មត្តេយ្យសិក្សាសហគនមន៍ ចំនួន ០៥ ថ្នាក់ ចំណាយថវិកាសេវាសង្គមចំនួន ២,៨០០,០០០០ រៀល។
- ឧបត្ថម្ភស្បៀងអាហារដល់គ្រួសារក្រីក្រងាយរងគ្រោះ ដោយគ្រោះមហន្តរាយ បានចំនួន ៦០នាក់ ចំណាយថវិកាឃុំផ្នែកសេវាសង្គមចំនួន ៦,០០០,០០០ រៀល។
- ចុះប្រជុំផ្សព្វផ្សាយសុខភាពមាតា និងទារក ចំណាយថវិកាឃុំ ផ្នែកសេវាសង្គមចំនួន ៤,០០០,០០០ រៀល។
- ប្រជុំប្រចាំខែ គ.ក.ន.ក ចំណាយថវិកាឃុំ ផ្នែកសេវាសង្គមចំនួន ៤,៥០០,០០០ រៀល ។

❖ **ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ**

- ឧបត្ថម្ភជំនួយការរដ្ឋបាល០១នាក់ និងជំនួយការហិរញ្ញវត្ថុ ចំនួន ១នាក់ និងអ្នកអនាម័យឃុំចំនួន០២ នាក់ ចំណាយថវិការដ្ឋបាល ចំនួន ២៧,០០០,០០០ រៀល ។

❖ **ការអនុវត្តថវិកា សង្កាត់**

| ល.រ | ការបរិយាយ | អនុម័ត | ជាក់ស្តែង |
|---|---|---|---|
| ១ | ចំណូលសរុប | ១,៥៨៤,៧៦៨,៧៥៤ | ៩៣៩,៩៤០,៣០០ |
| ២ | ចំណាយសរុប | ១,៥៨៤,៧៦៨,៧៥៤ | ៩៣៩,៩៤០,៣០០ |

❖ ការគ្រប់គ្រងទ្រព្យសម្បត្តិ សង្កាត់

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ទ្រព្យសម្បត្តិឃុំ សង្កាត់ ដែលបានទិញ ឬទទួល (ថ្មី) | ០ |
| ២ | ទ្រព្យសម្បត្តិឃុំ សង្កាត់ដែលបានកាត់ចេញ | ០ |

❖ **ការអភិវឌ្ឍសមត្ថភាព**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | វគ្គសិក្សា | ១៧ |
| ២ | សិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា | ១៩ |
| ៣ | សិក្ខាកាមជាស្ត្រីដែលបានចូលរួមវគ្គសិក្សា | ១៥ |

❖ **សកម្មភាពសេវាសង្គម**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | មត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការដែលគាំទ្រពីឃុំ សង្កាត់ | ០៥ |
| ២ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់សម្រាប់កែលម្អអនាម័យ(ការលាងដៃនឹងសាប៊ូ) | ០ |
| ៣ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានទឹកស្អាតប្រើប្រាស់ | ០ |
| ៤ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានបង្គន់អនាម័យប្រើប្រាស់ | ០ |
| ៥ | គ្រួសារងាយរងគ្រោះដែលឃុំ សង្កាត់ចុះកំណត់អត្តសញ្ញាណ ( សេវាសង្គម ) | ៩៦៥ |
| ៦ | ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារដែលទទួលការគាំទ្រពីឃុំ សង្កាត់ | ០ |

- **ការសម្រុះសម្រួលទំនាស់**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយឃុំ សង្កាត់ | ១៩ |
| ២ | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | ០១ |

- **ការងារអត្រានុកូលដ្ឋាន**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សំបុត្រកំណើត | ៤៥ |
| ២ | សំបុត្របញ្ជាក់កំណើត | ១១៩ |
| ៣ | សេចក្ដីចម្លងសំបុត្រកំណើត | ៧៤ |
| ៤ | សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត | ៨៤ |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍ | ៤៥ |

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ៦ | សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ១២២ |
| ៧ | សំបុត្រមរណភាព | ២៥ |
| ៨ | សេចក្ដីចម្លងសំបុត្រមរណភាព | ៦៤ |

❖ **ការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ប្រជាពលរដ្ឋដែលបានចុះឈ្មោះថ្មី | 0 |
| ២ | ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត | 0 |
| ៣ | ប្រជាពលរដ្ឋសរុបដែលមានឈ្មោះបោះឆ្នោត (ចាស់ និងថ្មី) | ៩,២៥៩ |

❖ **បញ្ហាប្រឈមដែលរដ្ឋបាល សង្កាត់បានជួបប្រទះ**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| | | |
| ១ | ក្រុមហ៊ុនអាជីកម្មដឹកដីនិងខ្សាច់មួយចំនួនមិនគោរពតាមកិច្ចសន្យាធ្វើឱ្យខូចផ្លូវ ពិបាកធ្វើដំណើរ | ថ្នាក់ខេត្ត/ស្រុក ជួយវិធានការណ៍ |

### ៣.១.៣ សមិទ្ធផលក្នុងឆ្នាំ២០២៤

សម្រាប់ការបូកសរុបសមិទ្ធផលក្នុងឆ្នាំ២០២៣ សមិទ្ធដែលទទួលបានមានដូចខាងក្រោម៖[62]

❖ ស្ថិតិក្រុមប្រឹក្សា ឃុំ និងបុគ្គលិក

១. សមាជិកក្រុមប្រឹក្សាឃុំ សរុប ១១ នាក់, ស្រី ០១ នាក់

២. សមាជិកក្រុមប្រឹក្សាឃុំ ដែលបានផ្លាស់ប្ដូរ 0 នាក់

៣. មេឃុំ ០១ នាក់, ស្រី 0 នាក់

៤. ជំទប់ទី១ ០១ នាក់, ស្រី 0 នាក់

[62] *របាយការណ៍បូកសរុបសមិទ្ធផលក្នុងឆ្នាំ២០២៤*

៥. ជំទប់ទី២ ០១ នាក់, ស្រី 0 នាក់

៦. ស្មៀនឃុំ ០១ នាក់, ស្រី 0 នាក់

៧. បុគ្គលិកកិច្ចសន្យាសរុប ៤ នាក់, ស្រី ០១នាក់

៨. បុគ្គលិកកិច្ចសន្យាឃុំ ( គម្រោងTSSD-AF) ០១ នាក់, ស្រី ០១ នាក់

៩. មេភូមិ ១៤ នាក់, ស្រី 06 នាក់

១០. អនុប្រធានភូមិ ១៤ នាក់, ស្រី ០៣ នាក់

១១. សមាជិកភូមិ ១៤នាក់, ស្រី ០៦ នាក់

❖ **ដីកា សេចក្តីសម្រេច និងលិខិត**

១. ដីកាដែលបានដាក់ចេញចំនួន 0

២. សេចក្ដីសម្រេចដែលបានដាក់ចេញចំនួន ០៣

៣. លិខិតរដ្ឋបាលដែលបានដាក់ចេញចំនួន ៩១៥

៤. លិខិតដែលបានទទួលចំនួន ០៦

❖ **កិច្ចប្រជុំក្រុមប្រឹក្សាសង្កាត់ និង គ.ក.ន.ក**

១. កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាចំនួន ០៦

២. កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាចំនួន ០២

៣. កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សាចំនួន 0

៤. កិច្ចប្រជុំ គ.ក.ន.កចំនួន ០៦

❖ **គម្រោងវិនិយោគដែលមានការសន្យាគាំទ្រដោយថវិកាសង្កាត់**

| | | |
|---|---|---|
| ១. សេដ្ឋកិច្ច | ចំនួនគម្រោង ០១ | តម្លៃគម្រោង ៥០៤,០៨៥,000 |
| ២. សង្គមកិច្ច | ចំនួនគម្រោង ០៧ | តម្លៃគម្រោង ១៨,៩00,000 |
| ៣. ធនធានធម្មជាតិ និងបរិស្ថាន | ចំនួនគម្រោង 0 | តម្លៃគម្រោង 0 |
| ៤. សេវាកម្មរដ្ឋបាល និងសន្តិសុខ | ចំនួនគម្រោង ០១ | តម្លៃគម្រោង ១៣,៥00,000 |
| ៥. យេនឌ័រ | ចំនួនគម្រោង 0 | តម្លៃគម្រោង 0 |
| | សរុប ០៩ គម្រោង = ៥៧៨,៦៨៥,000 | |

❖ **ការអនុវត្តគម្រោងឃុំ សង្កាត់**

| ល.រ | ផ្នែក | សរុប | ស្ថានភាពនៃការអនុវត្ត | | |
|---|---|---|---|---|---|
| | | | មិនទាន់ | កំពុង | បញ្ចប់ |
| ១ | សេដ្ឋកិច្ច | ១ | 0 | 0 | ១ |
| ២ | សង្គមកិច្ច | ៦ | 0 | 0 | ៦ |
| ៣ | ធនធានធម្មជាតិ និងបរិស្ថាន | 0 | 0 | 0 | 0 |
| ៤ | សេវាកម្មរដ្ឋបាល និងសន្តិសុខ | 0 | 0 | 0 | 0 |
| ៥ | យេនឌ័រ | 0 | 0 | 0 | 0 |
| សរុប | | ៧ | 0 | 0 | ៧ |

❖ **ផ្នែកសេដ្ឋកិច្ច៖**

- គម្រោងមូលនិធិឃុំឆ្នាំ២០២៣ ជួសជុលផ្លូវបេតុង ១,០៣៥ម៉ែត្រ ទទឹង ៥ម៉ែត្រ នៅភូមិវាល,ភូមិបល្ល័ង្គ និងភូមិសារី អនុវត្តដោយក្រុមហ៊ុន យ៉េន ស៊ីនួន ៥០៤,០៨៥,000រៀល។

❖ **ផ្នែកសង្គមកិច្ច៖**

- ឧបត្ថម្ភស្ត្រីមានផ្ទៃពោះទៅពិនិត្យ និងសម្រាលកូននៅមណ្ឌលសុខភាព បានចំនួន ២៥នាក់ចំណាយថវិកាឃុំផ្នែកសេវាសង្គម ចំនួន ២,000,000រៀល។
- ឧបត្ថម្ភស្បៀងអាហារដល់គ្រួសារក្រីក្រងាយរងគ្រោះ បានចំនួន ៣០នាក់ ចំណាយថវិកាឃុំ ផ្នែកសេវាសង្គមចំនួន ៣,000,000 រៀល។
- ឧបត្ថម្ភគ្រូមត្តេយ្យសិក្សាសហគនមន៍ ចំនួន ០៥ ថ្នាក់ ៥នាក់ ចំណាយថវិកាសេវាសង្គម ចំនួន ៧,៥00,0000 រៀល។
- ឧបត្ថម្ភសម្ភារៈថ្នាក់មត្តេយ្យសិក្សាសហគនមន៍ ចំនួន ០៥ ថ្នាក់ ចំណាយថវិកាសេវាសង្គម ចំនួន ១,៤00,0000 រៀល។
- ឧបត្ថម្ភស្បៀងអាហារដល់គ្រួសារក្រីក្រងាយរងគ្រោះ ដោយគ្រោះមហន្តរាយ បានចំនួន ៣០នាក់ ចំណាយថវិកាឃុំ ផ្នែកសេវាសង្គមចំនួន ៣,000,000 រៀល។
- ចុះប្រជុំផ្សព្វផ្សាយសុខភាពមាតា និងទារកចំណាយថវិកាឃុំផ្នែកសេវាសង្គមចំនួន ២,000,000 រៀល។
- ប្រជុំប្រចាំខែ គ.ក.ន.ក ចំណាយថវិកាឃុំ ផ្នែកសេវាសង្គមចំនួន ២,២៥0,000 រៀល។

- **ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ**

- ឧបត្ថម្ភជំនួយការរដ្ឋបាល០១នាក់ និងជំនួយការហិរញ្ញវត្ថុ ចំនួន ១នាក់ និងអ្នកអនាម័យឃុំចំនួន០២ នាក់ ចំណាយថវិការដ្ឋបាល ចំនួន ១៣,៥០០,០០០ រៀល។

- **ការអនុវត្តថវិកា សង្កាត់**

| ល.រ | ការបរិយាយ | អនុម័ត | ជាក់ស្តែង |
|---|---|---|---|
| ១ | ចំណូលសរុប | ១,៥៨៦,៧៦៨,៧២៤ | ៩៤៩,៩៥០,០០០ |
| ២ | ចំណាយសរុប | ១,៥៨៦,៧៦៨,៧២៤ | ៩៤៩,៩៥០,០០០ |

- **ការគ្រប់គ្រងទ្រព្យសម្បត្តិ សង្កាត់**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ទ្រព្យសម្បត្តិឃុំ សង្កាត់ ដែលបានទិញ ឬទទួល (ថ្មី) | ០ |
| ២ | ទ្រព្យសម្បត្តិឃុំ សង្កាត់ដែលបានកាត់ចេញ | ០ |

- **ការអភិវឌ្ឍសមត្ថភាព**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | វគ្គសិក្សា | ៩ |
| ២ | សិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា | ៧ |
| ៣ | សិក្ខាកាមជាស្ត្រីដែលបានចូលរួមវគ្គសិក្សា | ៤ |

- **សកម្មភាពសេវាសង្គម**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | មត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការដែលគាំទ្រពីឃុំ សង្កាត់ | ០៥ |
| ២ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់សម្រាប់កែលម្អអនាម័យ(ការលាងដៃនឹងសាប៊ូ) | ០ |
| ៣ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានទឹកស្អាតប្រើប្រាស់ | ០ |

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ៤ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានបង្គន់អនាម័យប្រើប្រាស់ | ០ |
| ៥ | គ្រួសារងាយរងគ្រោះដែលឃុំ សង្កាត់ចុះកំណត់អត្តសញ្ញាណ ( សេវាសង្គម ) | ៩៦៥ |
| ៦ | ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារដែលទទួលការគាំទ្រពីឃុំ សង្កាត់ | ០ |

❖ **ការសម្រុះសម្រួលទំនាស់**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយឃុំ សង្កាត់ | ៩ |
| ២ | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | ០១ |

❖ **ការងារអត្រានុកូលដ្ឋាន**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សំបុត្រកំណើត | ៥៥ |
| ២ | សំបុត្របញ្ជាក់កំណើត | ៩៣ |
| ៣ | សេចក្តីចម្លងសំបុត្រកំណើត | ៦៤ |
| ៤ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ៧៤ |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍ | ៣៥ |
| ៦ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ២២ |
| ៧ | សំបុត្រមរណភាព | ៣៥ |
| ៨ | សេចក្តីចម្លងសំបុត្រមរណភាព | ២៤ |

❖ **ការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ប្រជាពលរដ្ឋដែលបានចុះឈ្មោះថ្មី | ០ |
| ២ | ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត | ០ |

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ៣ | ប្រជាពលរដ្ឋសរុបដែលមានឈ្មោះបោះឆ្នោត (ចាស់ និងថ្មី) | ៩,២៥៩ |

- **បញ្ហាប្រឈមដែលរដ្ឋបាល សង្កាត់បានជួបប្រទះ**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| | | |
| ១ | ក្រុមហ៊ុនអាជីកម្មដឹកដី និងខ្សាច់មួយចំនួនមិនគោរពតាមកិច្ចសន្យាធ្វើឱ្យខូចផ្លូវពិបាកធ្វើដំណើរ | ថ្នាក់ខេត្ត/ស្រុក ជួយវិធានការណ៍ |

## ៣.២. បញ្ហាប្រឈម

តាមការសិក្សារស្រាវជ្រាវតាមរយៈឯកសារតម្កល់ និងការចុះសម្ភាសន៍ជាមួយនឹងប្រធានក្រុមប្រឹក្សាមេឃុំ និងអាជ្ញាធរទាំងអស់ទាំងអស់ដែលបម្រើការងារនៅក្នុងឃុំសង្កាត់ នាងខ្ញុំ និងខ្ញុំបាទបានសង្កេតឃើញថានៅក្នុងការគ្រប់គ្រងរដ្ឋបាលថ្នាក់ឃុំសង្កាត់ ទោះបីជាមានការយកចិត្តទុកដាក់នៅក្នុងការបម្រើសេវាយ៉ាងណាក្តីក៏នៅតែមានការខ្វះចន្លោះខ្លះៗ ដែលធ្វើមានការលំបាក និងបញ្ហាប្រឈមមួយចំនួននាំឱ្យមានការរាំងស្ទះក្នុងការអភិវឌ្ឍដូចជា៖

### ៣.២.១. ផ្នែកអប់រំ

ក្នុងពេលបច្ចុប្បន្ននេះ នៅក្នុងឃុំសាន់គ មានសាលារៀន និងគ្រូគ្រប់គ្រាន់សម្រាប់បង្ហាត់បង្រៀនដល់កុមារឱ្យទទួលបានការបណ្តុះបណ្តាលផ្នែកអប់រំឲកាន់ល្អតែប្រសើរ ពីព្រោះថាផ្នែកអប់រំ គឺពិតជាមានសារៈសំខាន់ណាស់នៅក្នុងការចូលរួមចំណែកបង្កបង្កើតធនធានមនុស្សនៅក្នុងតំបន់ឃុំ សង្គម និងប្រទេសឱ្យសម្បូរទៅដោយអ្នកមានចំណេះដឹង មានគុណធម៌ សុជីវធម៌ ជាបុគ្គលដែលមានគុណភាព ជាសសរទ្រូងសម្រាប់អភិវឌ្ឍន៍ប្រទេសឱ្យមានភាពរីកចម្រើន។ ក៏ប៉ុន្តែអ្វីដែលជាបញ្ហាចោទនោះ គឺកុមារក៏ដូចជាអាណាព្យាបាលមិនបានចូលរួមសហការឱ្យបានជិតដល់ជាមួយអាជ្ញាធរក្នុងការរៀបចំនេះនោះទេ ដោយហេតុថា៖

- **សិស្សមួយចំនួនបានបោះបង់ការសិក្សា៖** កុមារខ្លះក៏ទទួលបានការបណ្តុះបណ្តាលផ្នែកអប់រំបានពេញលេញ រីឯកុមារខ្លះក៏បានបោះបង់ការសិក្សាដោយសារតែកត្តាជីវភាពមិនសូវធូធារ ។
- **បញ្ហាយុវវ័យ៖** នៅមានក្មេងទំនើងមួយចំនួន និងមួយចំនួនទៀតប្រើប្រាស់គ្រឿងញៀន ហើយការស្លៀកពាក់បែបសម័យខុសប្រពៃណីខ្មែរ និងប្រើប្រាស់សម្ភារៈនិយម។
- **ឪពុកម្តាយចំណាកស្រុក៖** ដោយសារឪពុកម្តាយទៅរកស៊ីឆ្ងាយ និងធ្វើការចំណាកស្រុក តម្រូវយកកូនទៅជាមួយពីព្រោះគ្មានអ្នកមើលថៃ ជាហេតុធ្វើឱ្យកូនបាត់បង់ឱកាសក្នុងទទួលបានការសិក្សារៀនសូត្រ។ កត្តាដែលនាំឱ្យមានការធ្វើការចំណាកស្រុកនេះមានហេតុផលជាច្រើនដូចជា៖

- ជំពាក់លុយធាគារ(រកស៊ី ឬធ្វើស្រែចំការខាត)
- គ្មានដើមទុនប្រកបមុខរបររកស៊ី
- នៅក្នុងតំបន់ស្រុកកំណើតមិនមានកន្លែងសម្រាប់ប្រកបមុខរបរចិញ្ចឹមជីវិត
- គ្មានចំណេះជំនាញពិតប្រាកដ
- ធ្វើការក្នុងស្រុកទទួលបានប្រាក់ចំណូលតិចពេក។

### ៣.២.២. ផ្នែកសុខាភិបាល

ក្នុងឃុំសាន់គយើងខ្ញុំ មានមណ្ឌលសុខភាព០១កន្លែង ដោយបានធ្វើការបម្រើសេវាសុខភាពជូនប្រជាពលរដ្ឋបានគ្រប់ម៉ោងធ្វើការ នៅមណ្ឌលសុខភាព បានទទួលសេវាល្អយ៉ាងកក់ក្ដៅ។ ដើម្បីបម្រើសេវាសុខភាពជូនប្រជាពលរដ្ឋឃុំបានយកចិត្តទុកដាក់ និងចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យមានការយល់ដឹងពីសុខភាព អនាម័យពីការហូបស្អាតផឹកស្អាត និងរស់នៅស្អាត ព្រមទាំងជម្រុញឱ្យពួកគាត់ទៅទទួលសេវាពិនិត្យតាមដានសុខភាពជាប្រចាំ។ ក៏ប៉ុន្តែនៅតែមានចន្លោះប្រហោង និងបញ្ហាប្រឈមមួយចំនួនរួមានៈ

- **ការប្រើប្រាស់ទឹកស្អាត៖** ទូទាំងឃុំសាន់គ បច្ចុប្បន្នមានអណ្ដូងចម្រុះចំនួន២,៥៧៦គ្រួសារ មានអណ្ដូងចំនួន ២៧៨អណ្ដូង ក្នុងនោះមានអណ្ដូងស្នប់ជ្រៅចំនួន០៦ អណ្ដូង គ្រួសារប្រើប្រាស់ទឹកស្រះសហគមន៍ ទឹកបឹងត្រពាំង មានចំនួន១៧៦ គ្រួសារ, គ្រួសារប្រើប្រាស់ទឹកស្អាត និងចម្រោះទឹកស្អាត មានចំនួន ៨៥០ គ្រួសារ។
- **ការប្រើប្រាស់បង្គន់អនាម័យ៖** ចំនួនបង្គន់អនាម័យ សាងសង់ដោយខ្លួនឯង និងមានជួយឧបត្ថម្ភពីដៃគូរអភិវឌ្ឍន៍មានចំនួន១,៥៨៦ បង្គន់។
- ***សុខភាពបន្តពូជ៖*** ឃុំបានធ្វើការផ្សព្វផ្សាយពីបញ្ហាសុខភាពបន្តពូជដល់ប្រជាពលរដ្ឋជារៀងរាល់ឆ្នាំ ដើម្បីឱ្យទៅទទួលសេវាសុខភាពពីមណ្ឌលសុខភាព ជាពិសេសស្ត្រីដែលទើបរៀបអាពាហ៍ពិពាហ៍រួច។
    - ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកំរិត
    - ប្រជាពលរដ្ឋមិនទាន់យល់អំពីបញ្ហាសុខភាព និងអនាម័យ
    - មិនយកចិត្តទុកដាក់ពីបញ្ហាសុខភាព
    - មណ្ឌលសុខភាពកំពុងធ្វើការសាងសង់ថ្មី មិនទាន់រួចរាល់
    - សមត្ថភាពឆ្មបនៅមណ្ឌលសុខភាពនៅមានកំរិត
    - ស្ត្រីនៅសហគមន៍មានចំណេះដឹងស្ដីពីការថែទាំកុមារ និងទារកមានកំរិតទាប
    - បញ្ហាជម្ងឺឆ្លង (ជម្ងឺអេដស៍ របេង គ្រុនចាញ់ គ្រុនឈាម និងជម្ងឺឆ្លងដទៃទៀត)។

### ៣.២.៣. ផ្នែកយេនឌ័រ

ជាមួយគ្នានេះផងដែរ ស្ត្រីជួបនូវបញ្ហាខ្លះៗ មួយចំនួនទទួលរងគ្រោះពីការធ្វើបាបដោយបុរស រំលោភទៅលើផ្លូវកាយ ផ្លូវចិត្ត និងមិនទាន់ផ្តល់បានសមភាពរវាងបុរសស្ត្រី ទៅតាមគោលការណ៍នៅឡើយ។ ចំពោះបញ្ហាទាំងអស់ខាងលើ រាជរដ្ឋាភិបាល ជាពិសេសអាជ្ញាធរពាក់ព័ន្ធនៅ ក្នុងឃុំសាន់គបាននឹងកំពុងយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងបំពេញនៅចន្លោះខ្វះដោយបង្កើនការយកចិត្ត ទុកដាក់លើការអភិវឌ្ឍលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ គមនាគមន៍ផ្សេងៗ ដើម្បីជួយសម្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំសាន់គ ទាំងមូល។ ចំពោះវិស័យផ្សេងៗទៀតដូចជា វិស័យសុខាភិបាល ការសិក្សាអប់រំ សន្តិសុខសុវត្ថិភាព យេនឌ័រ និងវិស័យផ្សេងៗជាច្រើនទៀតក៏ត្រូវបានយកចិត្តទុកដាក់ និងអភិវឌ្ឍន៍ជាបន្តបន្ទាប់ ដើម្បីបំពេញតម្រូវការសម្រាប់ប្រជាពលរដ្ឋនៅក្នុងឃុំសាន់គនោះផងដែរ។ បញ្ហាដែលតែងជួបប្រទះរួមមាន៖

១. មានការខ្មាសអៀនច្រើន

២. មិនមានភាពអង់អាចក្លាហានក្នុងការបញ្ចេញមតិយោបល់

៣. មិនមានទំនុកចិត្តលើខ្លួនឯង។[63]

### ៣.២.៤. ធនធានធម្មជាតិបរិស្ថាន និងការប្រែប្រួលអាកាសធាតុ

- **ការប្រើប្រាស់ដីធ្លី៖** ប្រជាពលរដ្ឋបាននឹងកំពុងចាប់ប្រើប្រាស់ដីលំនៅដ្ឋាន និងដីកសិកម្មដោយស្របច្បាប់ គឺភូមិមួយចំនួនបានចាប់ផ្តើមធ្វើប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីជាផ្លូវការហើយ គឺទើបនឹងចាប់ផ្ញើឯកសារស្នើសុំទៅជំនាញជាលក្ខណៈជាប្រព័ន្ធ ។ បញ្ហារួមមាន៖

- ការកំណត់ដីលំនៅដ្ឋានតែងតែមានទំនាស់ព្រំប្រទល់
- ការផ្លាស់ប្តូរទីតាំងមិនប្រាប់អាជ្ញាធរ
- ការរៀបចំគ្រប់គ្រងសំណង់អនាធិបតេយ្យ និងការរៀបចំប្លង់លំនៅដ្ឋានភាគច្រើនមិនគោរពតាមច្បាប់។

- **ធនធានធម្មជាតិ៖** ឃុំសាន់គ មានធនធានធម្មជាតិសំខាន់ៗដែលមានដូចជា ដីធ្លី ធនធានជលផល បឹង អូរ ស្ទឹង....។ល។ ដែលជាសម្បត្តិធម្មជាតិ ស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនហើយប្រជាពលរដ្ឋពឹងផ្អែកលើធនធានទាំងនេះ សម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់។ បន្ថែមពីលើនេះទៀត គឺឃុំសាន់គ មានសហគមន៍នេសាទចំនួនពីរ (ទី១ សហគមន៍នេសាទសាមគ្គីខ្សែងខ្លែង-កក់ធំ និងទី២ សហគមន៍នេសាទសាមគ្គីអភិវឌ្ឍន៍បឹងស្តុង) ដែលជាភ្នែកច្រមុះ និងជាក្តីរំពឹងក្នុងការបន្តនិរន្តរភាពពូជមច្ឆាជាតិ។ បញ្ហាប្រឈមរួមមាន៖

- នៅតែមានការនេសាទខុសច្បាប់ដោយមានជនទុច្ចរិតមួយចំនួនតូចលួចឆ្លៀតឱកាសឆក់ ដងកូនត្រី

[63] *សៀវភៅកត់ត្រាលម្អិតរយៈពេល៥ឆ្នាំនៅឃុំសាន់គ។*

- ការនេសាទដោយបំពាន យល់ដឹងពីច្បាប់តែនៅតែបំពាន
- ការនេសាទខុសច្បាប់ដោយមិនបានយល់ដឹងពីច្បាប់។

❖ **បរិស្ថាន៖** ប្រជាពលរដ្ឋមានការយល់ដឹងប្រសើរជាងមុនពាក់ព័ន្ធបរិស្ថាន ចេះសម្អាត ចេះថែរក្សាការពារបរិស្ថានបានល្អ និងយល់ដឹងពីសារៈសំខាន់នៃបរិស្ថាន។ បញ្ហាប្រឈមដែលតែងតែកើតមាន៖

- ឃុំខ្វះទីលានចាក់សំរាមនៅតាមបណ្តាភូមិ និងអាងស្តុកសំរាមបណ្តោះអាសន្ន ព្រមទាំងការទុកដាក់សំរាម (កាកសំណល់រឹង រាវ) នៅខ្វះចន្លោះតិចតួច។

❖ **ការប្រែប្រួលអាកាសធាតុ៖** នៅក្នុងឃុំ អាកាសធាតុមានការប្រែប្រួលភ្លៀងមិនទៀងទាត់ជួនមានទឹកជំនន់ ភាពរាំងស្ងួត សីតុណ្ហភាពឡើងខ្ពស់ កម្រិតទឹកភ្លៀងមិនទៀងទាត់ ដែលបណ្តាលឱ្យប៉ះពាល់ដល់ការរស់នៅ និងប្រកបមុខរបរប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋជាពិសេសប៉ះពាល់ដល់ សុខភាពរបស់ពួកគាត់។ ម្យ៉ាងទៀតឃុំបានផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋចេះរស់នៅដោយបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុមានការផ្គត់ផ្គង់ទឹកសម្រាប់សហគមន៍ គ្រួសារ ផ្នែកកសិកម្ម ការដាំកូនឈើឡើងវិញ។ បញ្ហាប្រឈមរួមមាន៖

- កន្លងមកឃុំបានទទួលរងនូវផលប៉ះពាល់នៃការបំផ្លិចបំផ្លាញដោយសារគ្រោះរាំងស្ងួត មានចំនួន ៣៦១ហិកតា និងមានខ្យល់កន្ត្រាក់ប៉ះពាល់១៥០គ្រួសារ ភ្លើងឆេះផ្ទះចំនួន០១គ្រួសារ គ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌមិនទាន់ផ្ទុះគ្មានគ្រោះទឹកជំនន់០០នាក់។ ម្យ៉ាងទៀតឃុំមានទីទួលសុវត្ថិភាពចំនួន០៥កន្លែងសម្រាប់ការពារនៅពេលមានទឹកជំនន់
- ការប្រើប្រាស់ធនធានធម្មជាតិមិនសមស្រប។

### ៣.២.៥. គ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

❖ **អភិបាលកិច្ច៖**

បញ្ហាប្រឈមរួមមាន

- លំបាកក្នុងការប្រមូលប្រជាពលរដ្ឋចូលរួមប្រជុំផ្សេងៗ
- ការងារ ជាន់ពេលគ្នាច្រើន
- ប្រជាពលរដ្ឋមិនសូវយកចិត្តទុកដាក់ និងចូលរួមសហការ។

❖ **ការគ្រប់គ្រងស្ថិតិ៖**

បញ្ហាប្រឈមរួមមាន៖

- ប្រជាពលរដ្ឋខ្វះការទុកដាក់ និងរក្សាឯកសារឱ្យបានល្អ
- ក្រុមប្រឹក្សាឃុំមានការងារប្រចាំថ្ងៃច្រើន
- ការងារបច្ចេកទេសមានការផ្លាស់ប្តូរច្រើន។

- **ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ៖**

បញ្ហាប្រឈមរួមមាន៖

- គ្រោះថ្នាក់ចរាចរណ៍នៅតែមានកើតឡើងដោយខ្វះការគោរពច្បាប់
- អំពើហិង្សា
- ក្មេងពាលនៅមានម្តងម្កាល
- ការលេងល្បែងស៊ីសង
- ការប្រើប្រាស់គ្រឿងញៀន។

## ៣.៣. ដំណោះស្រាយ

ដើម្បីឱ្យការអនុវត្តការងារនៅថ្នាក់ឃុំ សង្កាត់ឱ្យមានភាពល្អប្រសើរ និងប្រសិទ្ធភាព ប្រធានក្រុមប្រឹក្សាឃុំបានកំពុងយកចិត្តទុកដាក់ នឹងស្វាសស្វែងរកយុទ្ធសាស្ត្រដោះស្រាយបញ្ហាប្រឈមផ្សេងៗដែលតែងតែកើតមានឡើងនៅឃុំសង្កាត់របស់ខ្លួន។ យើងបានសង្កេតឃើញថាបញ្ហាប្រឈមដែលត្រូវដោះស្រាយមានដូចខាងក្រោម៖

### ៣.៣.១. ផ្នែកអប់រំ

ការអប់រំជាតម្រូវការបន្ទាន់ និងចាំបាច់សម្រាប់ការអភិវឌ្ឍធនធានមនុស្សនៅក្នុងឃុំ សង្កាត់ឱ្យកាន់តែមានការរីកចម្រើន។ ប៉ុន្តែស្ថានភាពអប់រំនៅក្នុងឃុំសាន់គមិនទាន់ល្អប្រសើរឡើយ ដោយសារ មិនមានការសហការអំពីអាណាព្យាបាលអំពីបញ្ហានេះ ដូច្នេះហើយប្រធានក្រុមប្រឹក្សាបានដាក់ចេញនូវដំណោះស្រាយដូចជា៖

- **ជំនួបរវាងក្រុមប្រឹក្សា និងគ្រូៗគ្រប់កម្រិតថ្នាក់៖** ការជំនួបរវាងក្រុមប្រឹក្សាជាមួយ និងលោកគ្រូអ្នកគ្រូនេះ គឺមានគោលដៅអំពីការផ្តល់មតិយោបល់ អំពីបញ្ហាចោទ នៃការបោះបង់ការសិក្សារបស់កុមារ និងផលប៉ះពាល់ដើម្បីឱ្យលោកគ្រូអ្នកគ្រូជួយសហកាបន្ថែមនឹងឈានរកទៅភាពល្អប្រសើរ។
- **ជំនួបរវាងគ្រូ និងអាណាព្យាបាលសិស្ស៖** វាពិតជាមានសារៈសំខាន់ណាស់ក្នុងការឱ្យគ្រូមានទំនាក់ទំនងជាមួយ និងអាណាព្យាបាលសិស្សកាន់តែស្និតស្នាលដើម្បីតាមដានអំពីការសិក្សារបស់កូនៗនិងបានបង្ហាញអំពីបញ្ហាចោទទៅកាន់នៃផលវិបាកនៃការបោះការសិក្សារបស់កុមារ។
- **ការផ្តល់ជាជំនួយជាអារូបករណ៍៖** នៅក្នុងឃុំសាន់គ ក៏មានការឧបត្ថម្ភជាជំនួយអាហារូបករណ៍ដល់គ្រួសារក្រីក្រ ឱ្យទទួលបានថវិកា និងសម្ភារៈខ្លះៗដើម្បីជួយសម្រួលដល់បន្ទុកគ្រួសារដែលខ្វះខាតខ្លាំង ដើម្បីឱ្យកូនៗមានឱកាសបានចូលរៀន។ ដែលមានការសហការអំពីឃុំសង្កាត់ និងអង្គការក្រៅរដ្ឋាភិបាល។

### ៣.៣.២. ផ្នែកសុខាភិបាល

ដំណោះស្រាយសម្រាប់ផ្នែកសុខាភិបាលរួមមាន៖

- ការឧបត្ថម្ភថ្នាំសង្កូវដោយឥតគិតថ្លៃសម្រាប់កុមារ និងមនុស្សចាស់នៅតាមមណ្ឌលសុខភាព

- ដើម្បីបម្រើសេវាសុខភាពជូនប្រជាពលរដ្ឋហើយឃុំសាន់គបានយកចិត្តទុកដាក់ និងចុះផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋយល់ដឹងពីសុខភាព អនាម័យពីការហូបស្អាតផឹកស្អាត និងរស់នៅស្អាតព្រមទាំងជម្រុញឱ្យពួកគាត់ទៅទទួលសេវាពិនិត្យតាមដានសុខភាពជាប្រចាំ
- ធ្វើការអប់រំអំពីអនាម័យសុខភាព និងការថែទាំប្រើប្រាស់អណ្តូង និងបង្គន់ដល់ប្រជាពលរដ្ឋតាមរយៈការផ្សព្វផ្សាយតាមភូមិឃុំ និងការចុះទៅជួបជាមួយប្រជាពលរដ្ឋផ្ទាល់ទៅភូមិនីមួយៗ
- ការផ្សព្វផ្សាយលក់សម្ភារៈអនាម័យសម្រាប់ប្រជាពលរដ្ឋដោយតម្លៃថោកសមរម្យ(ការធ្វើបង្គន់ ធុងចម្រោះទឹកស្អាត សម្ភារៈប្រើប្រាស់ផ្សេងៗ...)
- ការផ្តល់ជូននៅថ្នាំសម្លាប់សត្វល្អិតផ្សេងៗជូនប្រជាពលរដ្ឋ
- ឃុំបានធ្វើការផ្សព្វផ្សាយពីបញ្ហាសុខភាពបន្តពូជដល់ប្រជាពលរដ្ឋជារៀងរាល់ឆ្នាំ ដើម្បីឱ្យទៅទទួលសេវាសុខភាពពីមណ្ឌលសុខភាព ជាពិសេសស្ត្រីដែលទើបរៀបអាពាហ៍ពិពាហ៍រួចអំពីការពន្យាកំណើតដោយសុវត្ថិភាព
- នៅមណ្ឌលសុខភាពមានការការទទួលសេវា ត្រួតពិនិត្យសុខភាពទាក់ទងនឹងបញ្ហាកាមរោគផ្សេងៗដោយឥតគិតថ្លៃ។

### ៣.៣.៣. ផ្នែកយេនឌ័រ

បច្ចុប្បន្ននេះ នៅក្នុងមូលដ្ឋានមានស្ត្រីចូលរួមក្នុងការដឹកនាំភូមិឃុំជាមួយគ្នានោះស្ត្រីមានសិទ្ធិចូលរួមបញ្ចេញមតិយោបល់ និងការធ្វើសេចក្តីសម្រេចចិត្ត ហើយក៏ទទួលបាននូវផលប្រយោជន៍ សមស្របពីសង្គមស្ត្រីមានសិទ្ធិសេរីភាពពេញលេញក្នុងការរស់នៅ និងប្រកបការងារដោយមានការពារដោយច្បាប់។

- ជម្រុញប្រជាពលរដ្ឋចូលរួមក្នុងកិច្ចប្រជុំឱ្យបានច្រើន៖ នៅក្នុងន័យនេះលើកទឹកចិត្តឱ្យមានការចូលរួម កិច្ចប្រជុំទាំងបុរស និងស្ត្រីដោយមិនមានការបែកចែកអំពីភេទនោះទេ ដើម្បីឱ្យពួកគាត់បញ្ចេញមតិឬដោះដូរមតិគំនិតយោបល់គ្នា នោះពួកគាត់នឹងមានការយល់ដឹងទូលំទូលាយអំពីសកម្មភាពភាពពួកគាត់អាចចូលរួមបាន។
- ជម្រុញស្ត្រីឱ្យមានការចូលរួមបញ្ចេញមតិយោបល់៖ ការផ្តល់សិទ្ធិដល់ស្ត្រីក្នុងការផ្តល់ឱកាសឱ្យពួកគាត់ក្នុងការចូលរួមបញ្ចេញនូវមតិយោបល់ដូចជាសកម្មភាពផ្សេងៗនៅក្នុងសង្គមឱ្យបានច្រើន។
- ជម្រុញស្ត្រីឱ្យមានភាពអង់អាចក្លាហាន៖ ផ្តល់ឱកាសឱ្យពួកគាត់ទទួលបានក្នុងការសម្រេចចិត្តធ្វើអ្វីមួយ យល់ស្របជាមួយពួកគាត់ សម្របសម្រួលជាមួយពួកគាត់ លើកទឹកចិត្ត បង្ហាញផ្លូវ គាំទ្រ។

### ៣.៣.៤. ធនធានធម្មជាតិបរិស្ថាន និងការប្រែប្រួលអាកាសធាតុ

- **ការប្រើប្រាស់ដីធ្លី៖** ដើម្បីជៀសវាងបញ្ហាដែលតែងតែកើតមានទាក់ទងជាមួយការប្រើប្រាស់ដីមិនសមស្រប ការអនុវត្តនៃការកំណត់ដីលំនៅដ្ឋានតែងតែមានទំនាស់ព្រំប្រទល់ ការផ្លាស់ប្តូរទីតាំងមិនប្រាប់

អាជ្ញាធរ ការរៀបចំគ្រប់គ្រងសំណង់អនាធិបតេយ្យ និងការរៀបចំប្លង់លំនៅដ្ឋានភាគច្រើនមិនគោរពតាមច្បាប់ អាជ្ញាធរពាក់ព័ន្ធបានដាក់ចេញនូវដំណោះស្រាយជូនដូចជា៖

- ការផ្សព្វផ្សាយអំពីច្បាប់ភូមិបាលជូនទៅប្រជាពលរដ្ឋឱ្យពួកគាត់មានការយល់ដឹងកាន់តែទូលំទូលាយអំពីច្បាប់នេះ
- ការចុះបញ្ជីកាន់កាប់ និងប្រើប្រាស់ដីធ្លីឱ្យត្រឹមត្រូវតាមច្បាប់ណែនាំ
- រៀបចំទុកដាក់ និងរក្សាឯកសារពាក់ព័ន្ធឱ្យបានល្អត្រឹមត្រូវ(ប្លង់រឹង)។

❖ **ធនធានធម្មជាតិ៖** នៅក្នុងឃុំ សាន់គមានធនធានជលផលដែលជាធនធានធម្មជាតិ ហើយមានការសង្កេតឃើញថាប្រជាពលរដ្ឋមួយចំនួននៅក្នុងតំបន់នៅតែមានការនេសាទខុសច្បាប់ ទោះបីជាមានការគាំពារពីសំណាក់អាជ្ញាធរក៏ដោយ។ អាជ្ញាធរនៅឃុំសាន់គបានកំពុងបន្តរិតបន្តឹងបន្ថែម ដើម្បីឱ្យមានការកាត់បន្ថយក៏ដូចជាការនេសាទខុសច្បាប់៖

- កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់នៅលើបឹងទន្លេសាបនានា
- ពង្រឹង និងពង្រីកអាជ្ញាធរបន្ថែមដែលមានសមត្ថកិច្ចពាក់ព័ន្ធចុះត្រួតពិនិត្យនៅបឹងទន្លេសាប
- តម្រូវឱ្យមានការចុះផ្សព្វផ្សាយអំពីច្បាប់ពាក់ព័ន្ធជូនដល់ប្រជាពលរដ្ឋឱ្យបានជ្រាប និងមានការយល់ដឹងឱ្យបានទូលំទូលាយ
- តម្រូវឱ្យមានការប្រជុំជួបជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរនៅក្នុងតំបន់ ណែនាំអំពីបញ្ហាប្រឈមនៃការនេសាទខុសច្បាប់
- អ្នកដែលនេសាទខុសច្បាប់ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

❖ **បរិស្ថាន៖** នៅក្នុងឃុំសាន់ ការទុកដាក់ ឬបោះចោលសម្រាមនៅតាមដងផ្លូវ គឺពុំមានចោទបញ្ហានោះទេ ប៉ុន្តែបញ្ហាដែលឃើញនៅកើតមាន គឺការទុកដាក់សំរាមតាមលំនៅដ្ឋាននៅពុំទាន់មានរបៀបរៀបរយល្អនោះទេដោយសារពួកគាត់ពុំបានយល់ដឹងអំពីការទុកសំណល់រឹងសំណល់រាវ និងពុំទាន់ការចេះកែច្នៃសំរាមឱ្យមានប្រយោជន៍។ ដំណោះស្រាយសម្រាប់បញ្ហាចោទនេះរួមមាន៖

- បង្កើតឱ្យមានទីលានចាក់សំរាមឱ្យបានត្រឹមត្រូវ កុំឱ្យមានច្រើនកន្លែងពេក
- បង្កើតឱ្យមានអាងស្តុកសំរាមបណ្តោះអាសន្ន
- ចាត់វិធានចុះផ្សព្វផ្សាយ អំពីការណែនាំការទុកដាក់សំរាម
- ការបង្រៀនប្រជាពលរដ្ឋអំពីការកែច្នៃសំរាមឱ្យមានប្រយោជន៍( កែច្នៃសំរាមនិងសំណល់ធ្វើជាជី)។

❖ **ការប្រែប្រួលអាកាសធាតុ៖** ទាក់ទងជាមួយបញ្ហានេះផងដែរ នៅក្នុងឃុំសាន់គបានបង្កើតឱ្យមាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយសម្រាប់ដោះស្រាយរាល់បញ្ហាគ្រោះមហន្តរាយផ្សេងៗដែលកើតមាន៖

- អនុវត្តគោលនយោបាយដែលទាក់ទងទៅនឹងការគ្រប់គ្រងគ្រោះមហន្តរាយ
- កសាងផែនការត្រៀមបង្ការកាត់បន្ថយគ្រោះថ្នាក់ ត្រៀមរៀបចំដើម្បីការពារអាយុជីវិត មនុស្សសត្វ
- សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព ផលិតផលកសិកម្ម សេវាសាធារណៈ បរិស្ថាន និងអនុវត្តដើម្បីកាត់បន្ថយគ្រោះភ័យ នៅពេលមានមុខសញ្ញាគ្រោះថ្នាក់ពីធម្មជាតិ និងពីមនុស្សកើតឡើង
- សម្របសម្រួលផែនការខាងលើជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក
- រៀបចំបង្កើត និងគ្រប់គ្រងទីសុវត្ថិភាព
- រៀបចំគោលការណ៍ណែនាំ អនុវត្ត និងគាំទ្រសកម្មភាពគ្រប់គ្រងគ្រោះភ័យ នៃគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍
- ជាសេនាធិការរបស់គណៈកម្មការ គ្រប់គ្រងគ្រោះមហន្តរាយស្រុកក្នុងការងារកាត់បន្ថយគ្រោះមហន្តរាយ និងផ្តល់យោបល់ពីសកម្មភាពរបស់ស្ថាប័នពាក់ព័ន្ធ សមាគមជាតិ ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ដែលរួមចំណែកក្នុងការកាត់បន្ថយគ្រោះមហន្តរាយ និងភាពងាយរងគ្រោះនៅមុនពេលក្នុងពេល និងក្រោយពេលមានគ្រោះមហន្តរាយ។

### ៣.៣.៥. គ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

❖ **អភិបាលកិច្ច៖** ឃុំបានធ្វើការដឹកនាំការងារប្រកបដោយប្រសិទ្ធិភាពតម្លាភាព និងមានគណនេយ្យភាពចំពោះការងារនឹងប្រជាពលរដ្ឋរបស់ខ្លួន មិនតែប៉ុណ្ណោះឃុំបានធ្វើការបែងចែកការគ្រប់គ្រងការងារទៅតាមទីតាំង និងមណ្ឌលសំខាន់ៗ ដើម្បីងាយស្រួលគ្រប់គ្រង និងដឹកនាំចាត់ចែងការងារឱ្យបានល្អ និងទាន់តាមតម្រូវការរបស់ថ្នាក់លើ។

❖ **ការគ្រប់គ្រងស្ថិតិ៖** រាល់លិខិតបទដ្ឋាន ឃុំបានប្រកាស ឬបិទផ្សាយជាបន្តបន្ទាប់។ ចំណែកឯការងារអត្រានុកូលដ្ឋាន គឺប្រជាពលរដ្ឋខ្វះការយកចិត្តទុកដាក់នៅឡើយ លុះត្រាមានការចាំបាច់ទើបទៅសាលាឃុំ ហើយឃុំបានផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋមកចុះបញ្ជីអត្រានុកូលដ្ឋាននៅសាលាឃុំ។

- ការចុះបញ្ជីអត្រានុកូលដ្ឋានឆ្នាំ ២០២២
- ចុះសំបុត្រកំណើត ចំនួន ២៤៥ នាក់
- ចុះលិខិតបញ្ជាក់កំណើត ចំនួន ៨៧៥ នាក់
- ចុះលិខិតអាពាហ៍ពិពាហ៍ ចំនួន ៣៧១ នាក់
- ចុះលិខិតមរណភាព ចំនួន ៤៦ នាក់

- **សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**៖ ចំពោះបញ្ហាសន្តិសុខមិនសូវចោទជាបញ្ហាប៉ុន្មានទេដោយឃុំបានរៀបចំកំលាំងប្រជាការពារតាមភូមិរួមសហការណ៍ជាមួយ និងកំលាំងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំចុះល្បាតតាមភូមិពេលមានហេតុការណ៍អ្វីកើតឡើងរាយការណ៍បានទាន់ពេលវេលា។
  - មានការចុះផ្សព្វផ្សាយពីច្បាប់ចរាចរណ៍ ការទប់ស្កាត់អំពើហិង្សា ផលប៉ះពាល់នៃគ្រឿងញៀន និងល្បែងស៊ីសងផលប៉ះពាលនៃការនេសាទមិនត្រឹមត្រូវតាមរដូវកាល និងប្រើឧបករណ៍ខុសច្បាប់តាមមូលដ្ឋាន ជាពិសេសសាលារៀន វេទិការសាធារណៈក្នុងឃុំជាដើម។
  - ការបណ្តុះបណ្តាលផ្នែកអប់រំក្នុងការរស់នៅបន្ថែម។[64]

[64] *សៀវភៅនិងឯកសារតម្កល់របស់ឃុំសាន់គ។*

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ គឺជាការធ្វើកំណែទម្រង់ដឹកនាំឃុំ សង្កាត់តាមរបបប្រជាធិបតេយ្យ ដែលផ្តល់សេរីភាពពេញលេញក្នុងការឱ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍន៍មូលដ្ឋានដើម្បីបម្រើផលប្រយោជន៍ក្នុងឃុំ សង្កាត់របស់ខ្លួន តាមរយៈការចាត់ចែង មើលថែ ប្រើប្រាស់ថវិកា និងការផ្តល់ សេវាសាធារណៈឱ្យមានប្រសិទ្ធភាពពីមន្ត្រីទៅកាន់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន។ វិមជ្ឈការឃុំ សង្កាត់មានទិសដៅជម្រុញឱ្យប្រជាពលរដ្ឋបានចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពក្នុងឃុំ សង្កាត់ និងដំណើរការនៃការអភិវឌ្ឍមូលដ្ឋាន និងការចូលរួមចំណែកតាមមធ្យោបាយផ្សេងៗ។

ឆ្លងកាត់តាមរយៈការស្រាវជ្រាវទៅលើប្រធានបទដែលស្តីអំពី «ការគ្រប់គ្រងរដ្ឋបាលឃុំសាន់គស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ (២០២២-២០២៤) បានបង្ហាញឱ្យដឹងថាឃុំសាន់គ មានសេដ្ឋកិច្ចរីកចម្រើន ការរក្សាសណ្តាប់ធ្នាប់សន្តិសុខសាធារណៈ រួមទាំងលើកកម្ពស់វិស័យអប់រំ និងការ រស់នៅរបស់ប្រជាពលរដ្ឋក្នុងគោលដៅកាត់បន្ថយអនក្ខរកម្ម ជាពិសេសប្រជាពលរដ្ឋរស់នៅតាមទីជនបទ និងតំបន់ដាច់ស្រយាលឱ្យមានលក្ខណៈល្អប្រសើរ សំដៅដល់ការកាត់បន្ថយភាពក្រីក្រ និងការរស់នៅប្រកបដោយ សន្តិភាព និងសុខសុវត្ថិភាព។ ទន្ទឹមនឹងនេះ រដ្ឋបាលឃុំមានបេសកកម្មក្នុងការកែលម្អរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ឃុំឱ្យស្របនឹងចរិតលក្ខណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអភិវឌ្ឍសមត្ថភាព លើកិច្ចការងាររដ្ឋបាលស្រុកតាមរយៈការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (អភិបាលកិច្ចឌីជីថល) រួមទាំងបង្កើត ឱ្យមានវឌ្ឍភាពលើគ្រប់វិស័យ ដោយទទួលបាននូវកំណើនខ្ពស់ដើម្បីឈានទៅសម្រេចឱ្យបាននូវសូចនាករគោលដៅអភិវឌ្ឍន៍របស់ខ្លួន។

ស្របពេលជាមួយគ្នានេះដែរ នៅក្នុងឆ្នាំ២០២២មកដល់២០២៤ទោះបីជាការគ្រប់គ្រងរបស់រដ្ឋបាលឃុំសាន់គ បានសម្រេចនូវសមិទ្ធផលលើការសេវាសារណៈលើ វិស័យអប់រំ យេនឌ័រ សុខាភិបាល ធនធានធម្មជាតិនិងបរិស្ថានក៏ដោយ ក៏នៅតែជួបប្រទះនូវបញ្ហាប្រឈមមួយ ចំនួនដែលពាក់ព័ន្ធគ្នារវាងប្រជាពលរដ្ឋ និងមន្ត្រី ឬអាជ្ញាធរមានសមត្ថកិច្ច ហើយវាជាបញ្ហាចោទដ៏សំខាន់ដែល រដ្ឋបាលឃុំត្រូវពង្រឹងលើផែនការអនុវត្តន៍ វិះរកយុទ្ធសាស្ត្រ និងចាត់វិធានការសម្រាប់ដោះស្រាយជាចាំបាច់ ដើម្បីឱ្យស្រុកកាន់តែមានភាពរីកចម្រើន និងជៀសវាងការបង្កឱ្យមានអសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងអំពើអបាយមុខផ្សេងៗនៅក្នុងមូលដ្ឋាន។ បញ្ហាទាំងនោះរួមមានដូចជា ១) ការមិនយល់ព្រមចូលរួមសហការ របស់ប្រជាពលរដ្ឋជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការចូលរួមអភិវឌ្ឍន៍សហគមន៍ ជាពិសេសពាក់ព័ន្ធនឹងបញ្ហាបរិស្ថានដូចជា ការបោះចោលសំរាមចូលក្នុងប្រភពទឹក ការកាប់បំផ្លាញព្រៃឈើជាដើម។ ២) បទពិសោធរបស់បុគ្គលិក ឬមន្ត្រីរាជការមួយចំនួនតូចនៅមានកម្រិត គួបផ្សំនឹងការមិនចូលរួមក្នុងវគ្គបណ្តុះបណ្តាលលើ

ជំនាញពាក់ព័ន្ធផ្សេងៗច្បាស់លាស់។ ៣) កង្វះមន្ត្រីសម្រាប់បំពេញការងារនៅក្នុងមូលដ្ឋានដែលបណ្តាលឱ្យការ អនុវត្តការងារមានភាពយឺតយ៉ាវ រួមទាំងជះឥទ្ធិពលអវិជ្ជមានដល់ការដឹកនាំ និងគ្រប់គ្រងស្រុក។ ទោះជាមាន បញ្ហាទាំងអស់នេះកើតឡើងក៏ដោយ ប៉ុន្តែរដ្ឋបាលឃុំសាន់គនៅតែអាចបន្តការអភិវឌ្ឍក្នុងកិច្ចការងាររបស់ ខ្លួនបានដោយទទួលបាននូវសមិទ្ធផល និងការរីកចម្រើនជាច្រើន។

ជាមួយគ្នានេះដែរ ឃុំសាន់គក៏បានអនុវត្ត ដំណោះស្រាយស្របទៅតាមច្បាប់ អនុក្រឹត្យ គោលនយោបាយ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តផ្សេងៗរបស់ រាជរដ្ឋាភិបាលទាក់ទងនឹងការគ្រប់គ្រង ពោលគឺរដ្ឋបាលឃុំសាន់គបានអនុវត្តបាននូវគោលការណ៍លើក កម្ពស់គុណភាពជីវិត និងការរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការអភិវឌ្ឍស្រុកប្រកបដោយចីរភាព សន្តិសុខ សណ្តាប់ធ្នាប់ ការអប់រំ ស្ថិរភាពនយោបាយ ការរក្សាបាននូវបរិស្ថានល្អ អភិបាលកិច្ចល្អ សមធម៌សង្គម និង ប្រសិទ្ធភាពក្នុងការផ្តល់ជូនសេវាសាធារណៈដល់ប្រជាពលរដ្ឋ ដើម្បីឱ្យសេដ្ឋកិច្ច និងកិច្ចបំពេញការងាររបស់ ឃុំសាន់គប្រព្រឹត្តទៅបានល្អប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ព្រមទាំងជាមូលដ្ឋានគ្រឹះជួយ ឱ្យឃុំមានការរីកចម្រើនយ៉ាងឆាប់រហ័សក្នុងឆ្នាំបន្តបន្ទាប់ទៀត។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សា ទាំងទ្រឹស្តី និងការចុះកម្មសិក្សាផ្ទាល់ដែលមានការសម្ភាន៍ផ្ទាល់ជាមួយក្រុមប្រឹក្សាឃុំសាន់គ មេឃុំសាន់គ និងមន្ត្រីថ្នាក់ក្រោមដែលបម្រើការងារក្នុងឃុំសាន់គជាច្រើនរូបរួចមក សង្កេតឃើញថា អាជ្ញាធរដែលបម្រើការងារនៅទីនោះ  បានចូលរួមយ៉ាងសកម្មក្នុងការប្រើសេវាជូនប្រជាពលរដ្ឋប្រកមដោយ  គុណភាព សមភាព គុណធម៌ សុជីវធម៌ជាមន្ត្រីរាជការ រហ័សរហួន ធ្វើឱ្យប្រជាពលរដ្ឋមានទំនុកចិត្តទទួលបានការពេញចិត្ត និងកោតសសើរ ប្រជាពលរដ្ឋទទួលបានបានការបម្រើសេវាយ៉ាងពេញចិត្ត ចំណេញទាំងពេលវេលា ថវិកា និងទំនុកចិត្តខ្ពស់។ ហើយនៅឃុំសាន់គចាប់ពីអាណត្តិទី៤មកដល់២០២៤សង្កេតឃើញថាពុំមានបញ្ហាពាក់ព័ន្ធអំពីបញ្ហាពុករលួយការកៀប ឬគេងប្រវ័ញ្ចអំពីសំណាក់ប្រជាពលរដ្ឋរបស់មន្ត្រីរាជការដែលបម្រើការងារនៅទីនោះឡើយ។ ប៉ុន្តែអ្វីដែលខ្ញុំចង់ផ្តល់ជាសំណូមពរមានមួយចំនួនដូចជា៖

- អាជ្ញាធរត្រូវប្រជុំ និងផ្តល់ព័ត៌មានរាយការដល់ប្រជាពលរដ្ឋអំពីការធ្វើលិខិតស្នាមផ្សេងៗឱ្យបានទូលំទូលាយ។
- បង្កើនការប្រាស្រ័យទាក់ទងគ្នារវាងរដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពពាក់ព័ន្ធ និងដៃគូសហការនានា ដើម្បីជួយជម្រុញការអភិវឌ្ឍបានល្អប្រសើរ និងស្របតាមគោលដៅរាជរដ្ឋាភិបាល ចង់ឱ្យសម្រេចបាន។
- សូមឱ្យក្រុមប្រឹក្សាឃុំសង្កាត់អនុវត្តសិទ្ធអំណាច និងគណនេយ្យភាពរបស់ខ្លួនឱ្យស្របតាមច្បាប់ និងលិខិបទដ្ឋានគតិយុត្តដែលកំណត់ឱ្យ។
- អាជ្ញាធរត្រូវប្រជុំ និងផ្តល់ព័ត៌មានរាយការដល់ប្រជាពលរដ្ឋអំពីការធ្វើលិខិតស្នាមផ្សេងៗឱ្យបានទូលំទូលាយ។
- បង្កើតឱ្យមានមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្សបន្ថែមទៀតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់នូវចំណេះដឹង ជំនាញ ការច្នៃប្រឌិតការងារ ការធ្វើការងារជាក្រុម ការប្រើប្រាស់ព័ត៌មានវិទ្យាភាសា និងឥរិយាបថក្នុងនាមជាមន្ត្រីរាជការ និងសមត្ថភាពពេញលេញក្នុងនាមជាអ្នកដឹកនាំ និងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពខ្ពស់។
- បង្កើនការប្រាស្រ័យទាក់ទងគ្នារវាងរដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពពាក់ព័ន្ធ និងដៃគូសហការនានា ដើម្បីជួយជម្រុញការអភិវឌ្ឍបានល្អប្រសើរ និងស្របតាមគោលដៅរាជរដ្ឋាភិបាលចង់ឱ្យសម្រេចបាន។

- បើកវេទិកាសាធារណៈឱ្យបានញឹកញាប់ ដើម្បីទទួលបានការរាយការណ៍រាល់បញ្ហាប្រឈមនានាដែលកើតមាននៅក្នុងរដ្ឋបាលស្រុក ខណ្ឌ ឃុំ-សង្កាត់ រួចរកដំណោះស្រាយជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា ពោល គឺចៀសវាងការអនុវត្តការងារមានភាពយឺតយ៉ាវ។

# ឯកសារយោង

# ឯកសារយោង

៙📖៚

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១។
- ច្បាប់ស្តីពីការ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់, ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥។
- ច្បាប់ស្តីពីវិសោធកម្មច្បាប់បោះឆ្នោត, ព្រះរាជក្រមលេខ នស/០៧២៣/០១០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣។
- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨។
- អនុក្រឹត្យលេខ ២៦ អនក្រ.កប ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់។
- ប្រកាសលេខ ២៨១៥ ប្រ.ក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការទទួលស្គាល់សមាសភាព ប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំ នៃឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

## ២. សៀវភៅនៃឯកសារ

- នីតិរដ្ឋបាលទូទៅ  សាស្ត្រាចារ្យ ហៀង សាង
- នីតិមុខងារសាធារណៈ សាស្ត្រាចារ្យ  ហៀង សាង
- នីតិរដ្ឋបាលទូទៅ បណ្ឌិត សាយ បូរី ឆ្នាំ២០០៦
- វិមជ្ឈការនៅប្រទេសកម្ពុជា លី វ៉ុង ឆ្នាំ២០១៧
- ក្រសួងមហាផ្ទៃ, ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា ឆ្នាំ ២០១៨
- សៀវភៅស្តីពី ស្ថានភាពសេដ្ឋកិច្ចនិងសង្គមកិច្ចនៅឃុំសាន់គ
- សៀវភៅផែនការរំកិល៥ឆ្នាំរបស់ឃុំសាន់គ។

## ៣. ឯកសារ និងរបាយការណ៍

- ឯកសារស្តីពី ប្រវត្តិនៃការកកើត ទឹកដី និងសមិទ្ធិផលនានាក្នុងឃុំ សាន់គ
- ឯកសារតម្កល់របស់ឃុំសាន់គដែលពាក់ព័ន្ធនៅក្នុងឃុំសាន់គ
- សន្និបាតបូកសរុប ការងារគណៈកម្មាធិការគណបក្ស និងក្រុមប្រឹក្សាឃុំក្នុងអាណត្តិទី៥(២០២២-បច្ចុប្បន្ន)
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២ ២០២៣
- កំណត់ហេតុនៃការប្រជុំវិសាមញ្ញលើកទី៤របស់ក្រុមប្រឹក្សាឃុំអាណត្តិទី៥ ដើម្បីពិភាក្សាគ្នា និងអនុម័តលើគម្រោងថវិកាឆ្នាំ២០២៤។

# ឧបសម្ព័ន្ធ

# មាតិកាឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធរូបភាព

មាតិកាឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី១៖ ផែនទីបង្ហាញពីឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
- ឧបសម្ព័ន្ធទី២៖ ផែនទីព្រំប្រទល់រដ្ឋបាល ឃុំសាន់គ
- ឧបសម្ព័ន្ធទី៣៖ ផែនទីគម្រោងវិនិយោគឃុំសាន់គ
- ឧបសម្ព័ន្ធទី៤៖ ផែនទីប្រើប្រាស់ដីសាមញ្ញឃុំសាន់គ
- ឧបសម្ព័ន្ធទី៥៖ ផែនទីហេដ្ឋារចនាសម្ព័ន្ធឃុំសាន់គ
- ឧបសម្ព័ន្ធទី៦៖ ផែនទីប្រព័ន្ធធារាសាស្ត្រឃុំសាន់គ
- ឧបសម្ព័ន្ធទី៧៖ រូបភាពសាលាឃុំសាន់គជាក់ស្តែងពេលបច្ចុប្បន្ន
- ឧបសម្ព័ន្ធទី៨៖ ថតរូបជាមួយមេឃុំ និងក្រុមប្រឹក្សាឃុំសាន់គ
- ឧបសម្ព័ន្ធទី៩៖ និមិត្តសញ្ញារដ្ឋបាលឃុំសាន់គ។

## ២. ឧបសម្ព័ន្ធគតិយុត្តិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១។
- ច្បាប់ស្តីពីការ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់, ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥។
- ច្បាប់ស្តីពីវិសោធកម្មច្បាប់បោះឆ្នោត, ព្រះរាជក្រមលេខ នស/០៧២៣/០១០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣។
- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨
- ប្រកាសលេខ ២៨១៥ ប្រ.ក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំ នៃឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

# ឧបសម្ព័ន្ធរូបភាព

## ឧបសម្ព័ន្ធទី១៖ ផែនទីបង្ហាញពីឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ



# ឧបសម្ព័ន្ធទី២៖ ផែនទីព្រំប្រទល់រដ្ឋបាល ឃុំសាន់គ



# ឧបសម្ព័ន្ធទី៣៖ ផែនទីគម្រោងវិនិយោគឃុំសាន់គ



# ឧបសម្ព័ន្ធទី៤៖ ផែនទីប្រើប្រាស់ដីសាមញ្ញឃុំសាន់គ



# ឧបសម្ព័ន្ធទី៥៖ ផែនទីហេដ្ឋារចនាសម្ព័ន្ធឃុំសាន់គ



# ឧបសម្ព័ន្ធទី៦៖ ផែនទីប្រព័ន្ធធារាសាស្ត្រឃុំសាន់គ



## ឧបសម្ព័ន្ធទី៧៖ រូបភាពសាលាឃុំសាន់គជាក់ស្តែងពេលបច្ចុប្បន្ន



## ឧបសម្ព័ន្ធទី៧៖ រូបភាពថតជាមួយមេឃុំ និងក្រុមប្រឹក្សាឃុំសាន់គ



# ឧបសម្ព័ន្ធទី៨៖ និមិត្តសញ្ញារដ្ឋបាលឃុំសាន់គ

- រូបរាងនៃនិមិត្តសញ្ញារដ្ឋបាលឃុំសាន់គ៖មានរាងមូលពងក្រពើ
- ពណ៌ខៀវ៖តំណាងឱ្យភាពស្មោះត្រង់ ចំណេះដឹង ជំនឿចិត្ត ការទទួលខុសត្រូវ និងការសាមគ្គីភាពខ្ពស់
- ពណ៌ក្រហម៖បង្ហាញពីអំណាច ថាមពល សេចក្តីក្លាហាន រឹងមាំ និងការពុះពារតស៊ូព្យាយាមអំណត់អត់ធ្មត់
- ពណ៌ស៖តំណាងឱ្យភាពបរិសុទ្ធ សន្តិភាព សេចក្តីសង្ឃឹម និងសេចក្តីជ្រះថ្លាល្អ
- ពណ៌បៃតង ៖បង្ហាញពីធម្មជាតិតំណាងឱ្យសុខភាព ជីវិត និងជីវជាតិ ដែលសំបូររុងរឿង
- ពណ៌មាស៖តំណាងឱ្យគុណតម្លៃ និងវិសាលភាពនៃភាពសប្បាយរីករាយ សេចក្តីសុខ និងភាពវៃឆ្លាតនៃប្រាជ្ញាស្មារតី ដែលជាគំនិតសុទិដ្ឋិនិយមដោយផុសចេញពីបេះដូង ឬ សេចក្តីស្រឡាញ់ពិតៗ
- អក្សរ(ឃុំសាន់គ)៖តំណាងឱ្យឈ្មោះរដ្ឋបាលឃុំសាន់គ
- ដែលមានវត្តប្រាសាទអណ្តែត៖តំណាងឱ្យសាសនា និងការអប់រំ
- ប្រាសាទបូរាណ៖តំណាឱ្យមរតកដូនតា វប្បធម៌ និងការអប់រំ
- វាលស្រែ៖តំណាងឱ្យវិស័យកសិកម្មដែលបង្ហាញពីភាពសម្បូរសប្បាយរុងរឿង និងនិរន្តភាពនៃវិស័យកសិកម្មជាពិសេសភោគផលនៃដំណាំស្រូវ
- ប្រឡាយទឹក៣០កញ្ញា៖តំណាងឱ្យទឹក ដែលបង្ហាញពីភាពសំបូរបែបនៃប្រព័ន្ធធារាសាស្ត្រសម្រាប់ស្រោចស្រពដំណាំផ្សេងៗ ក្នុងឃុំសាន់គ
- ត្បាល់បុកអំបុកនិងអំបុក៖តំណាងឱ្យវិស័យកសិកម្ម វប្បធម៌ អរិយធម៌ ការសាមគ្គីភាព និងភាពអត់ធ្មត់
- ក្បាច់កាំទាំង៧៖តំណាងឱ្យវិស័យសិប្បកម្ម និងឧស្សាហកម្ម
- ភ្លីក្បាច់រចនាបទខ្មែរ៖តំណាងឱ្យការអប់រំ ប្រពៃណី សិល្បៈ និងវប្បធម៌។

# ឧបសម្ព័ន្ធគតិយុត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខៈ ៥៤០១៤ប្រក

# ប្រកាស
## ស្តីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំ នៃឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៦៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥
- យោងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅឃុំសាន់គ លេខកូដ ០៦-០២៥ នៃខេត្តកំពង់ធំ (ទម្រង់បែបបទ១១១៨) របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២

## សម្រេច

**ប្រការ១.-**

ទទួលស្គាល់សមាសភាពជាប្រធានក្រុមប្រឹក្សាឃុំ និងសមាជិកក្រុមប្រឹក្សាឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | លោក | ជូ សួន | ជាប្រធានក្រុមប្រឹក្សាឃុំ |
| ២- | លោក | ជឹម ស៊ុនលី | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៣- | លោក | ខ្វៃ ធាំ | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៤- | លោក | សៅ ផ្លយ | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៥- | លោក | ភិន ឃាត | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៦- | លោកស្រី | ទូច ធារ័ត្ន | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៧- | លោក | ហ៊ឹម សម្ល័ស | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៨- | លោក | ធាតុ កុសល | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៩- | លោក | ហ៊ិត ហ៊ត | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ១០- | លោក | ឈិន ឆង | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ១១- | លោក | ឌី គក់ | ជាសមាជិកក្រុមប្រឹក្សាឃុំ។ |

**ប្រការ២.-**

ទទួលស្គាល់សមាសភាពជាមេឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | លោក | ជូ សួន | ជាមេឃុំ |
| ២- | លោក | ជឹម ស៊ុនលី | ជាជំទប់ទី១ |
| ៣- | លោក | ខ្វៃ ធាំ | ជាជំទប់ទី២។ |

**ប្រការ៣.-**

ការអនុវត្តការងារប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំ នៃឃុំសាន់គ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ១៣រោច ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អង្គភាពប្រឆាំងអំពើពុករលួយ
  "ដើម្បីជូនជ្រាប"
- រដ្ឋបាលខេត្ត ស្រុក ឃុំ សាមី
- ដូចក្នុងប្រការ១
  "ដើម្បីមុខការ"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ